# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ២




វត្តនិគ្រោធវ័ន "គល់ទទឹង"

# អភិធម្មត្ថសង្គហៈ

# បរិច្ឆេទទី ២


*រៀបរៀងដោយ*

**ភិក្ខុ អគ្គធីរោ គង់ សុមិត្ត**



*ព.ស. ២៥៥៥*

ឈ្មោះសៀវភៅ **អភិធម្មត្ថសង្គហៈ បរិច្ឆេទទី ២**

រៀបរៀងដោយ ភិក្ខុ **អគ្គធីរោ គង់ សុមិត្ត**

ផ្ទៀងផ្ទាត់ដោយ លោកម្ចាស់គ្រូ ទឹម សៀត

| | |
|---|---|
| ភិក្ខុ សាន សប្បាយ | ភិក្ខុ សៅ ប៊ុនថេង |
| ភិក្ខុ គូ សុភាព | សាមណេរ ញ៉ិប យ័ន្ត |
| ភិក្ខុ អ៊ឹម សុទ្ធា | សាមណេរ ម៉ៃ ភារា |
| ភិក្ខុ សៀង សៀត | សាមណេរ លីម ណារ៉ុម |
| ភិក្ខុ ថាវ ប៊ុនថេន | សាមណេរ សុខ ណាត |

កាលបរិច្ឆេទ ព.ស. ២៥៥៥

ស្ថានទីធ្វើ ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន

"គល់ទទឹង" សង្កាត់ព្រែកថ្មី

ខណ្ឌមានជ័យ រាជធានីភ្នំពេញ

# សម្ដែងព្រះអភិធម្ម នៅឋានតាវត្តិង្ស

កាលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ចាំព្រះវស្សាទី៧ នៅឋានតាវត្តិង្សទេវលោក ក្នុងគ្រាដែលបានសំដែងយមកបាដិហារ្យផ្ចាញ់ពួកតិរ្ថិយរួចហើយ បានគង់លើសិលាសនៈ ឈ្មោះបណ្ឌុកម្ពល ក្រោមដើមបារិឆត្ត ទ្រង់ព្រះសិរីសោភា ដូចព្រះអាទិត្យឧទ័យឡើងលើភ្នំយុគន្ធរ ដែលពួកនៃទេវតាទាំងឡាយក្នុងម៉ឺនចក្រវាឡបានមកប្រជុំគ្នា ហែហមសម្ដេចព្រះបរមសាស្ដាចារ្យ ទ្រង់ធ្វើសន្ទុសិតទេវបុត្រដែលធ្លាប់ជាពុទ្ធមាតា ឱ្យជាប្រមាននៃពួកទេវតាទាំងឡាយ ហើយត្រាស់កថាមគ្គព្រះអភិធម្មថា "**កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា**"ជាដើម ទ្រង់សម្ដែងដោយន័យនេះ ជាប់តរហូតអស់មួយព្រះវស្សា ដោយតេជៈនៃព្រះសព្វញ្ញុតញ្ញាណនោះ ៗ ក៏កាលដែលទ្រង់សម្ដែងធម៌នោះ ក្នុងវេលាភិក្ខាចារទ្រង់និម្មិតព្រះពុទ្ធនិមិត្តដោយទ្រង់អធិដ្ឋានថា "ព្រះពុទ្ធនិមិត្ត

នេះ ចូរសម្ដែងធម៌ ឈ្មោះប៉ុណ្ណោះ ដរាបដល់តថាគតមក” ហើយក៏ស្ដេចយាងទៅព្រៃហេមពាន្ត ទ្រង់ទំពាឈើស្ទន់ ឈ្មោះនាគលតា ខ្ពុរព្រះឱស្ឋក្នុងស្រះអនោតត្ត នាំបិណ្ឌបាត អំពីឧត្តរកុរុទ្វីប បានធ្វើភត្តកិច្ចក្នុងរោងធំទូលាយហើយ ។ ព្រះសារីបុត្រទៅធ្វើវត្តចំពោះព្រះសាស្ដាក្នុងទីនោះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ជាទេវតារបស់ទេវតា ជាអ្នកនាំវិសេសអង្គនោះ កាលទ្រង់សំដែងអភិធម្មណា ដល់ទេវតាទាំងឡាយហើយ ក៏បានត្រាស់ប្រាប់ដល់ព្រះសារីបុត្តត្ថេរ អ្នកឧបដ្ឋាកព្រះមហេសីជាម្ចាស់ ក្នុងអនោតត្តស្រះ ដោយន័យ (សង្ខេប) ទៀតថា “ម្នាលសារីបុត្រ ថ្ងៃនេះតថាគតបានសម្ដែងធម៌ឈ្មោះប៉ុណ្ណោះ អ្នកចូរប្រាប់ដល់ (ភិក្ខុ ៥០០) ជាកូនសិស្សរបស់អ្នក” ព្រះថេរៈបានស្ដាប់ហើយ ក៏បាននិមន្តមកកាន់លំនៅឋាន ហើយប្រាប់ដល់ភិក្ខុទាំងឡាយ, ព្រះអភិធម្មនោះ ដែលភិក្ខុទាំងឡាយបានទ្រទ្រង់ចាំទុកហើយ ដោយប្រការយ៉ាងនេះ ។

# ជីវប្រវត្តិសង្ខេប

ភិក្ខុ **គង់-សុមិត្ត** គង់នៅពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន គល់ទទឹង

ញោមប្រុស ឈ្មោះ គង់-តិក( ស្លាប់ ) ញោមស្រី ឈ្មោះ ហុក-តាង រស់នៅក្នុងភូមិខ្វិត ឃុំព្រែកខ្ពប ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។

កើតនៅថ្ងៃព្រហស្បតិ៍ ៩ កើត ខែមិគសិរ ឆ្នាំ ថោះ ព.ស. ២៥១៩ - គ.ស. ១៩៧៦ ។ មានបងប្អូន ៧ នាក់ គឺ ប្រុស ៥ នាក់ ស្រី ២ នាក់. ជាកូនពៅ

ក្នុងកុមារ បានចូលរៀនសាលារដ្ឋ ( ក្តាំងផា និង ព្រែកហ្លួង )ដល់ថ្នាក់ទី ៨ ។

ក្នុងព.ស.២៥៣៧ មានអាយុ១៩ឆ្នាំ បួសជាសាមណេរ ក្នុងសំណាក់ឧបជ្ឈាយ៍ ព្រះនាម ឡយ-លឿង វត្តស្លាកែត មកគង់នៅវត្តក្តាំងផា ខេត្តបាត់ដំបង ។

ព.ស. ២៥៣៨ មានអាយុគ្រប់ ២០ បានឧបសម្បទាជាភិក្ខុភាវៈ ។ ព.ស. ២៥៣៩ មកគង់នៅវត្តសមសាន្ត (ខេត្តបាត់ដំបង) រៀនវិន័យ-អភិធម្ម ។ ព.ស. ២៥៤០ មកនៅវត្តនិគ្រោធវ័ន ខេត្តកណ្តាល រៀនធម៌វិន័យបន្ត ។ ព.ស. ២៥៤១ ចេញទៅគង់នៅវត្តខេមវ័ន (ខេត្តកំចាម) បង្រៀនធម៌វិន័យ ។ ព.ស. ២៥៤៥ បានត្រឡប់មកវត្តនិគ្រោធវ័នវិញហើយលាសិក្ខា បានខិតខំ រៀបចំ និងជួយសរសេរសៀវភៅធម៌-វិន័យ ។ ព.ស. ២៥៤៦ បានបួសជាសាមណេរវិញទៀត ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ ព្រះនាម ឃី-ទិត វត្តកោះក្របី ឃុំព្រែកថ្មី ស្រុកគៀនស្វាយ ខេត្តកណ្តាល បានជួយបង្រៀនព្រះវិន័យដល់ព្រះសង្ឃ ក្នុងវត្តនិគ្រោធវ័ន ។ ព.ស. ២៥៤៧ បានឧបសម្បទាជាភិក្ខុ បានបង្រៀនព្រះវិន័យដល់ព្រះសង្ឃ បង្រៀនអភិធម្មដល់ដូនជី ក្នុងវត្តនិគ្រោធវ័ន និងខិតខំរៀបចំសៀវភៅធម៌-វិន័យរហូតមក ។

# អភិធម្មត្ថសង្គហកថា

គម្ពីរអភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ព្រះអនុរុទ្ធាចារ្យ បានចងក្រងឡើង ។

អភិធម្មត្ថសង្គហៈ មាន ៩ បរិច្ឆេទ គឺ

បរិច្ឆេទទី១ ចិត្តសង្គហវិភាគ ការសម្ដែងសង្គ្រោះនិងចែកចិត្ត ៨៩ ឬ១២១

បរិច្ឆេទទី២ ចេតសិកសង្គហវិភាគ ការសម្ដែងសង្គ្រោះនិងចែកចេតសិក ៥២

បរិច្ឆេទទី៣ បកិណ្ណកសង្គហៈ ការសម្ដែងសង្គ្រោះនិងចែកបកិណ្ណក ៦ ពួក

បរិច្ឆេទទី៤ វិថីសង្គហវិភាគ ការសម្ដែងសង្គ្រោះនិងចែកវិថីចិត្ត

បរិច្ឆេទទី៥ វិថីវិមុត្តសង្គហវិភាគ ការសម្ដែងសង្គ្រោះនិងចែកវិថីវិមុត្ត

បរិច្ឆេទទី៦ រូបសង្គហវិភាគ-និព្វានបរមត្ថ ការសម្ដែងសង្គ្រោះនិងចែករូបនិងនិព្វាន

បរិច្ឆេទទី៧ សមុច្ចយសង្គហវិភាគ ការសម្ដែងសង្គ្រោះនិងចែកពួកធម៌ជាក្រុម ៗ

បរិច្ឆេទទី៨ បច្ចយសង្គហវិភាគ ការសម្ដែងសង្គ្រោះនិងចែកបច្ច័យ១២ និង២៤

បរិច្ឆេទទី៩ កម្មដ្ឋានវិភាគ ការសម្ដែងចែកកម្មដ្ឋាន ៤០ និងវិបស្សនា ។

សៀវភៅអភិធម្មនេះ ព្រះអនុរុទ្ធាចារ្យបានប្រមូលចងក្រងអំពីបិដក និងអដ្ឋកថា ហើយបានចែកជាបរិច្ឆេទតាមប្រភេទនៃបរមត្ថធម៌ ដើម្បីងាយស្រួលក្នុងការសិក្សា គឺបរិច្ឆេទទី១ សម្ដែងចិត្តបរមត្ថ, បរិច្ឆេទទី២ សម្ដែងចេតសិកបរមត្ថ, បរិច្ឆេទទី៣, ៤, ៥ សម្ដែងចិត្តបរមត្ថ និងចេតសិកបរមត្ថរួមគ្នា, បរិច្ឆេទទី ៦ សម្ដែងរូបបរមត្ថ, និងនិព្វានបរមត្ថ, បរិច្ឆេទទី៧, ៨, ៩ សម្ដែងបរមត្ថទាំង ៤ រួមគ្នា ។

# បុព្វកថា

សៀវភៅអភិធម្មនេះ ខ្ញុំបានសរសេរក្នុងព.ស. ២៥៤៥ ចប់នៅក្នុងព.ស. ២៥៤៧ ។ ព.ស. ២៥៥២ បានរៀបចំជាសៀវភៅធំ ឈ្មោះថា អភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ។ ព.ស. ២៥៥៥ ដោយសេចក្តីត្រូវរបស់អ្នកសិក្សា ក៏បានចែកតាមបរិច្ឆេទនីមួយ ៗវិញ ដើម្បីងាយកាន់សិក្សា ។

ការរៀបចំសៀវភៅអភិធម្មត្ថសង្គហៈនេះ បានចប់សព្វគ្រប់ ហើយ បើមានពាក្យឬសេចក្តីណានៅខុស ក៏សូមអភ័យទោស និងសូមមេត្តាកែ សម្រួលផងចុះ ។

គម្ពីរព្រះអភិធម្ម ជាគម្ពីរដែលសម្តែងឡើងនូវធម៌ពិត គឺ សច្ចធម៌ បរមត្ថធម៌ និងបង្ហាញនូវផ្លូវបដិបត្តិឆ្ពោះទៅរកទីរំលត់ទុក្ខ គឺ ព្រះនិព្វាន ។ សត្វលោកដែលកើតមកសុទ្ធតែមានអវិជ្ជា និងតណ្ហាគ្រប់គ្នា មានតែព្រះពុទ្ធនិងព្រះបច្ចេកពុទ្ធទេ ដែលអាចត្រាស់ដឹងនូវធម៌ពិត កម្ចាត់អវិជ្ជាបានដោយខ្លួនព្រះអង្គឯង ក្រៅពីនោះ ត្រូវតែអាស្រ័យ

ព្រះពុទ្ធ ដែលទ្រង់មានព្រះទ័យមហាករុណាសម្តែងប្រាប់ ទើបអាចយល់ដឹងស្គាល់ធម៌ពិត និងបានឃើញផ្លូវបដិបត្តិដល់ព្រះនិព្វានជាទីរំលត់ទុក្ខបាន ។

កាលបើពុទ្ធបរិស័ទទាំងអស់ សិក្សានូវព្រះអភិធម្មបានយល់ដឹងហើយ បញ្ញាក៏កើតឡើង បានឃើញនូវសភាវធម៌ពិតទាំងដែលយើងសព្វថ្ងៃបានជួប បានទាន់ព្រះធម៌កំពុងឋិតនៅសម្រាប់ក្រេបជញ្ជក់ធម្មរស ហើយធ្វើឱ្យយើងមានសម្រស់ក្នុងជីវិត មិនឋិតនៅក្នុងភាពស្ងិតស្រពោន និងសម្រេចមគ្គផលតាមឧបនិស្ស័យដែលយើងបានសន្សំមក, ព្រោះហេតុដូច្នេះទើបខ្ញុំព្យាយាមរៀបចំសៀវភៅនេះឡើង ។ ម្យ៉ាងទៀត សៀវភៅនេះ ក៏ដូចជាសាវកមួយអង្គដែលឈ្លាសវៃនាំយកព្រះពុទ្ធដីកាមកប្រាប់ ហើយពន្យល់សេចក្តីនោះ ឱ្យយើងបានយល់ដឹងឬចាត់ថា ជាគ្រូក៏បាន ។

ការរៀបចំសៀវភៅធម៌នេះ ជាបុណ្យកុសលមួយ

យ៉ាងល្អប្រសើរ ដែលខ្ញុំព្រះករុណា អាត្មាភាព និងពុទ្ធបរិស័ទទាំងឡាយ បានរួបរួមសាមគ្គីជួយឧបត្ថម្ភ ដោយកត្តាំងកាយចិត្ត និងថវិកា ជាចេតនាមហាកុសលថ្នាក់ធម្មទាន និងធម្មបូជា យ៉ាងពេញចិត្តគ្រប់ ៗគ្នា ។ ដោយអំណាចនៃបុណ្យនេះ នឹងនាំឱ្យបានទទួលនូវសេចក្ដីសុខ ជាពិសេស គឺបាននូវបញ្ញាដែលជាពន្លឺញ៉ាំងជីវិតឱ្យរុងរឿងគ្រប់ ៗ ជាតិរហូតដល់បានលះបង់នូវមន្ទិលគឺ កិលេស ដែលយើងគ្រប់ ៗ គ្នាចង់បាននូវ ការត្រាស់ដឹងនូវសច្ចធម៌ ឃើញច្បាស់នូវព្រះនិព្វាន ដែលជាទីបំផុតទុក្ខ ។ម្យ៉ាងទៀត បញ្ញានេះឯង អាចឱ្យសម្រេចតាមសេចក្ដីប្រាថ្នានោះបាន ។

ខ្ញុំព្រះករុណាអាត្មាភាព សូមអនុមោទនានូវបុណ្យកុសលរបស់ពុទ្ធបរិស័ទ ទាំងអស់ ដែលបានឧបត្ថម្ភថវិកាជាធម្មទាន និងការខិតខំសិក្សានេះ ។ ម្យ៉ាងទៀត សូមពុទ្ធ

បរិស័ទទាំងអស់ អនុមោទនាយកនូវបុណ្យដែលខ្ញុំព្រះករុណាអាត្មាភាព បានរៀបចំបោះពុម្ពព្រះអភិធម្មនេះផងចុះ ។ សូមឱ្យពុទ្ធបរិស័ទទាំងអស់ មានបញ្ញា ភ្លឺថ្លាមោះមុត ជាគ្រឿងត្រាស់ដឹងនូវសច្ចធម៌ សូមបានសម្រេចនូវសម្បត្តិលោកិយៈ និងលោកុត្តរៈ មានចិត្តល្អបរិសុទ្ធរួចផុតចាកទុក្ខដល់ព្រះនិព្វានគ្រប់ ៗ គ្នា កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអនុមោទនា !!!

ថ្ងៃ១៥កើត ខែស្រាពណ៍ ឆ្នាំថោះ ត្រីស័ក ព.ស.២៥៥៥

# ឯកសារវិគ្រោះ

| អក្សរកាត់ | អក្សរពេញ | ភាគគម្ពីរ |
|---|---|---|
| ទីឃ. សីល. | ទីឃនិកាយ សីលក្ខន្ធវគ្គ | បិដកភាគ១៤. ១៥. |
| ទីឃ. បាដិ. | ទីឃនិកាយ បាដិកវគ្គ | បិដកភាគ ១៨. ១៩ |
| សំយុ. ខន្ធ. | សំយុត្តនិកាយ ខន្ធវារវគ្គ | បិដកភាគ ៣៣ |
| សំយុ. មហា. | សំយុត្តនិកាយ មហាវារវគ្គ | បិដកភាគ ៣៧. ៣៨. ៣៩. |
| អង្គុ. ទុក. | អង្គុត្តរនិកាយ ទុកនិបាត | បិដកភាគ ៤០ |
| អង្គុ. តិក. | អង្គុត្តរនិកាយ តិកនិបាត | បិដកភាគ ៤១ |
| អង្គុ. សត្ត. | អង្គុត្តរនិកាយ សត្តកនិបាត | បិដកភាគ ៤៧ |
| ខុទ្ទ. បដិ. | ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ | បិដកភាគ ៦៩. ៧០. ៧១. |
| អភិ. សង្គ. | អភិធម្ម ធម្មសង្គណី | បិដកភាគ ៧៨. ៧៩. |
| អភិ. វិភ. | អភិធម្ម វិភង្គ | បិដកភាគ ៨០. ៨១. ៨២. |

មនោរថបូរណី អដ្ឋកថានៃអង្គុត្តរនិកាយឯកនិបាត ទុកនិបាត អដ្ឋកនិបាត

អត្ថយោជនា, វិភាវិនីដីកា, បរមត្ថទីបនីដីកា, ។

លេខដែលនៅបន្ទាប់គឺ ខាងដើមជាភាគគម្ពីរ កណ្តាលជាលេខឃ្នាប ខាងចុងជាលេខទំព័រ ឧទាហរណ៍ : ៣១. ៦៦/៦១ គឺ បិដកភាគ ៣១ លេខឃ្នាប ៦៦ ទំព័រ ៦១ ។

# បញ្ជីមាតិកា អភិធម្មត្ថសង្គហៈ

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**

សម្ដែងព្រះអភិធម្ម នៅឋានតាវត្តិង្ស ... ... ... ... ... ក
ជីវប្រវត្តិសង្ខេបគ ... ... ... ... ... ... ... ... ... ... ... ... គ
អភិធម្មត្ថសង្គហកថា ... ... ... ... ... ... ... ... ... ... ... ង
បុព្វកថា ... ... ... ... ... ... ... ... ... ... ... ... ... ... ... ឆ
ឯកសារវិគ្រោះ ... ... ... ... ... ... ... ... ... ... ... ... ... ជ
បញ្ជីមាតិកា ... ... ... ... ... ... ... ... ... ... ... ... ... ... ឋ

**អភិធម្មត្ថសង្គហៈ បរិច្ឆេទទី ២ ចេតសិកសង្គហវិភាគ**

សង្គហគាថាទី១ ... ... ... ... ... ... ... ... ... ... ... ... ១
លក្ខណាទិចតុក្កៈរបស់ចេតសិក ... ... ... ... ... ... ៣
ចេតសិក ៥២ ... ... ... ... ... ... ... ... ... ... ... ... ... ... ៤
១-អញ្ញសមានាចេតសិក ១៣ ... ... ... ... ... ... ... ៤
២-អកុសលចេតសិក ១៤ ... ... ... ... ... ... ... ... ៥
៣-សោភណចេតសិក ២៥ ... ... ... ... ... ... ... ... ៧
សម្ដែងចេតសិក ៥២ ដោយ ៣ រាសី ... ... ... ១១
សង្គហគាថាទី២ ... ... ... ... ... ... ... ... ... ... ... ១២

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**

អធិប្បាយចេតសិក ៥២ ... ... ... ... ... ... ... ... ... ... ... ១៤
អញ្ញសមានាចេតសិក ១៣ ... ... ... ... ... ... ... ... ១៤
សព្វចិត្តសាធារណចេតសិក ៧ ... ... ... ... ... ... ១៤
១-ផស្សចេតសិក ... ... ... ... ... ... ... ... ... ១៤
២-វេទនាចេតសិក ... ... ... ... ... ... ... ... ១៦
៣-សញ្ញាចេតសិក ... ... ... ... ... ... ... ... ២៧
៤-ចេតនាចេតសិក ... ... ... ... ... ... ... ... ២៨
៥-ឯកគ្គតាចេតសិក ... ... ... ... ... ... ... ... ៣០
៦-ជីវិតិន្ទ្រិយចេតសិក ... ... ... ... ... ... ... ៣១
៧-មនសិការចេតសិក ... ... ... ... ... ... ... ៣២
ចែកសព្វចិត្តសាធារណចេតសិក ដោយន័យផ្សេង ៗ ៣៦
បកិណ្ណកចេតសិក៦ ... ... ... ... ... ... ... ... ... ... ៣៨
១-វិតក្កចេតសិក ... ... ... ... ... ... ... ... ... ៣៨
២-វិចារចេតសិក ... ... ... ... ... ... ... ... ... ៣៩
៣-អធិមោក្ខចេតសិក ... ... ... ... ... ... ... ៤០

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**

៤-វិរិយចេតសិក ... ... ... ... ... ... ... ... ... ៤១
៥-បីតិចេតសិក ... ... ... ... ... ... ... ... ... ៤២
៦-ឆន្ទចេតសិក ... ... ... ... ... ... ... ... ... ៤៤
សម្តែងអញ្ញសមានាចេតសិក ១៣ ... ... ... ... ... ៤៥
អធិប្បាយ អកុសលចេតសិក ១៤ ... ... ... ... ៤៦
១-មោហចេតសិក ... ... ... ... ... ... ... ... ... ៤៧
២-អហិរិកចេតសិក ... ... ... ... ... ... ... ... ៤៩
៣-អនោត្តប្បចេតសិក ... ... ... ... ... ... ... ៥០
៤-ឧទ្ធច្ចចេតសិក ... ... ... ... ... ... ... ... ... ៥១
៥-លោភចេតសិក ... ... ... ... ... ... ... ... ... ៥២
៦-ទិដ្ឋិចេតសិក ... ... ... ... ... ... ... ... ... ... ៥៨
៧-មានចេតសិក ... ... ... ... ... ... ... ... ... ៦២
៨-ទោសចេតសិក ... ... ... ... ... ... ... ... ៦៥
៩-ឥស្សាចេតសិក ... ... ... ... ... ... ... ... ៧០
១០-មច្ឆរិយចេតសិក ... ... ... ... ... ... ... ៧១

**មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ**

១១-កុក្កុច្ចចេតសិក ... ... ... ... ... ... ... ... ៧៣
១២-ថីនចេតសិក ... ... ... ... ... ... ... ... ... ៧៤
១៣-មិទ្ធចេតសិក ... ... ... ... ... ... ... ... ... ៧៥
១៤-វិចិកិច្ឆាចេតសិក ... ... ... ... ... ... ... ... ៧៦
សម្តែងអកុសលចេតសិក ១៤ ... ... ... ... ... ... ៧៨
សោភណចេតសិក ២៥ ... ... ... ... ... ... ... ... ៧៩
១-សទ្ធាចេតសិក ... ... ... ... ... ... ... ... ... ៧៩
២-សតិចេតសិក ... ... ... ... ... ... ... ... ... ៨៣
៣-ហិរិចេតសិក ... ... ... ... ... ... ... ... ... ៨៤
៤-ឱត្តប្បចេតសិក ... ... ... ... ... ... ... ... ៨៥
៥-អលោភចេតសិក ... ... ... ... ... ... ... ... ៨៦
៦-អទោសចេតសិក ... ... ... ... ... ... ... ... ៨៨
៧-តត្រមជ្ឈត្តតាចេតសិក ... ... ... ... ... ... ៨៩
៨-កាយបស្សទ្ធិ ៩-ចិត្តបស្សទ្ធិ ... ... ... ... ៩០
១០-កាយលហុតា ១១-ចិត្តលហុតា ... ... ... ៩១

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**


១២-កាយមុទុតា ១៣-ចិត្តមុទុតា ... ... ... ៩២

១៤-កាយកម្មញ្ញតា ១៥-ចិត្តកម្មញ្ញតា ... ... ៩៣

១៦-កាយបាគុញ្ញតា ១៧-ចិត្តបាគុញ្ញតា ... ... ៩៤

១៨-កាយុជុកតា ១៩-ចិត្តុជុកតា ... ... ... ៩៥

២០-សម្មាវាចាចេតសិក ... ... ... ... ... ... ... ៩៧

២១-សម្មាកម្មន្តចេតសិក ... ... ... ... ... ... ៩៨

២២-សម្មាអាជីវចេតសិក ... ... ... ... ... ... ១០០

២៣-ករុណាចេតសិក ... ... ... ... ... ... ... ១០២

២៤-មុទិតាចេតសិក ... ... ... ... ... ... ... ... ១០៤

២៥-បញ្ញិន្ទ្រិយចេតសិក ... ... ... ... ... ... ... ១០៦

សម្តែងបញ្ញាចេតសិក ប្រកបជាមួយចិត្ត ៧៩ ... ១១៣

សម្តែងសោភណចេតសិក ២៥ ... ... ... ... ... ... ១១៤

សម្បយោគន័យ ... ... ... ... ... ... ... ... ... ... ... ... ... ១១៥

សង្គហគាថាទី៣ ... ... ... ... ... ... ... ... ... ... ... ១១៥

សង្គហគាថាទី៤ ... ... ... ... ... ... ... ... ... ... ... ១១៦

**មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ**

អធិប្បាយសម្បយោគ ១៦ ន័យ ... ... ... ... ... ១២០
សង្គហគាថាទី៥-៦ ... ... ... ... ... ... ... ... ... ... ១២០
សង្គហគាថាទី៧ សម្បយោគអកុសលចេតសិក ១២៦
សង្គហគាថាទី៨ សម្បយោគសោភណចេតសិក ១២៨
អនិយតយោគី និងនិយតយោគីចេតសិក ... ... ១៣២
សង្គហគាថាទី៩ អនិយតយោគីចេតសិក ... ... ១៣៣
អធិប្បាយអនិយតយោគីជាដើម ... ... ... ... ... ១៣៤
នានាកទាចិចេតសិក ... ... ... ... ... ... ... ... ... ... ១៣៥
កទាចិចេតសិក ... ... ... ... ... ... ... ... ... ... ... ១៣៦
សហាកទាចិចេតសិក ... ... ... ... ... ... ... ... ... ១៣៦
អធិប្បាយ និយតយោគីចេតសិក ... ... ... ... ... ១៣៨
សង្គហន័យ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ១៤១
សង្គហគាថាទី១០ ... ... ... ... ... ... ... ... ... ... ១៤១
សង្គហៈដោយសង្ខេប ៥ ន័យ ... ... ... ... ... ១៤២
សង្គហៈដោយពិស្តារ ៣៣ ន័យ ... ... ... ... ... ១៤៣

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ


សង្គហគាថាទី១១ ... ... ... ... ... ... ... ... ... ... ១៤៣
អធិប្បាយលោកុត្តរចិត្ត ៥ ន័យ ... ... ... ... ... ១៤៤
សង្គហគាថាទី១២ ... ... ... ... ... ... ... ... ... ... ១៤៥
អធិប្បាយមហគ្គតចិត្ត ៥ ន័យ ... ... ... ... ... ... ១៤៦
សង្គហគាថាទី១៣ ... ... ... ... ... ... ... ... ... ... ១៤៨
សង្គហគាថាទី១៤ ... ... ... ... ... ... ... ... ... ... ១៥០
សង្គហគាថាទី១៥ ... ... ... ... ... ... ... ... ... ... ១៥២
សង្គហគាថាទី១៦ ... ... ... ... ... ... ... ... ... ... ១៥៥
សព្វាកុសលយោគីចេតសិក ... ... ... ... ... ... ... ១៥៩
សង្គហគាថាទី១៧ ... ... ... ... ... ... ... ... ... ... ១៦០
សង្គហគាថាទី១៨ អហេតុកសង្គហៈ មាន ... ... ១៦១
តទុភយមិស្សកន័យ ... ... ... ... ... ... ... ... ... ... ... ... ១៦៤
សង្គហគាថាទី១៩ ... ... ... ... ... ... ... ... ... ... ១៦៤
ចេតសិក ប្រកបជាមួយចេតសិក ... ... ... ... ... ១៦៧
អវសានគាថា ... ... ... ... ... ... ... ... ... ... ... ... ១៧២

# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ២ ចេតសិកសង្គហវិភាគ

*នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។*

### សង្គហគាថា

១. ឯកុប្បាទនិរោធា ច ឯកាលម្ពនវត្ថុកា
ចេតោយុត្តា ទ្វិបញ្ញាស ធម្មា ចេតសិកា មតា ។

*ធម៌ទាំងឡាយ ៥២ ដែលឈ្មោះថា ចេតសិក ព្រោះមានលក្ខណៈ ៤ យ៉ាង គឺ កើតព្រមជាមួយនឹងចិត្ត ១ រលត់ព្រមជាមួយនឹងចិត្ត ១ មានអារម្មណ៍តែមួយជាមួយនឹងចិត្ត ១ មានទីកើតតែមួយជាមួយនឹងចិត្ត ១ ។*

*ព្រះអនុរុទ្ធាចារ្យ កាលចែកចិត្តដោយប្រភេទនៃភូមិ ជាតិ សម្បយោគ សង្ខារ ឈាន អារម្មណ៍ និងមគ្គ តាម*

សមគួរហើយ, ឥឡូវនេះ ដើម្បីផ្ដើមតាំងលក្ខណៈរបស់ចេតសិក ដោយការសម្ដែងនូវលក្ខណៈនៃសម្បយោគ ៤ យ៉ាង ទើបលើកចេតសិកធម៌ឡើងសម្ដែង ៣ រាសី គឺ អញ្ញសមានារាសី អកុសលរាសី និងសោភណរាសី ហើយសម្ដែងសម្បយោគ ដោយអាការ ១៦ យ៉ាង និងសង្គហវិធី ៣៣ យ៉ាងនៃចេតសិកទាំងនោះ, ទើបផ្ដើមពាក្យថា **ឯកុប្បាទនិរោធា ច** ជាដើម ។

ចេតសិក ជាធម៌ដែលត្រូវអាស្រ័យចិត្តកើតឡើងនេះ អធិប្បាយថា ប្រៀបដូចជាសិស្ស និងអាចារ្យ បើមានអាចារ្យក៏ត្រូវមានសិស្ស ឬថាជាសិស្ស ក៏ត្រូវមានអាចារ្យ, មិនអាចអត់ណាមួយបានទេ ព្រោះវត្ថុទាំង ២ នេះ ប្រាកដព្រមគ្នា ។

**ចេតសិក** មានវិចនត្ថៈថា **ចេតសិ ភវំ ចេតសិកំ វា ចេតសិ និយុត្តំ = ចេតសិកំ :** ធម្មជាតិកើតក្នុងចិត្ត ឬប្រកបក្នុងចិត្ត ឈ្មោះថា ចេតសិក ។

មួយទៀត អាការដែលចេតសិក ប្រកបជាមួយនឹង

ចិត្តជានិច្ចនោះ ហៅថា **ចេតោយុត្តា** ហៅថា **ចេតោយុត្ត** **លក្ខណៈ** ដែលជាការប្រកបព្រមគ្នា ដោយលក្ខណៈ៤ គឺ ៖

**១-ឯកុប្បាទៈ** កើតព្រមជាមួយនឹងចិត្ត

**២-ឯកនិរោធៈ** រលត់ព្រមជាមួយនឹងចិត្ត

**៣-ឯកាលម្ពនៈ** មានអារម្មណ៍តែមួយជាមួយនឹងចិត្ត

**៤-ឯកវត្ថុកៈ** មានវត្ថុជាកន្លែងកើតតែមួយជាមួយនឹងចិត្ត

## លក្ខណាទិចតុក្កៈរបស់ចេតសិក

**១-ចិត្តនិស្សិតលក្ខណំ** មានការអាស្រ័យចិត្ត ជាលក្ខណៈ

**២-អវិយោគុប្បាទនរសំ** មានការកើតរួមជាមួយចិត្ត ជាកិច្ច

**៣-ឯកាលម្ពនបច្ចុប្បដ្ឋានំ** មានអារម្មណ៍តែមួយជាមួយនឹងចិត្ត ជាផល

**៤-ចិត្តុប្បាទបទដ្ឋានំ** មានការកើតឡើងនៃចិត្ត ជាហេតុជិត ។

ចិត្តនិងចេតសិកទាំង ២ នេះ ជានាមធម៌ ទើបប្រកបជាមួយគ្នាបានស្និទ្ធ ដូចជាតែមួយ តែផ្សេងគ្នាដោយកិច្ច គឺ

ចិត្តជាប្រមានក្នុងការដឹងអារម្មណ៍, ចំណែកចេតសិក មានការកើតរួមនឹងចិត្ត និងតាក់តែងចិត្តឱ្យប្រព្រឹត្តទៅផ្សេង ៗ ។

## ចេតសិក ៥២

ចេតសិក ៥២ ចែកជា ៣ ប្រភេទធំ គឺ ***អញ្ញសមានាចេតសិក ១៣ អកុសលចេតសិក ១៤ សោភណចេតសិក ២៥***

## ១-អញ្ញសមានាចេតសិក ១៣

<u>សព្វចិត្តសាធារណចេតសិក</u> ៧ គឺ ៖

១-ផស្សចេតសិក មានការប៉ះខ្ទប់ ជាលក្ខណៈ

២-វេទនាចេតសិក មានការសោយអារម្មណ៍ ជាលក្ខណៈ

៣-សញ្ញាចេតសិក មានការចងចាំ ជាលក្ខណៈ

៤-ចេតនាចេតសិក មានការតាំងចិត្ត ជាលក្ខណៈ

៥-ឯកគ្គតាចេតសិក មានការមិនរវើរវាយ ជាលក្ខណៈ

៦-ជីវិតិន្ទ្រិយចេតសិក មានការរក្សាសហជាតធម៌ ជាលក្ខណៈ
៧-មនសិការចេតសិក មានការប្រមូលសហជាតធម៌ ជាលក្ខណៈ

<u>បកិណ្ណកចេតសិក</u> ៦ គឺ

១-វិតក្កចេតសិក មានការលើកចិត្តឡើងកាន់អារម្មណ៍ ជាលក្ខណៈ
២-វិចារចេតសិក មានការពិចារណាអារម្មណ៍ ជាលក្ខណៈ
៣-អធិមោក្ខចេតសិក មានការសន្និដ្ឋាន ជាលក្ខណៈ
៤-វីរិយចេតសិក មានភាពឧស្សាហ៍ ជាលក្ខណៈ
៥-បីតិចេតសិក មានការឆ្អែតចិត្ត ជាលក្ខណៈ
៦-ឆន្ទចេតសិក មានការប្រាថ្នាដើម្បីធ្វើ ជាលក្ខណៈ

## ២-អកុសលចេតសិក ១៤

<u>មោចតុក្កៈ</u> ៤ គឺ

១-មោហចេតសិក មានការមិនដឹង( សភាវធម៌ ) តាម

សេចក្តីពិត ជាលក្ខណៈ

២-អហិរិកចេតសិក មានការមិនរង្កៀស ឬមិនខ្មាសចំពោះទុច្ចរិត មានកាយទុច្ចរិតជាដើម ជាលក្ខណៈ

៣-អនោត្តប្បចេតសិក មានការមិនតក់ស្លុតចំពោះទុច្ចរិត ជាលក្ខណៈ

៤-ឧទ្ធច្ចចេតសិក មានការមិនចូលទៅស្ងប់ ជាលក្ខណៈ

<u>លោភតិកៈ</u> ៣ គឺ

៥-លោភចេតសិក មានការកាន់យកអារម្មណ៍ ជាលក្ខណៈ

៦-ទិដ្ឋិចេតសិក មានការប្រកាន់ទុក ដោយមិនត្រូវទំនង ជាលក្ខណៈ

៧-មានចេតសិក មានការលើកខ្លួន ( អួតខ្លួន ) ជាលក្ខណៈ

<u>ទោចតុក្កៈ</u> ៤ គឺ

៨-ទោសចេតសិក មានការកាច ជាលក្ខណៈ

៩-ឥស្សាចេតសិក មានការច្រណែនសម្បត្តិអ្នកដទៃ ជាលក្ខណៈ

១០_មច្ឆរិយចេតសិក មានការបិទបាំងសម្បត្តិរបស់ខ្លួនដែលបានហើយ ឬដែលគួរបាន ជាលក្ខណៈ

១១_កុក្កុច្ចចេតសិក មានការក្តៅក្រហាយចិត្តជាខាងក្រោយជាលក្ខណៈ

<u>ថីទុកៈ</u> ២ គឺ

១២_ថីនចេតសិក មានភាពមិនឧស្សាហ៍ ជាលក្ខណៈ

១៣_មិទ្ធចេតសិក មានភាពមិនគួរដល់ការងារ ជាលក្ខណៈ

<u>ឯកវិចិកិច្ឆា</u> ១ គឺ

១៤_វិចិកិច្ឆាចេតសិក មានការសង្ស័យ ជាលក្ខណៈ

## ៣_សោភណចេតសិក ២៥

<u>សោភណសាធារណចេតសិក</u> ១៩ គឺ

១_សទ្ធាចេតសិក មានការជឿ ជាលក្ខណៈ

២_សតិចេតសិក មានការរលឹកបាន មិនរវើរវាយ ជាលក្ខណៈ

៣-ហិរិចេតសិក មានការខ្មើសចំពោះបាប ជាលក្ខណៈ

៤-ឱត្តប្បចេតសិក មានការតក់ស្លុតចំពោះបាប ជាលក្ខណៈ

៥-អលោភចេតសិក មានការមិនជាប់នៅក្នុងអារម្មណ៍ ជាលក្ខណៈ

៦-អទោសចេតសិក មានការមិនកាច ជាលក្ខណៈ

៧-តត្រមជ្ឈត្តតាចេតសិក មានការនាំចិត្តនិងចេតសិកទៅដោយស្មើ ជាលក្ខណៈ

៨-កាយបស្សទ្ធិចេតសិក មានការស្ងប់នាមក្ខន្ធ៣ ជាលក្ខណៈ

៩-ចិត្តបស្សទ្ធិចេតសិក មានការស្ងប់ចិត្ត ជាលក្ខណៈ

១០-កាយលហុតាចេតសិក មានការស្ងប់ភាពធ្ងន់របស់កាយ ជាលក្ខណៈ

១១-ចិត្តលហុតាចេតសិក មានការស្ងប់ភាពធ្ងន់របស់ចិត្ត ជាលក្ខណៈ

១២-កាយមុទុតាចេតសិក មានការស្ងប់ភាពរឹងរបស់នាមខន្ធ ៣ ជាលក្ខណៈ

១៣-ចិត្តមុទុតាចេតសិក មានការស្ងប់ភាពរឹងរបស់ចិត្ត ជាលក្ខណៈ

១៤-កាយកម្មញ្ញតាចេតសិក មានការរម្ងាប់កាយដែលមិនគួរដល់ការងារ ជាលក្ខណៈ

១៥-ចិត្តកម្មញ្ញតាចេតសិក មានការរម្ងាប់ចិត្តដែលមិនគួរដល់ការងារ ជាលក្ខណៈ

១៦-កាយបាគុញ្ញតាចេតសិក មានការស្ងប់ភាពឈឺរបស់កាយ ជាលក្ខណៈ

១៧-ចិត្តបាគុញ្ញតាចេតសិក មានការស្ងប់ភាពឈឺរបស់ចិត្ត ជាលក្ខណៈ

១៨-កាយុជុកតាចេតសិក មានការស្ងប់ភាពវៀចរបស់កាយ ជាលក្ខណៈ

១៩-ចិត្តុជុកតាចេតសិក មានការស្ងប់ភាពវៀចរបស់ចិត្ត ជាលក្ខណៈ

<u>វិរតិចេតសិក</u> ៣ គឺ

២០-សម្មាវាចាចេតសិក មានការមិនកន្លងវត្ថុដែលជាទីតាំងនៃវចីទុច្ចរិត ជាលក្ខណៈ

២១-សម្មាកម្មន្តចេតសិក មានការមិនកន្លងវត្ថុដែលជាទីតាំងនៃកាយទុច្ចរិត ជាលក្ខណៈ

២២-សម្មាអាជីវចេតសិក មានការមិនកន្លងវត្ថុដែលជាទីតាំងនៃកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ជាលក្ខណៈ

<u>អប្បមញ្ញាចេតសិក</u> ២ គឺ

២៣-ករុណាចេតសិក មានសេចក្ដីត្រូវការបំបាត់ទុក្ខអ្នកដទៃជាលក្ខណៈ

២៤-មុទិតាចេតសិក មានការសរសើរសម្បត្តិរបស់អ្នកដទៃជាលក្ខណៈ

<u>បញ្ញិន្ទ្រិយចេតសិក</u> ១ គឺ

២៥-បញ្ញាចេតសិក មានការចាក់ធ្លុះធម៌តាមសេចក្ដីពិត ជាលក្ខណៈ

## សម្តែងចេតសិក ៥២ ដោយ ៣ រាសី

- ចេតសិក ៥២
  - អញ្ញសមានាចេតសិក ១៣
    - សព្វចិត្តសាមារណចេតសិក ៧
    - បកិណ្ណកចេតសិក ៦
  - អកុសលចេតសិក ១៤
    - មោចតុក្កចេតសិក ៤
    - លោតិកចេតសិក ៣
    - ទោចតុក្កចេតសិក ៤
    - ថីទុកចេតសិក ២
    - វិចិកិច្ឆាចេតសិក ១
  - សោភណចេតសិក ២៥
    - សោភណសាមារណចេតសិក ១៩
    - វិរតិចេតសិក ៣
    - អប្បមញ្ញាចេតសិក ២
    - បញ្ញាចេតសិក ១

អញ្ញសមានាចេតសិក ១៣ ជា ១ រាសី

អកុសលចេតសិក ១៤ ជា ១ រាសី

សោភណចេតសិក ២៥ ជា ១ រាសី

## សង្គហគាថា

២. តេរសញ្ញសមានា ច ចុទ្ទសាកុសលា តថា
សោភណា បញ្ចវីសាតិ ទ្វិបញ្ញាស បវុច្ចរេ ។

***ធម៌ គឺ ចេតសិក៥២ បណ្ឌិតពោលទុក៣ ប្រភេទ ដោយជាអញ្ញសមានាចេតសិក១៣ អកុសលចេតសិក ១៤ និង សោភណចេតសិក ២៥ ដោយប្រការដូច្នេះ ។***

*ពាក្យថា* ***អញ្ញសមានា*** *(**អញ្ញ+សមានា**) ប្រែថា ស្មើដោយធម៌ដទៃ ៗ គឺ ចេតសិកដែលប្រកបជាមួយនឹងចិត្តជាតិកុសល ក៏ជាកុសល, ប្រកបជាមួយនឹងចិត្តជាតិអកុសល ក៏ជាអកុសល, ប្រកបជាមួយនឹងអព្យាកតចិត្ត គឺចិត្តជាតិវិបាក និងជាតិកិរិយា ក៏ជាវិបាក និងជាកិរិយាដែរ ព្រោះហេតុនេះ ទើបហៅថា* ***អញ្ញសមានាចេតសិក*** *។*

*ពាក្យថា* ***សព្វចិត្តសាមារណៈ (សព្វ + ចិត្ត +***

**សាមារណ** ) ប្រែថា ទូទៅដល់ចិត្តទាំងពួង ។

ពាក្យថា **បកិណ្ណកៈ** បានដល់ ជាចេតសិកដែលខ្ចាត់ខ្ចាយ រាត់រាយ លាយគ្នា ឬហៅថា បន្តិចបន្តួច ។

ពាក្យថា **អកុសលចេតសិក** បានដល់ ចេតសិកដែលមិនល្អ ប្រកបជាមួយនឹងចិត្ត ក៏ធ្វើឱ្យចិត្តជាអកុសល ។

ពាក្យថា **សោភណចេតសិក** បានដល់ ចេតសិកដែលល្អ កាលប្រកបជាមួយចិត្ត ក៏ធ្វើចិត្ត ឱ្យជាកាមាវចរសោភណចិត្តខ្លះ ជារូបាវចរចិត្តខ្លះ អរូបាវចរចិត្តខ្លះ និងលោកុត្តរចិត្តខ្លះ ។

# អធិប្បាយចេតសិក ៥២

## អញ្ញសមានាចេតសិក ១៣

## សព្វចិត្តសាធារណចេតសិក ៧

### ១-ផស្សចេតសិក

*ផស្ស មានវិគ្រោះថា **ផុស្សតីតិ = ផស្សោ** ធម៌ឈ្មោះថា ផស្សៈ ព្រោះអត្ថថា ប៉ះខ្ទប់ ឬពាល់ត្រូវ ។*

***ផស្សៈ**នេះ លោកហៅថា **ផស្សាហារ** ព្រោះជាអាហារ គឺ ជាបច្ច័យ ។*

*មួយទៀត ផស្សចេតសិកនោះ ព្រះនាគសេនត្ថេរបានវិសជ្ជនា ឱ្យដល់ស្ដេចមិលិន្ទជ្រាបថា ៖*

*ដូចពពែ ២ ជល់គ្នា ពពែមួយប្រៀបដូចចក្ខុប្រសាទ ពពែមួយទៀត ប្រៀបដូចរូប (ពណ៌), ផស្សៈ ដូចការជល់គ្នារបស់សត្វពពែទាំង ២ នោះ, មួយទៀត ប្រៀបដូចការទះដៃ, មួយទៀត ប្រៀបដូចឈើវាយភ្លេង សម្រាប់គោះឱ្យជា*

ចង្វាក់ភ្លេង ក្នុងការរាំច្រៀង ។

## លក្ខណាទិចតុក្កៈរបស់ផស្សៈ

**១-ផុស្សនលក្ខណោ** មានការប៉ះខ្ទប់ ជាលក្ខណៈ

**២-សង្ឃដ្ដនរសោ** មានការធ្វើឱ្យចិត្ត និងអារម្មណ៍ ប៉ះខ្ទប់គ្នា ជាកិច្ច

**៣-សន្និបាតបច្ចុប្បដ្ឋានោ** មានការប្រជុំអារម្មណ៍ វត្ថុ ចិត្ត ជាផល

**៤-អាបាថគតវិសយបទដ្ឋានោ** មានអារម្មណ៍មកកាន់គន្លង ជាហេតុជិត ។

ផស្សចេតសិកនេះ មានអត្ថថា ប៉ះខ្ទប់អារម្មណ៍, កិច្ច គឺ នាទីរបស់ផស្សៈ គឺ ការប៉ះខ្ទប់អារម្មណ៍ដែលចិត្តដឹង, ផល ឬអាការប្រាកដនោះ ជាបច្ច័យធ្វើឱ្យធម៌ ៣ យ៉ាង គឺ អារម្មណ៍ វត្ថុ និងវិញ្ញាណ ប្រជុំគ្នា, មួយទៀត លោកពោលថា ផស្សៈ មានវេទនាជាអាការប្រាកដ ឬផល ហេតុដែលនឹង

ឱ្យកើតផស្សៈបាន ព្រោះមានអារម្មណ៍មកកាន់គន្លង ។

បណ្ឌិតគប្បីឃើញផស្សៈ ដូចមេគោ ត្រូវបកស្បែកចេញហើយ ព្រោះជាទីតាំងនៃវេទនា ។

ការដែលផស្សៈប៉ះខ្ទប់នឹងអារម្មណ៍ មិនដូចរូបនិងរូបប៉ះខ្ទប់គ្នា ព្រោះផស្សៈជានាមធម៌ មានគុណសម្បត្តិអាចប៉ះខ្ទប់អារម្មណ៍ដែលជារូប ឬជានាមក៏បាន ក្នុងខណៈដែលចិត្តដឹងអារម្មណ៍ ផស្សៈនេះ រមែងធ្វើនាទីប៉ះខ្ទប់ មិនថាអារម្មណ៍នោះ ជាអារម្មណ៍អ្វីឡើយ គឺ ជាលោកិយារម្មណ៍ក្តី លោកុត្តរារម្មណ៍ ( និព្វាន )ក្តី, ផស្សៈ ក៏ជាបច្ច័យសំខាន់ដល់សម្បយុត្តធម៌ទាំងនោះ ។

## ២_វេទនាចេតសិក

***វេទនា*** មានវិគ្រោះថា ***វេទិយតិ អាលម្ពនរសំ អនុភវតីតិ*** = ***វេទនា*** ដែលឈ្មោះថា ***វេទនា*** ព្រោះអត្ថថា រលឹកដឹងខ្លួន គឺ សោយរសនៃអារម្មណ៍, សម្បយុត្តធម៌

ក្រៅពីវេទនា សូម្បីមានការសោយរសនៃអារម្មណ៍ ក៏បានត្រឹមតែឯកទេសប៉ុណ្ណោះ តែវេទនានោះរមែងសោយរសអារម្មណ៍ដោយត្រង់ ព្រោះជាធំក្នុងការសោយ ។

<u>ក្នុងអដ្ឋសាលិនី</u> ប្រៀបវេទនា ដូចព្រះរាជាអ្នកសោយក្រយាហារ, ចំណែកចិត្ត និងចេតសិកដទៃ ៗ ដែលកើតរួមប្រៀបដូចចុងភៅដាំស្ងួអាហារថ្វាយព្រះរាជា មានសិទ្ធិអាចនឹងភ្លក់អាហារបានបន្តិចបន្តួចតាមសមគួរ មិនដូចព្រះរាជាមានសិទ្ធិបរិបូណ៌ក្នុងការសោយ ។

មួយទៀត កាលចែកដោយអារម្មណានុភវនលក្ខណន័យ ក៏បានវេទនា ៣ គឺ សុខវេទនា ១ ទុក្ខវេទនា ១ ឧបេក្ខាវេទនា ១ ។

ចែកដោយឥន្ទ្រិយ បានវេទនា ៥ គឺ សុខវេទនា ១ ទុក្ខវេទនា ១ សោមនស្សវេទនា ១ ទោមនស្សវេទនា ១ និងឧបេក្ខាវេទនា ១ ។

## លក្ខណាទិចតុក្កៈរបស់វេទនា

១-អនុភវនលក្ខណា មានការសោយអារម្មណ៍ ជាលក្ខណៈ

២-វិសយរសសម្ភោគរសា មានការបរិភោគរសអារម្មណ៍ ជាកិច្ច

៣-សុខទុក្ខបច្ចុប្បដ្ឋានា មានសុខនិងទុក្ខ ជាផល

៤-ផស្សបទដ្ឋានា មានផស្សៈ ជាហេតុជិត ។

## លក្ខណាទិចតុក្កៈរបស់សុខវេទនា

១-ឥដ្ឋផោដ្ឋព្វានុភវនលក្ខណា មានការសោយផោដ្ឋព្វៈគួរប្រាថ្នា ជាលក្ខណៈ

២-សម្បយុត្តានំ ព្រូហនរសា មានការធ្វើឱ្យសម្បយុត្តធម៌ចម្រើន ជាកិច្ច

៣-កាយិកអស្សាទបច្ចុប្បដ្ឋានា មានការត្រេកអរផ្លូវកាយជាផល

៤-កាយិន្ទ្រិយបទដ្ឋានា មានកាយប្រសាទ ជាហេតុជិត ។

## លក្ខណាទិចតុក្កៈរបស់ទុក្ខវេទនា

**១-អនិដ្ឋផោដ្ឋព្វានុភវនលក្ខណា** មានការសោយផោដ្ឋព្វៈមិនគួរប្រាថ្នា ជាលក្ខណៈ

**២-សម្បយុត្តានំ មិលាបនរសា** មានការធ្វើសម្បយុត្តធម៌ឱ្យសៅហ្មង ជាកិច្ច

**៣-កាយិកាពាធបច្ចុប្បដ្ឋានា** មានអាពាធផ្លូវកាយ ជាផល

**៤-កាយិន្ទ្រិយបទដ្ឋានា** មានកាយប្រសាទ ជាហេតុជិត ។

## លក្ខណាទិចតុក្កៈរបស់សោមនស្ស

**១-ឥដ្ឋារម្មណានុភវនលក្ខណា** មានការសោយអារម្មណ៍ដែលពេញចិត្ត ជាលក្ខណៈ

**២-ឥដ្ឋាការសម្ភោគរសា** មានការប្រសព្វនឹងអាការគួរប្រាថ្នា ជាកិច្ច

**៣-ចេតសិកអស្សាទបច្ចុប្បដ្ឋានា** មានការត្រេកអរផ្លូវចិត្តជាផល

៤-បស្សទ្ធិបទដ្ឋានា មានការស្ងប់កាយនិងចិត្ត ជាហេតុជិត ។

## លក្ខណាទិចតុក្កៈរបស់ទោមនស្ស

១-អនិដ្ឋារម្មណានុភវនលក្ខណា មានការសោយអារម្មណ៍មិនល្អ ជាលក្ខណៈ

២-អនិដ្ឋាការសម្ភោគរសា មានការប្រសព្វនឹងអាការមិនគួរប្រាថ្នា ជាកិច្ច

៣-ចេតសិកាពាធបច្ចុប្បដ្ឋានា មានអាពាធផ្លូវចិត្ត ជាផល

៤-ឯកន្តេនេវហទយវត្ថុបទដ្ឋានា មានហទយវត្ថុតែម្យ៉ាងប៉ុណ្ណោះ ជាហេតុជិត ។

## លក្ខណាទិចតុក្កៈរបស់ឧបេក្ខាវេទនា

១-មជ្ឈត្តវេទយិតលក្ខណា មានការសោយអារម្មណ៍ជាកណ្តាល ជាលក្ខណៈ

២-សម្បយុត្តានំ នាតិឧបព្រូហនមិលាបនរសា មានការរក្សាសម្បយុត្តធម៌មិនឱ្យចម្រើន និងមិនឱ្យសាបសូន្យ ជាកិច្ច

**៣-សន្តភាវបច្ចុប្បដ្ឋានា** មានការស្ងប់ ជាផល
**៤-និប្បីតិកចិត្តបទដ្ឋានា** មានចិត្តមិនប្រកបដោយបីតិ ជាហេតុជិត ។

## ឧបេក្ខា ១០ យ៉ាង

**១- ឧបេក្ខាណា** ជាធម៌បរិសុទ្ធជាប្រក្រតីក្នុងគន្លងនៃអារម្មណ៍ ៦ ដែលគួរប្រាថ្នា ឬមិនគួរប្រាថ្នាក៏ដោយ ក្នុងទ្វារ ៦របស់ព្រះខីណាស្រព តាមដែលពោលទុកក្នុងបាលីថា- **"ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ ច វិហរតិ សតោ សម្បជានោ :** ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែក ជាអ្នកមិនសោមនស្ស មិនទោមនស្ស មានស្មារតីដឹងខ្លួន មានចិត្តប្រកបដោយឧបេក្ខា "[១] ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា **ឆឡង្គុបេក្ខា** ។

**២- ឧបេក្ខាណា** មានអាការជាកណ្តាលក្នុងសត្វទាំង

---

១. ខុទ្ទ. បដិ. បញ្ញាវគ្គ. ៧១. ១៦១/២៨៣ ។

ឡាយ ដែលមានមកក្នុងបាលីថា- “**ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ** : ភិក្ខុមានចិត្តប្រកប ដោយឧបេក្ខាផ្សាយទៅកាន់ទិសទី១”[១] ដូច្នេះ, ឧបេក្ខានេះ ឈ្មោះថា **ព្រហ្មវិហារុបេក្ខា** ( ឧបេក្ខា ក្នុងព្រហ្មវិហារ ) ។

៣- **ឧបេក្ខា**ណា មានភាពជាកណ្តាលក្នុងសហជាត ធម៌ ដែលមកក្នុងបាលីថា- “**ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ** : ភិក្ខុចម្រើនឧបេក្ខាសម្ពោជ្ឈង្គៈដែលអាស្រ័យ វិវេកធម៌”[២] ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា **ពោជ្ឈង្គុបេក្ខា** ( ឧបេក្ខា ក្នុងសម្ពោជ្ឈង្គៈ ) ។

៤- **ឧបេក្ខា**ណា ពោលគឺ មានសេចក្តីព្យាយាម មិនធូរថយ និងមិនប្រឹងប្រែងខ្លាំងពេក ( មានភាពជា កណ្តាល ) នៃសេចក្តីព្យាយាម ដែលមានមកក្នុងបាលីថា

---

១. ទីឃ. សីល. តេវិជ្ជសូត្រ. ១៥. ១៨៦/២៧៥ ។

២. ទីឃ. បាជិ. សង្គីតិសូត្រ. ១៩. ១០៩/១៥៨ ។

**"កាលេន កាលំ ឧបេក្ខានិមិត្តំ មនសិករោតិ** : ភិក្ខុធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្តក្នុងកាលដ៏គួរ"[១] ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា **វីរិយុបេក្ខា** ( ឧបេក្ខា គឺ វីរិយៈ ) ។

**៥- ឧបេក្ខា**ណា មានអាការជាកណ្តាល ដែលកំណត់ពិចារណាធម៌ មាននីវរណៈជាដើម ដែលមានមកក្នុងបាលីថា **"កតិ សង្ខារុបេក្ខា សមថវសេន ឧប្បជ្ជន្តិ កតិ សង្ខារុបេក្ខា វិបស្សនាវសេន ឧប្បជ្ជន្តិ អដ្ឋ សង្ខារុបេក្ខា សមថវសេន ឧប្បជ្ជន្តិ ។ ទស សង្ខារុបេក្ខា វិបស្សនាវសេន ឧប្បជ្ជន្តិ** : សង្ខារុបេក្ខាប៉ុន្មាន កើតដោយអំណាចសមថ សង្ខារុបេក្ខាប៉ុន្មាន កើតដោយអំណាចវិបស្សនា, វិសជ្ជនាថា សង្ខារុបេក្ខា ៨ កើតដោយអំណាចសមថៈ សង្ខារុបេក្ខា ១០ កើតដោយអំណាចវិបស្សនា"[២] ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា

---

១ . អង្គុ. តិក. លោណផលវគ្គ. ៤១. ១០៤/៣៨៨ ។

២ . ខុទ្ទ. បដិ. មហាវគ្គ. ៦៩. ១៣៣/១៤៤ ។

***សង្ខារុបេក្ខា*** បានដល់ បញ្ញា ។

៦- ***ឧបេក្ខា***ណា ដែលកំណត់សំគាល់ ចាំក្នុងសេចក្តីមិនមែនទុក្ខ មិនមែនសុខ ដែលមានមកក្នុងបាលីថា "***យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ ឧបេក្ខាសហគតំ*** : ចិត្តជាកាមាវចរកុសល ប្រកបដោយឧបេក្ខា កើតមានឡើងក្នុងសម័យនោះ"[១] ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា ***វេទនុបេក្ខា*** ( ឧបេក្ខាវេទនា ) ។

៧- ***ឧបេក្ខា***ណា មានភាពជាកណ្តាលក្នុងការពិចារណា ដែលមានមកក្នុងបាលីថា "... ***យទត្ថិ យំ ភូតំ. តំ បជហតិ. ឧបេក្ខំ បដិលភតិ*** : ភិក្ខុរមែងបាននូវឧបេក្ខាថា ... ខន្ធបញ្ចកៈណា ដែលកើតមាន អញលះនូវខន្ធបញ្ចកៈនោះចេញ"[២] ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា ***វិបស្សនុបេក្ខា*** ( បញ្ញា ) ។

---

១. អភិ. សង្គ. មហាកុសល. ៧៨. ១៣០/៧០ ។

២. អង្គុ. សត្ត. អព្យាកតវគ្គ. ៤៧. ៥២/១២៩-១៣១ ។

៨- **ឧបេក្ខា**ណា ញុំាងសហជាតធម៌ឱ្យប្រព្រឹត្តទៅជានិច្ច ដែលមានមកក្នុង **យេវាបនកធម៌**[១] មានឆន្ទៈជាដើម ឧបេក្ខានេះ ឈ្មោះថា **តត្រមជ្ឈត្តុបេក្ខា** (តត្រមជ្ឈត្តតាចេតសិក) ។

៩- **ឧបេក្ខា**ណា ជាធម្មជាតិធ្លាក់ទៅក្នុងសេចក្តីសុខនៃឈាននោះ សូម្បីជាសុខដ៏ប្រសើរលើស ដែលមានមកក្នុងបាលីថា "**ឧបេក្ខកោ ច វិហរតិ** : ប្រកបដោយឧបេក្ខាផង"[២] ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា **ឈានុបេក្ខា** (តត្រមជ្ឈត្តតា) ។

**១០- ឧបេក្ខា**ណា បរិសុទ្ធចាកបច្ចនិកធម៌ មិនត្រូវខ្វល់ខ្វាយក្នុងការរម្ងាប់បច្ចនិកធម៌ទេ ដែលមានមកក្នុងបាលីថា "**អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ** : ចតុត្ថជ្ឈានមានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ គឺ ជា

---

១. អភិ. សង្គ. មហាកុសល. ៧៨. ១៦/១៧ ។

២. ទីឃ. សីល. ព្រហ្មជាលសូត្រ. ១៤. ៥០/៨៩ ។

ឧបេក្ខា មានសតិដ៏បរិសុទ្ធកើតអំពីឧបេក្ខា"[១] ដូច្នេះ ឧបេក្ខានេះ ឈ្មោះថា **បារិសុទ្ធិឧបេក្ខា** (តត្រមជ្ឈត្តតា) ។

បណ្ដាឧបេក្ខាទាំងនោះ ឧបេក្ខាទី១ គឺ ឆឡង្គុបេក្ខា, ទី២ ព្រហ្មវិហារុបេក្ខា, ទី៣ ពោជ្ឈង្គុបេក្ខា, ទី៨ តត្រមជ្ឈត្តុបេក្ខា, ទី៩ ឈានុបេក្ខា, ទី១០ បារិសុទ្ធិឧបេក្ខា, រួម ៦ នេះ ដោយអត្ថ គឺ ជាតត្រមជ្ឈត្តតាចេតសិក តែផ្សេងគ្នាដោយប្រភេទ, ប្រៀបដូចមនុស្សម្នាក់ គឺ ក្នុងវេលាជាក្មេង ជាមនុស្សកម្លោះ ជាមនុស្សចាស់ ជាសេនាបតី ជាព្រះរាជាជាដើម ។

ឧបេក្ខា ២ យ៉ាង គឺ ឧបេក្ខាទី ៥ សង្ខារុបេក្ខា និងទី ៧ វិបស្សនុបេក្ខា ជាបញ្ញាចេតសិក តែផ្សេងគ្នាដោយកិច្ច ក៏វិបស្សនុបេក្ខាជាបច្ច័យឱ្យសង្ខារុបេក្ខាកើតឡើង ។

ចំណែកឧបេក្ខាទី ៤ គឺ វីរិយុបេក្ខា បានដល់

---

១. ទីឃ. សីល. ១៤. ៥០/៩០ ។

សេចក្តីព្យាយាម ដែលប្រព្រឹត្តទៅជានិច្ចរឿយ ៗ ។

ឧបេក្ខាទី ៦ គឺ វេទនុបេក្ខា បានដល់ ឧបេក្ខាវេទនា ចេតសិក ។

## ៣-សញ្ញាចេតសិក

**សញ្ញា** មានវចនត្ថៈថា-

**នីលាទិភេទារម្មណំ សញ្ជានាតិ សញ្ញំ កត្វា ជានាតីតិ = សញ្ញា** ធម្មជាតិ ដែលឈ្មោះថា **សញ្ញា** ព្រោះអត្ថថា ចាំអារម្មណ៍ ដែលមានពណ៌ខៀវជាដើម គឺ ធ្វើគ្រឿងកំណត់សំគាល់ ។

### លក្ខណាទិចតុក្កៈរបស់សញ្ញា

**១-សញ្ជាននលក្ខណា** មានការចាំបាន ជាលក្ខណៈ

**២-បុនសញ្ជាននបច្ចយនិមិត្តករណរសា** មានការស្គាល់និងធ្វើគ្រឿងសំគាល់ទុក ជាកិច្ច ដូចជាងឈើធ្វើគ្រឿងសំគាល់ត្រង់ដើមឈើជាដើម

**៣-យថាគហិតនិមិត្តវសេន អភិនិវេសករណបច្ចុបដ្ឋានា** មាន
ការអាស្រ័យនិមិត្ត តាមដែលកំណត់ទុក ជាផល
**៤-យថាឧបដ្ឋិតវិសយបទដ្ឋានា** មានអារម្មណ៍ តាមដែល
ប្រាកដ ជាហេតុជិត ។

## ៤-ចេតនាចេតសិក

ចេតនាចេតសិក ជាធម្មជាតិផ្គងចិត្ត គឺ ចាត់ចែងជាស់តឿនសម្បយុត្តធម៌ ដែលកើតព្រមជាមួយនឹងខ្លួនឱ្យធ្វើកិច្ចរបស់ខ្លួន ៗ ។

**ចេតនា** មានវចនត្ថៈថា-

**ចេតេតិ អត្តនា សម្បយុត្តធម្មេ អារម្មណេ អភិសន្ទហតិ សន្ធិតាភិសន្ធរណេ វា ព្យាបារមាបជ្ជតីតិ** = **ចេតនា** ធម្មជាតិ ដែលឈ្មោះថា ចេតនា ព្រោះអត្ថថា តាំងចិត្ត គឺ ញុំាងសម្បយុត្តធម៌ ឱ្យព្រមព្រៀងជាមួយនឹងខ្លួនក្នុងអារម្មណ៍ ឬ ឈ្មោះថា **ចេតនា** ព្រោះអត្ថថា ដល់នូវសេចក្តីខ្វល់ខ្វាយក្នុងការតាក់តែងធម៌ដែលជាសន្ធិតៈ ។

ពិតមែន ព្រះមានព្រះភាគ កាលទ្រង់ចែកសង្ខារក្ខន្ធ ត្រាស់ថា ចេតនា ឈ្មោះថា សង្ខារ ព្រោះអត្ថថា តាក់តែង ធម៌ដែលជាសង្ខតៈ ដូចព្រះបាលី ក្នុងវិភង្គប្បករណ៍ថា "**ចក្ខុសម្ផស្សជា ចេតនា** : ចេតនាកើតអំពីចក្ខុសម្ផស្ស"[១] ជាដើម ។ "**អភិសង្ខរណោ បមានត្ថា** : ព្រោះជាប្រមាន ក្នុងការតាក់តែង" ។

## លក្ខណាទិចតុក្កៈរបស់ចេតនា

**១-ចេតនាភាវលក្ខណា** ចេតនាមានការផ្ដួងចិត្ត ជាលក្ខណៈ

**២-អាយូហនរសា** មានការតាំងចិត្តប្រមូលមក ជាកិច្ច

**៣-សំវិធានបច្ចុប្បដ្ឋានា** មានការចាត់ចែង ជាផល ដូចជាងឈើធ្វើកិច្ចឱ្យសម្រេច

**៤-សេសខន្ធត្តយបទដ្ឋានា** មានខន្ធ ៣ ដែលនៅសល់ (វេទនា សញ្ញា វិញ្ញាណ) ជាហេតុជិត ។

---

១. អភិ. វិភ. ខន្ធវិភង្គ. ៨០. ២១/១៤ ។

## ៥_ឯកគ្គតាចេតសិក

**ឯកគ្គតាចេតសិក** ជាធម្មជាតិស្ងប់និងធ្វើឱ្យសម្បយុត្តធម៌ តាំងនៅក្នុងអារម្មណ៍មួយជាមួយគ្នា ។

**ឯកគ្គតា** មានវចនត្ថៈថា **នានាលម្ពនវិក្ខេបាភាវេន ឯកំ អារម្មណំ អគ្គំ ឥមិស្សាតិ ឯកគ្គំ ចិត្តំ តស្ស ភាវោ** = **ឯកគ្គតា** ចិត្តដែលឈ្មោះថា ឯកគ្គៈ ដោយអត្ថថា មានអារម្មណ៍មួយ ព្រោះមិនមានសេចក្តីរវើរវាយ ទៅក្នុងអារម្មណ៍ផ្សេង ៗ, ភាវៈនៃចិត្តមានអារម្មណ៍មួយនោះ ឈ្មោះថា **ឯកគ្គតា** ។

### លក្ខណាទិចតុក្កៈរបស់ឯកគ្គតា

**១-អវិក្ខេបលក្ខណា** មានការមិនរវើរវាយ ជាលក្ខណៈ

**២-សហជាតានំ សម្បិណ្ឌនរសា** មានការប្រមូលសហជាតធម៌មក ជាកិច្ច

**៣-ឧបសមបច្ចុប្បដ្ឋានា** មានការចូលទៅស្ងប់ ជាផល

**៤-សុខបទដ្ឋានា** មានសុខវេទនា ជាហេតុជិត ។

## ៦_ជីវិតិន្ទ្រិយចេតសិក

ជីវិតិន្ទ្រិយចេតសិក ជាធម៌រក្សាសម្បយុត្តធម៌ គឺឱ្យសម្បយុត្តធម៌ តាំងនៅនិងប្រព្រឹត្តទៅ, ធម៌ ឈ្មោះថាឥន្ទ្រិយ ព្រោះភាពជាធំ ក្នុងការរក្សាធម៌ ដែលកើតរួមគ្នា ។

**ជីវិតិន្ទ្រិយ** មានវចនត្ថៈថា-

**ជីវន្តិ តេន សម្បយុត្តធម្មាតិ ជីវិតំ. តទេវ សហជាតានុបាលនេ អធិបច្ចយោគេន ឥន្ទ្រិយន្តិ = ជីវិតិន្ទ្រិយំ** ឈ្មោះថា **ជីវិត** ព្រោះអត្ថថា ជាគ្រឿងតាំងនៅនៃសម្បយុត្តធម៌, ក៏ជីវិតនោះឯង ជាធំក្នុងការរក្សាសហជាតធម៌ដោយគួរដល់សេចក្តីជាធំ ព្រោះដូច្នោះ ទើបឈ្មោះថា **ជីវិតិន្ទ្រិយ** ។

### លក្ខណាទិចតុក្កៈរបស់ជីវិតិន្ទ្រិយ

**១-សហជាតានំ អនុបាលនលក្ខណំ** មានការតាមរក្សាសហជាតធម៌ ជាលក្ខណៈ ប្រៀបដូចទឹកស្អិតរក្សាផ្កាឈូកជាដើម ។

***២-តេសំ បវត្តនរសំ*** *មានការញ៉ាំងសម្បយុត្តធម៌ ឱ្យប្រព្រឹត្តទៅ ជាកិច្ច*

***៣-តេសញ្ញេវ ឋបនបច្ចុប្បដ្ឋានំ*** *មានការតាំងនៅនៃសហជាតធម៌ ជាផល*

***៤-សេសខន្ធត្តយបទដ្ឋានំ*** *មានខន្ធ ៣ ដែលនៅសល់ ជាហេតុជិត ។*

## ៧-មនសិការចេតសិក

***មនសិការចេតសិក*** *ជាធម្មជាតិនាំសម្បយុត្តធម៌ មកកាន់អារម្មណ៍ ។*

***មនសិការ*** *មានវចនត្ថៈថា* ***ករណំ ការោ មនស្មឹ ការោ = មនសិការោ*** *ការធ្វើ ឈ្មោះថា ការៈ, ការធ្វើទុកក្នុងចិត្ត ឈ្មោះថា មនសិការៈ ។*

## លក្ខណាទិចតុក្កៈរបស់មនសិការៈ

**១-សារណលក្ខណោ** មានការឱ្យសម្បយុត្តធម៌ត្រាច់ទៅ ជាលក្ខណៈ

**២-សម្បយុត្តានំ អារម្មណេ សំយោជនរសោ** មានការញុំាងសម្បយុត្តធម៌ ឱ្យប្រកបក្នុងអារម្មណ៍ ជាកិច្ច

**៣-អារម្មណាភិមុខីភាវបច្ចុប្បដ្ឋានោ** មានការបែរមុខ( ប្រាថ្នា ) ចំពោះអារម្មណ៍ ជាផល ដូចនាយសារថី នាំសេះឱ្យទៅកាន់ទិសដែលត្រូវការ

**៤-អារម្មណបទដ្ឋានោ** មានអារម្មណ៍ ជាហេតុជិត ។

## មនសិការៈ ៣ យ៉ាង គឺ -

**១-វិថីបដិបាទកមនសិការោ** មនសិការៈដែលធ្វើឱ្យវិថីចិត្តកើត គឺ បញ្ចទ្វារាវជ្ជនចិត្ត[១] ជាអនន្តរប្បច្ច័យ ឱ្យចក្ខុវិញ្ញាណ

---

១. <u>**ចំណាំ**</u> អហេតុកកិរិយាចិត្តទាំង៣ សរសេរតាមកិច្ច( ក្នុងអដ្ឋកថា ដីកាក៏មាន ) ដើម្បីសម្រួលពាក្យឱ្យខ្លី ។

ជាដើមកើត ។

**២-ជវនបដិបាទកមនសិការ** មនសិការៈដែលធ្វើឱ្យជវនចិត្តកើត គឺ មនោទ្វារាវជ្ជនចិត្ត ជាអនន្តរប្បច្ច័យឱ្យជវនចិត្តកើត ។[១]

**៣-អារម្មណបដិបាទកមនសិការ** មនសិការចេតសិក ធ្វើឱ្យអារម្មណ៍ប្រាកដ បើអត់មនសិការចេតសិក អារម្មណ៍រមែងមិនប្រាកដ ។

## ចេតនា និងមនសិការចេតសិក

ចេតសិកទាំង ២ នេះ មានសភាពស្រដៀងគ្នា តែមិនដូចគ្នា គឺ ចេតនា មាននាទីតាក់តែងដាស់តឿនសម្បយុត្តធម៌ដែលកើតព្រមនឹងខ្លួន ឱ្យធ្វើកិច្ចរបស់ខ្លួន ៗ,

ចំណែកមនសិការចេតសិក មាននាទីប្រាថ្នានាំ

---

១. ច្បាប់ខ្លះថា ទី១-២ បានដល់យោនិសោមនសិការ ឬអយោនិសោមនសិការ ។

សម្បយុត្តធម៌ដែលកើតព្រមនឹងខ្លួនឱ្យប្រព្រឹត្តទៅ ។

ចេតសិកទាំង ៧ នេះ ប្រកបជាមួយនឹងចិត្តទាំងអស់ ព្រោះសភាពរបស់ចិត្តនោះ កើតឡើងដើម្បីដឹងអារម្មណ៍, ការដែលនឹងដឹងអារម្មណ៍បានព្រោះ ៖

- **ផស្សៈ** ធ្វើកិច្ចប៉ះខ្ទប់អារម្មណ៍,
- **វេទនា** ជាសភាពសោយអារម្មណ៍,
- **សញ្ញា** ធ្វើកិច្ចចាំអារម្មណ៍,
- **ចេតនា** ធ្វើកិច្ចខ្វល់ខ្វាយឱ្យសម្រេច,
- **ឯកគ្គតា** ដែលមានអារម្មណ៍តែមួយ ធ្វើសម្បយុត្តធម៌ដែលកើតព្រមគ្នាឱ្យតាំងនៅក្នុងអារម្មណ៍នោះ,
- **ជីវិតិន្ទ្រិយ** ជាសភាពរក្សាសម្បយុត្តធម៌ឱ្យប្រព្រឹត្តទៅ
- **មនសិការៈ** គឺ ការធ្វើអារម្មណ៍ទុកក្នុងចិត្ត,

* បើចេតសិកទាំង ៧ នេះ មិនកើតទេ ចិត្តក៏កើតមិនបានដែរ ដូច្នោះ ចេតសិកទាំង ៧ នេះ ទើបជាសព្វចិត្ត

សាធារណចេតសិក ។

## ចែកសព្វចិត្តសាធារណចេតសិក ដោយន័យផ្សេង ៗ

**១-ដោយខន្ធ** វេទនាចេតសិក ជាវេទនាខន្ធ សញ្ញាចេតសិក ជាសញ្ញាខន្ធចេតសិក ៥ ទៀត ជាសង្ខារក្ខន្ធ ។

**២-ដោយជាតិ** ចេតសិក៦ (វៀរវេទនា) ជាជាតិ ទាំង ៤, សុខ ទុក្ខ ជាវិបាកជាតិ, ទោមនស្ស ជាអកុសលជាតិ, សោមនស្ស ឧបេក្ខា ជាជាតិទាំង ៤,

**៣-ដោយទ្វារ** ចេតសិក ៦ (វៀរវេទនា) កើតបាន ៦ ទ្វារ និងទ្វារវិមុត្ត, សុខ ទុក្ខ កើតផ្លូវកាយទ្វារ, ទោមនស្ស កើតបាន ៦ ទ្វារ, សោមនស្ស ឧបេក្ខា កើត ៦ ទ្វារ និងទ្វារវិមុត្ត

**៤-ដោយអារម្មណ៍** ចេតសិក ៦ (វៀរវេទនា) ដឹងអារម្មណ៍បាន ៦, សុខ ទុក្ខ ដឹងផោដ្ឋព្វារម្មណ៍, ទោមនស្ស ដឹងអារម្មណ៍បាន ៦, សោមនស្ស, ឧបេក្ខា ដឹងអារម្មណ៍បាន ៦ (គ្រប់ទាំងអស់)

**៥-ដោយភូមិ** ចេតសិក ៦ (វៀរវេទនា)ជាភូមិទាំង ៤ (កើតក្នុងភូមិ៣០) សុខ ទុក្ខ ទោមនស្ស ជាកាមភូមិ (កើតក្នុងកាមភូមិ ១១), សោមនស្ស ជាកាមភូមិ រូបភូមិ លោកុត្តរភូមិ (កើតក្នុងភូមិ៣០) ឧបេក្ខា ជាភូមិទាំង ៤ (កើតក្នុងភូមិ៣០ វៀរអសញ្ញីភូមិ)

**៦-ដោយវត្ថុ** ចេតសិក ៦ (វៀរវេទនា) កើតបានទាំង ៦ វត្ថុ; សុខ ទុក្ខ កើតត្រង់កាយវត្ថុ; ទោមនស្ស សោមនស្ស កើតត្រង់ហទយវត្ថុ; ឧបេក្ខា កើតបាន ៥ វត្ថុ (វៀរកាយវត្ថុ)

**៧-ដោយហេតុ** ចេតសិក ៧ ជានហេតុ

**៨-ដោយសោភណ** ចេតសិក ៧ ជាសោភណក៏មាន អសោភណក៏មាន

**៩-ដោយលោក** ចេតសិក ៧ ជាលោកិយក៏មាន លោកុត្តរក៏មាន ។

## បកិណ្ណកចេតសិក៦

## ១-វិតក្កចេតសិក

***វិតក្ក*** *មានវចនត្ថៈថា-*

***អារម្មណំ វិតក្កេតិ សម្បយុត្តធម្មេ អភិនិរោបេតីតិ*** = ***វិតក្កោ*** *ធម៌ណា រមែងត្រិះរិះ( ទឹក )ដល់អារម្មណ៍ គឺ លើក សម្បយុត្តធម៌ឡើងកាន់អារម្មណ៍ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា* ***វិតក្កៈ*** ។

### *លក្ខណាទិចតុក្កៈរបស់វិតក្កៈ*

***១-អារម្មណេ ចិត្តស្ស អភិនិរោបនលក្ខណោ*** *មានការលើកចិត្តឡើងកាន់អារម្មណ៍ ជាលក្ខណៈ*

***២-អាហននបរិយាហននរសោ*** *មានការធ្វើចិត្តឱ្យប៉ះខ្ទប់អារម្មណ៍រឿយ ៗ ជាកិច្ច*

***៣-អានយបច្ចុប្បដ្ឋានោ*** *មានការនាំចិត្តមកក្នុងអារម្មណ៍ ជាផល*

***៤-អាបាថវិសយបទដ្ឋានោ*** *មានអារម្មណ៍ក្នុងវិថី ជាហេតុជិត* ។

## ២-វិចារចេតសិក

***វិចារ*** *មានវចនត្ថៈថា ៖*

***អារម្មណេ តេន ចរន្តិ ចិត្តំ វិចារតីតិ = វិចារោ*** *ចិត្តរមែងត្រាច់ទៅក្នុងអារម្មណ៍ ដោយធម៌នោះ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា* ***វិចារៈ ។***

### *លក្ខណាទិចតុក្កៈរបស់វិចារៈ*

***១-អារម្មណានុមជ្ជនលក្ខណោ*** *មានការពិចារណាក្នុងអារម្មណ៍ ជាលក្ខណៈ*

***២-តត្ថ សហជាតានុយោជនរសោ*** *មានការតាមប្រកបសហជាតធម៌ទុកក្នុងអារម្មណ៍ ជាកិច្ច*

***៣-ចិត្តានុបពន្ធបច្ចុប្បដ្ឋានោ*** *មានការចងចិត្តទុកក្នុងអារម្មណ៍ ជាផល*

***៤-អារម្មណបទដ្ឋានោ*** *មានអារម្មណ៍ ជាហេតុជិត ។*

## ៣-អធិមោក្ខចេតសិក

**អធិមោក្ខ** មានវចនត្ថៈថា ៖

**អធិមុច្ចនំ** = **អធិមោក្ខោ** ការបង្អោនចិត្តទៅ ឈ្មោះថា **អធិមោក្ខៈ**

### លក្ខណាទិចតុក្កៈរបស់អធិមោក្ខៈ

**១-សន្និដ្ឋានលក្ខណោ** មានការយល់ជាក់ ដាក់ចិត្តស៊ប់ ( សន្និដ្ឋាន ) ជាលក្ខណៈ គប្បីឃើញដូចសសរខឿន ព្រោះមិនញាប់ញ័រក្នុងអារម្មណ៍

**២-អសំសប្បនរសោ** មានការមិនសង្ស័យ ជាកិច្ច

**៣-វិនិច្ឆយបច្ចុប្បដ្ឋានោ** មានការចុះចិត្តស៊ប់ ជាផល

**៤-សន្និដ្ឋេយ្យធម្មបទដ្ឋានោ** មានធម៌ដែលគប្បីយល់ឃើញស៊ប់ ជាហេតុជិត ។

អធិមោក្ខៈ នេះ ជាបដិបក្ខចំពោះវិចិកិច្ឆា ។

## ៤-វីរិយចេតសិក

**វីរិយ** មានវចនត្ថៈថា **វីរានំ ភាវោ កម្មំ វា វិធិនា ឥរយិតព្វំ បវត្តេតព្វន្តិ វា = វីរិយំ ឧស្សាហោ** ភាវៈឬការងាររបស់អ្នកក្លាហាន ឈ្មោះថា វីរិយៈ, មួយទៀត ធម្មជាតណា ដែលបុគ្គលគប្បីឱ្យដំណើរទៅ គប្បីឱ្យប្រព្រឹត្តទៅដោយវិធី( ការទ្រទ្រង់ទុកវិសេស ) ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា វីរិយៈ បានដល់ សេចក្តីព្យាយាម ។

### លក្ខណាទិចតុក្កៈរបស់វីរិយៈ

**១-ឧស្សាហនលក្ខណំ** មានការឧស្សាហ៍ ជាលក្ខណៈ

**២-សហជាតានំ ឧបត្ថម្ភនរសំ** មានការឧបត្ថម្ភដល់សហជាតធម៌ ជាកិច្ច

**៣-អសំសីទនភាវបច្ចុប្បដ្ឋានំ** មិនមានការរាថយ ជាផល

**៤-សំវេគវត្ថុបទដ្ឋានំ** មានសំវេគវត្ថុ ជាហេតុជិត ។

## សំវេគវត្ថុ ៨

ហេតុជាទីតាំងនៃសេចក្តីសង្វេគ ហៅថា **សំវេគវត្ថុ** មាន ៨ គឺ ការពិចារណាដល់ជាតិទុក្ខ ១ ....ជរាទុក្ខ ១ ....ព្យាធិទុក្ខ ១ ....មរណទុក្ខ ១ ....អបាយិកទុក្ខ ១ ....អតីតវដ្តមូលកទុក្ខ ១ ...អនាគតវដ្តមូលកទុក្ខ ១ និងការពិចារណាដល់ទុក្ខ ក្នុងការស្វែងរកអាហារក្នុងបច្ចុប្បន្ន ១ ។

## ៥_បីតិចេតសិក

**បីតិ** មានវចនត្ថៈថា **បីនយតិ កាយចិត្តំ តប្បេតិ វឌ្ឍេតីតិ វា = បីតិ** ធម្មជាតិ ដែលឈ្មោះថា បីតិ ព្រោះអត្ថថា ញុំាងកាយ និងចិត្ត ឱ្យឆ្អែត ឱ្យស្រើមជោក ឬញុំាងកាយនិងចិត្តឱ្យចម្រើន ។

### លក្ខណាទិចតុក្កៈរបស់បីតិ

**១-សម្បិយាយនលក្ខណា** មានការឆ្អែត ជាលក្ខណៈ

**២-កាយចិត្តសម្បីណនរសា** មានការធ្វើកាយនិងចិត្តឱ្យឆ្អែត

ជាកិច្ច

**៣-ឧទគ្យបច្ចុប្បដ្ឋានា** មានការរីកសាយ ជាផល

**៤-សេសខន្ធត្តយបទដ្ឋានា** មានទាមខន្ធ ៣ ដែលនៅសស់ ជាហេតុជិត ។

## **បីតិ ៥ យ៉ាង**

**១, ខុទ្ទកាបីតិ** សេចក្ដីត្រេកអរតិច ត្រឹមព្រឺរោម ព្រឺស្បែក

**២, ខណិកាបីតិ** សេចក្ដីត្រេកអរមួយខណៈ ៗ ប្រាកដ ដូចជាផ្លេកបន្ទោរ

**៣, ឱក្កន្តកាបីតិ** សេចក្ដីត្រេកអររឿយ ៗ មានអាការ ប្រាកដ ដូចជាទឹករលកបោកខ្ទប់មកត្រូវ

**៤, ឧព្វេង្គាបីតិ** សេចក្ដីត្រេកអរខ្លាំង អាចញុំាំងកាយឱ្យ អណ្ដែតឡើង

**៥, ផរណាបីតិ** សេចក្ដីត្រេកអរធ្វើឱ្យផ្សព្វផ្សាយជ្រួត ជ្រាបទូទៅក្នុងកាយ ។

## ៦_ឆន្ទចេតសិក

**ឆន្ទ** មានវចនត្ថៈថា **ឆន្ទនំ** = **ឆន្ទោ** សេចក្តីពេញចិត្ត ឈ្មោះថា **ឆន្ទៈ**

ក៏ឆន្ទៈនេះ មានការប្រាថ្នារូបារម្មណ៍ជាដើម ។

### លក្ខណាទិចតុក្កៈរបស់ឆន្ទៈ

**១_កត្តុកម្យតាលក្ខណោ** មានការប្រាថ្នាដើម្បីធ្វើ ជាលក្ខណៈ
**២_អារម្មណបរិយេសនរសោ** មានការស្វែងរកអារម្មណ៍ ជាកិច្ច
**៣_អត្ថិកតាបច្ចុប្បដ្ឋានោ** មានសេចក្តីត្រូវការអារម្មណ៍ ជាផល
**៤_អារម្មណបទដ្ឋានោ** មានអារម្មណ៍ ជាហេតុជិត ។

បកិណ្ណកចេតសិកទាំង ៦ នេះ ជាសង្ខារក្ខន្ធទាំងអស់ មិនចាំបាច់ចែកដោយន័យផ្សេង ៗទេ ព្រោះប្រកបជាមួយ នឹងចិត្តយ៉ាងណា ចេតសិកទាំង ៦ នោះ ក៏ជាយ៉ាងនោះ ។

## សម្តែងអញ្ញសមានាចេតសិក ១៣

អញ្ញសមានាចេតសិក ១៣

- សព្វចិត្តសាមារណចេតសិក ៧
  - ផស្សចេតសិក ១
  - វេទនាចេតសិក ១
  - សញ្ញាចេតសិក ១
  - ចេតនាចេតសិក ១
  - ឯកគ្គតាចេតសិក ១
  - ជីវិតិន្ទ្រិយចេតសិក ១
  - មនសិការចេតសិក ១
- បកិណ្ណកចេតសិក ៦
  - វិតក្កចេតសិក ១
  - វិចារចេតសិក ១
  - អធិមោក្ខចេតសិក ១
  - វីរិយចេតសិក ១
  - បីតិចេតសិក ១
  - ឆន្ទចេតសិក ១

ចប់ អញ្ញសមានាចេតសិក

## អធិប្បាយ អកុសលចេតសិក ១៤

អកុសលចេតសិកទាំង ១៤ នេះ ជាចេតសិកផ្នែកអាក្រក់ ជាបាប, កាលប្រកបជាមួយនឹងចិត្ត រមែងធ្វើឱ្យចិត្តសៅហ្មងឱ្យក្តៅក្រហាយ, អកុសលចេតសិកទាំង ១៤ នេះ ប្រកបបានចំពោះចិត្តជាអកុសល ១២ មិនប្រកបជាមួយអហេតុកចិត្ត ១៨ និងសោភណចិត្តទាំង ៥៩ ឬ៩១ ទេ ។

### អកុសលចេតសិក ១៤ មាន ៥ ន័យ

**១-មោចតុក្កៈ** បានដល់ ចេតសិក ៤ គឺ មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ

**២-លោតិកៈ** បានដល់ ចេតសិក ៣ គឺ លោភៈ ទិដ្ឋិ មានះ

**៣-ទោចតុក្កៈ** បានដល់ ចេតសិក ៤ គឺ ទោសៈ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ

**៤-ថីទុកៈ** បានដល់ ចេតសិក ២ គឺ ថីនៈ មិទ្ធៈ

**៥-ឯកវិចិកិច្ឆា** បានដល់ ចេតសិក ១ គឺ វិចិកិច្ឆា

មោចតុក្កចេតសិក ៤ តាមដែលពោលនេះ ប្រកបជាមួយអកុសលចិត្ត បានទាំង ១២ ដូច្នោះ មោចតុក្កចេតសិកទើបឈ្មោះថា **សព្វាកុសលសាមារណចេតសិក ។**

## ១_មោហចេតសិក

**មោហ** មានវចនត្ថៈថា **អារម្មណេ មុយ្ហតីតិ = មោហោ អញ្ញាណំ** ធម៌ ដែលឈ្មោះថា **មោហៈ** ព្រោះអត្ថថា វង្វេងក្នុងអារម្មណ៍ បានដល់ អញ្ញាណ ។

**លក្ខណាទិចតុក្កៈរបស់មោហៈ**

**១_អញ្ញាណលក្ខណោ** មានការមិនដឹង(សភាវធម៌) តាមសេចក្ដីពិត ជាលក្ខណៈ

**២_អារម្មណសភាវច្ឆាទនរសោ** មានការបិទបាំងសភាវៈនៃអារម្មណ៍ ជាកិច្ច

**៣_អន្ធការបច្ចុប្បដ្ឋានោ** មានទូវភាពងងឹត ជាផល

**៤-អយោនិសោមនសិការបទដ្ឋានោ** មានអយោនិសោមនសិការៈ ជាហេតុជិត ។

**មោហៈ** គឺ អវិជ្ជា បានដល់ ការមិនដឹងតាមសេចក្តីពិត

ក្នុងទីនេះ លោកសម្តែងដល់សេចក្តីមិនដឹងក្នុងធម៌ ៨ យ៉ាង គឺ

**១-ទុក្ខេ អញ្ញាណំ** សេចក្តីមិនដឹងក្នុងទុក្ខសច្ចៈ

**២-ទុក្ខសមុទយេ អញ្ញាណំ** សេចក្តីមិនដឹងក្នុងទុក្ខសមុទយសច្ចៈ

**៣-ទុក្ខនិរោធេ អញ្ញាណំ** សេចក្តីមិនដឹងក្នុងទុក្ខនិរោធសច្ចៈ

**៤-ទុក្ខនិរោធគាមិនីបដិបទាយ អញ្ញាណំ** សេចក្តីមិនដឹងក្នុងមគ្គសច្ចៈ ( ដែលជាផ្លូវនាំឱ្យដល់ទីរំលត់ទុក្ខ ១២ កង )

**៥-បុព្វន្តេ អញ្ញាណំ** សេចក្តីមិនដឹងក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអតីត

**៦-អបរន្តេ អញ្ញាណំ** សេចក្តីមិនដឹងក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអនាគត

***៧-បុព្វន្តាបរន្តេ អញ្ញាណំ*** *សេចក្តីមិនដឹងក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអតីត និងអនាគត*

***៨-ឥទប្បច្ចយតា បដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ*** *សេចក្តីមិនដឹងក្នុងបដិច្ចសមុប្បាទ គឺ មិនដឹងក្នុងធម៌ទាំងឡាយ ដែលអាស្រ័យគ្នាកើតឡើងថា "ធម៌នេះជាបច្ច័យ" ។*

## ២-អហិរិកចេតសិក

***អហិរិក*** *មានវចនត្ថៈថា* ***ន ហិរិយតិ ន លជ្ជិយតីតិ = អហិរិកោ បុគ្គលោ ធម្មសមូហោ វា*** *: បុគ្គលឬប្រជុំនៃធម៌ ឈ្មោះថា* ***អហិរិកៈ*** *ព្រោះអត្ថថា មិនខ្មាស គឺ មិនរង្កៀសចំពោះបាប ។*

### *លក្ខណាទិចតុក្កៈរបស់អហិរិកៈ*

***១-កាយទុច្ចរិតាទីហិ អជិគុច្ឆនលក្ខណំ អលជ្ជនលក្ខណំ វា*** *មានការមិនរង្កៀស ឬមិនខ្មាសទុច្ចរិត មានកាយទុច្ចរិតជាដើម ជាលក្ខណៈ*

**២-បាបានំ ករណរសំ** មានការធ្វើបាប ជាកិច្ច
**៣-អសង្កោចនបច្ចុប្បដ្ឋានំ** មានការមិនថយចាកបាប ជាផល
**៤-អត្តនិ អគារវបទដ្ឋានំ** មានការមិនគោរពខ្លួន គឺ មិនខ្មាសដល់ចិត្តខ្លួនឯង ជាហេតុជិត ។

## ៣-អនោត្តប្បចេតសិក

**អនោត្តប្ប** មានវិគ្រោះថា **ន ឱត្តប្បតីតិ = អនោត្តប្បំ** ឈ្មោះថា **អនោត្តប្បៈ** ព្រោះអត្ថថា មិនតក់ស្លុតចំពោះបាប ។

### លក្ខណាទិចតុក្កៈរបស់អនោត្តប្បៈ

**១-អនុត្តាសលក្ខណំ** មានការមិនតក់ស្លុត ជាលក្ខណៈ
**២-បាបានំ ករណរសំ** មានការធ្វើបាប ជាកិច្ច
**៣-អសង្កោចនបច្ចុប្បដ្ឋានំ** មានការមិនថយចាកបាប ជាផល
**៤-បរាគារវបទដ្ឋានំ** មានការមិនគោរពអ្នកដទៃ ជាហេតុជិត ។

**អហិរិកៈ** មានការមិនខ្ពើមកាយទុច្ចរិតជាដើម ដូចជ្រូកមិនខ្ពើមលាមក ចំណែកអនោត្តប្បៈ មានការមិនក្រែង

ខ្វាចចំពោះកាយទុច្ចរិតជាដើម ដូចសត្វមមាចមិនខ្លាចភ្លើង ។

## ៤-ឧទ្ធច្ចចេតសិក

**ឧទ្ធច្ច** មានវចនត្ថៈថា ៖

**ឧទ្ធតស្ស ភាវោ = ឧទ្ធច្ចំ** ភាវៈនៃចិត្តដែលរវើរវាយទៅ ( មិនស្ងប់ ) ឈ្មោះថា **ឧទ្ធច្ចៈ** ។

### លក្ខណាទិចតុក្កៈរបស់ឧទ្ធច្ចៈ

**១-អវូបសមនលក្ខណំ** មានការមិនចូលទៅស្ងប់ ជាលក្ខណៈ ដូចទឹករញ្ជួយ ព្រោះខ្យល់បក់ ឬផេះហុយព្រោះត្រូវគេវែងដោយថ្ម

**២-អនវដ្ឋានរសំ** មានការមិនតាំងមាំ ជាកិច្ច ដូចទង់បក់ព្រោះខ្យល់

**៣-ភន្តត្តបច្ចុប្បដ្ឋានំ** មានការវិលវក់ទៅក្នុងអារម្មណ៍ ជាផល

**៤-អយោនិសោមនសិការបទដ្ឋានំ** មានអយោនិសោមនសិការៈ ជាហេតុជិត ។

## ៥_លោភចេតសិក

**លោភ** មានវចនត្ថៈថា **លុព្ភតីតិ** = **លោភោ** ឈ្មោះថា លោភៈ ព្រោះអត្ថថា ចង់បាន ។ លោភនេះ កើតជាមួយនឹង លោភមូលចិត្ត ៨ ។

### លក្ខណាទិចតុក្កៈរបស់លោភៈ

**១_អារម្មណគ្គហណលក្ខណោ** មានការកាន់យកអារម្មណ៍ ជាលក្ខណៈ ដូចស្វាជាប់ជ័រ[១]

**២_អភិសំគរសោ** មានការទាក់ជាប់ក្នុងអារម្មណ៍ ជាកិច្ច ដូចដុំសាច់ដែលដាក់ក្នុងខ្ទះក្ដៅ (ដែលអត់ខ្លាញ់)

**៣_អបរិច្ចាគបច្ចុប្បដ្ឋានោ** មានការមិនលះបង់ ជាផល ដូចសំពត់ប្រឡាក់ប្រេង

**៤_សញ្ញោជនីយធម្មេសុ អស្សាទទស្សនបទដ្ឋានោ** មានការ

---

១. សំយុ. មហា. អដ្ឋបាលិវគ្គ. ៣៨. ២៤/១៩ មានសម្ដែងអំពីស្វាជាប់ជ័រ ។

មើលវត្ថុដែលពេញ ចិត្តជាដើមក្នុងធម៌ដែលជាអារម្មណ៍ របស់សញ្ញោជនៈ ជាហេតុជិត ។

<u>**ក្នុងបរមត្ថទីបនី**</u> ពោលបរិយាយ( វេវចន ) នៃលោភៈ ទុក ១០ យ៉ាង គឺ **១-តណ្ហា** សេចក្តីចង់ **២-រាគៈ** តម្រេក, **៣-កាមៈ** សេចក្តីប្រាថ្នា, **៤-នន្ទិ** សេចក្តីរីករាយ, **៥-អភិជ្ឈា** ការសំឡឹងរំពៃ, **៦-ជនេត្តី** មេអ្នកឱ្យកើត, **៧-បោនោព្ភវិកា** អ្នកឱ្យកើតក្នុងភពថ្មី, **៨-ឥច្ឆា** សេចក្តីប្រាថ្នា, **៩-អាសា** ការប៉ុនប៉ង, **១០-សញ្ញោជនៈ** គ្រឿងចង ។

<u>**ក្នុងអភិធម្មសង្គណី**</u> មានពាក្យលោភៈ ១០២ គឺ

**រាគោ** តម្រេក, **សារាគោ** ការត្រេកអរខ្លាំង, **អនុនយោ** ការជាប់ជំពាក់ក្នុងអារម្មណ៍, **អនុរោធោ** ការស្រើបស្រាល, **នន្ទី** ការរីករាយ, **នន្ទីរាគោ** ការរីករាយខ្លាំង, **ចិត្តស្ស សារាគោ** តម្រេកខ្លាំងនៃចិត្ត, **ឥច្ឆា** សេចក្តីប្រាថ្នា, **មុច្ឆា** ការជ្រុលជ្រប់, **អជ្ឈោសានំ** ការងល់ងប់, **គេធោ** ការ

ពាក់ព័ន្ធ, **បលិគេមោ** ការរួបរឹត, **សង្គោ** ការជាប់ជំពាក់, **បង្កោ** ការលិចចុះ, **ឯជា** ធម្មជាតិនាំសត្វឱ្យកើតក្នុងភព, **មាយា** មាយា, **ជនិកា** ធម្មជាតិបង្កើតសត្វ, **សញ្ជននី** ធម្មជាតិឱ្យសត្វប្រកបដោយទុក្ខ, **សិព្វិនី** ធម្មជាតិចាក់ស្រេះសត្វទុក, **ជាលិនី** បណ្ដាញ, **សរិតា** ការបង្ហូរ, **វិសត្តិកា** ការផ្សាយទៅកាន់អារម្មណ៍ផ្សេង ៗ, **សុត្តំ** ចំណងចងសត្វទុក, **វិសដា** ការផ្សាយទៅក្នុងអារម្មណ៍, **អាយូហិនី** ធម្មជាតិញុំាងសត្វឱ្យបម្រើន, **ទុតិយា** ធម្មជាតិជាគម្រប់ពីរ, **បណិធិ** ការតាំងចិត្តទុក, **ភវនេត្តិ** ធម្មជាតិនាំសត្វទៅកាន់ភព, **វនំ** ធម្មជាតិដូចជាព្រៃ, **វនថោ** ដូចជាព្រៃស្បាត, **សន្ថវោ** ការមូលមិត្ត, **សិនេហោ** សេចក្ដីស្រឡាញ់, **អបេក្ខា** ការអាឡោះអាល័យ, **បដិពន្ធុ** ផៅពង្សតទៅ, **អាសា** ការប៉ុនប៉ង, **អាសិសនា** ការប្រាថ្នា, **អាសិសិតត្តំ** ភាពនៃចិត្តប៉ុនប៉ង, **រូបាសា** ការប៉ុនប៉ងរូប, **សទ្ទាសា** ប៉ុនប៉ងសំឡេង, **គន្ធាសា** ប៉ុនប៉ងក្លិន, **រសាសា** ប៉ុនប៉ងរស, **ផោដ្ឋព្វាសា** ប៉ុនប៉ងផ្សព្វ,

**លាភាសា** ប៉ុនប៉ងលាភ, **ធនាសា** ប៉ុនប៉ងទ្រព្យ, **បុត្តាសា** ប៉ុនប៉ងបុត្រ, **ជីវិតាសា** ប៉ុនប៉ងជីវិត, **ជប្បា** ធម្មជាតិឆ្លេឆ្លា, **បជប្បា** ឆ្លេឆ្លាជ្រុល, **អភិជប្បា** ឆ្លេឆ្លាខ្លាំង, **ជប្បា** សេចក្តីឆ្លេឆ្លា, **ជប្បនា** អាការឆ្លេឆ្លា, **ជប្បិតត្តំ** ភាពនៃចិត្តឆ្លេឆ្លា, **លោលុប្បំ** ការរុលត្បុល, **លោលុប្បាយនា** អាការរុលត្បុល, **លោលុប្បាយិតត្តំ** ភាពនៃចិត្តរុលត្បុល, **បុច្ឆញ្ចិកតា** ការញាប់ញ័រ, **សាធុកម្យតា** ការចង់បានសម្រេចប្រយោជន៍, **អធម្មរាគោ** ការត្រេកអរខុសគន្លងធម៌, **វិសមលោភោ** ការលោភហួសកំណត់, **និកន្តិ** ការត្រេកត្រអាល, **និកាមនា** ការចង់បានមិនឈប់, **បត្ថនា** ការប្រាថ្នា, **បិហនា** សេចក្តីស្រឡាញ់, **សម្បត្ថនា** ការប្រាថ្នាព្រម, **កាមតណ្ហា** ប្រាថ្នាក្នុងកាម, **ភវតណ្ហា** ប្រាថ្នាក្នុងភព, **វិភវតណ្ហា** ប្រាថ្នាប្រាសចាកភព, **រូបតណ្ហា** ប្រាថ្នាក្នុងរូបភព, **អរូបតណ្ហា** ប្រាថ្នាក្នុងអរូបភព, **និរោធតណ្ហា** ប្រាថ្នាក្នុងនិរោធ, **រូបតណ្ហា** ប្រាថ្នារូប, **សទ្ទតណ្ហា** ប្រាថ្នាសំឡេង, **គន្ធតណ្ហា** ប្រាថ្នាក្លិន, **រស**

**តណ្ហា** ប្រាថ្នារស, **ផោដ្ឋព្វតណ្ហា** ប្រាថ្នាផ្សព្វ, **ធម្មតណ្ហា** ប្រាថ្នាធម៌, **ឱឃោ** កិលេសដូចជាជំនន់, **យោគោ** គ្រឿងប្រកប, **គន្ថោ** គ្រឿងចងក្រង, **ឧបាទានំ** គ្រឿងប្រកាន់មាំ, **អាវរណំ** គ្រឿងរារាំងទូទៅ, **នីវរណំ** គ្រឿងរារាំងមិនសល់, **ឆាទនំ** គ្រឿងបិទបាំង, **ពន្ធនំ** គ្រឿងចង, **ឧបក្កិលេសោ** គ្រឿងសៅហ្មងខ្លាំង, **អនុសយោ** គ្រឿងដេកចាំ, **បរិយុដ្ឋានំ** គ្រឿងស្ទាក់ដំណើរ, **លតា** តណ្ហាដូចជាវល្លិ, **វេវិច្ឆំ** ប្រាថ្នាផ្សេង ៗ, **ទុក្ខមូលំ** ឫសគល់នៃទុក្ខ, **ទុក្ខនិទានំ** ហេតុនៃទុក្ខ, **ទុក្ខប្បភវោ** ហេតុជាដែនកើតនៃទុក្ខ, **មារបាសោ** អន្ទាក់នៃមារ, **មារពឡិសំ** នុយនៃមារ, **មារវិសយោ** អារម្មណ៍នៃមារ, **តណ្ហានទី** ស្ទឹងគឺ តណ្ហា, **តណ្ហាជាលំ** បណ្ដាញ គឺ តណ្ហា, **តណ្ហាគទ្ទុលំ** ខ្នោះគឺ តណ្ហា, **តណ្ហាសមុទ្ទោ** សមុទ្រគឺ តណ្ហា, **អភិជ្ឈា** ការ

សម្ងឹងរំពៃ, **លោភោ** សេចក្ដីលោភ, **អកុសលមូលំ** ជាអកុសលមូល, នេះ ហៅថា លោភៈ ។[១]

**តណ្ហា** មានវចនត្ថៈថា

**បរិតស្សតីតិ = តណ្ហា** ឈ្មោះថា តណ្ហា ព្រោះអត្ថថា ចង់

**តណ្ហា** មាន ៣ គឺ

**១-កាមតណ្ហា** មានវចនត្ថៈថា

**កាមោ ច សោ តណ្ហា ចាតិ = កាមតណ្ហា** កាមនោះឯង ជាតណ្ហា ទើបឈ្មោះថា **កាមតណ្ហា** ។

**២-ភវតណ្ហា** មានវចនត្ថៈថា

**សស្សតទិដ្ឋិសហគតោ ហិ រាគោ = ភវតណ្ហាតិ វុច្ចតិ** ពិតមែន សេចក្ដីត្រេកអរកើតព្រមនឹងសេចក្ដីយល់ខុសថា ទៀង ហៅថា **ភវតណ្ហា** ។

---

១. អភិ. សង្គ. ហេតុគោច្ឆក. ៧៩. ១៩១/១៤១ ។

៣-វិភវតណ្ហា មានវចនត្ថៈថា

**ឧច្ឆេទទិដ្ឋិសហគតោ ហិ រាគោ = វិភវតណ្ហាតិ វុច្ចតិ** ពិតមែន សេចក្ដីត្រេកអរ កើតព្រមនឹងសេចក្ដីយល់ខុសថា ដាច់សូន្យ ហៅថា **វិភវតណ្ហា** ។

## ៦-ទិដ្ឋិចេតសិក

**ទិដ្ឋិ** មានវចនត្ថៈថា **ទស្សនំ = ទិដ្ឋិ** សេចក្ដីយល់ឃើញ ឈ្មោះថា ទិដ្ឋិ ។

<u>ក្នុងអភិធម្មត្ថវិភាវិនីដីកា</u> អធិប្បាយថា

**ឥទមេវ សច្ចំ មោឃមញ្ញន្តិ មិច្ឆាភិនិវេសលក្ខណា = ទិដ្ឋិ** ទិដ្ឋិ មានលក្ខណៈប្រកាន់ក្នុងវត្ថុដែលខុសថា "វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទទេ" ដូច្នេះ, បានដល់ ទិដ្ឋិ ៦២ យ៉ាង ។

## ទិដ្ឋិ ២ យ៉ាង

**១-សាមញ្ញទិដ្ឋិ** បានដល់ សក្កាយទិដ្ឋិដែលមានសេចក្ដីយល់ខុសចាកពីបរមត្ថថា "ជាមនុស្ស ជាសត្វ ជា

អត្តា” ។

ទិដ្ឋិនេះ មានទូទៅដល់បុថុជ្ជន វៀរព្រះអរិយៈប៉ុណ្ណោះ ទើបហៅថា សាមញ្ញទិដ្ឋិ ។

**២-ទិដ្ឋិវិសេស** បានដល់ ទិដ្ឋិ ៦២ វៀរសក្កាយទិដ្ឋិ ព្រោះទិដ្ឋិនេះ មានដល់មនុស្សពួកខ្លះ និងឱកាសខ្លះ ដូច និយតមិច្ឆាទិដ្ឋិ ៣ គឺ នត្ថិកទិដ្ឋិ ១ អហេតុកទិដ្ឋិ ១ និង អកិរិយទិដ្ឋិ ១ ។

<u>ក្នុងអដ្ឋសាលិនី</u> អធិប្បាយទុកថា

១-**ទិដ្ឋិ** ឈ្មោះថា **ទិដ្ឋិគតៈ** សេចក្តីឃើញខុស ព្រោះប្រព្រឹត្ត ទៅក្នុងទិដ្ឋិ ៦២ យ៉ាង

២-**ទិដ្ឋិនោះឯង** ឈ្មោះថា **ទិដ្ឋិគហនៈ** សាំញ៉ាំគឺ ទិដ្ឋិ ព្រោះ ការឈានកន្លងបានដោយលំបាក ដូចព្រៃស្តុក

៣-**ទិដ្ឋិនោះឯង** ឈ្មោះថា **ទិដ្ឋិកន្តារ** កន្តារៈគឺ ទិដ្ឋិ ព្រោះជា ផ្លូវគួរវង្វេស មានភ័យចំពោះមុខ ដូចផ្លូវដែលមាន ភ័យអំពីចោរ ភ័យអំពីសត្វកាច ភ័យអំពីវាលខ្សាច់

ភ័យអំពីទឹកជនលិច និងភ័យអំពីអត់បាយ

៤-ដែលឈ្មោះថា **ទិដ្ឋិវិសូកាយិកៈ** ចម្រូងគឺ ទិដ្ឋិ ព្រោះជំទាស់ចំពោះសម្មាទិដ្ឋិ

៥-ដែលឈ្មោះថា **ទិដ្ឋិវិប្ផន្ទិតៈ** សេចក្ដីស្ទុះស្ទាគឺទិដ្ឋិ ព្រោះប្រែប្រួល គឺ ពេលខ្លះ កាន់យកថា ទៀង ពេលខ្លះ កាន់យកថា ដាច់សូន្យ

៦-ដែលឈ្មោះថា **ទិដ្ឋិសំយោជនៈ** ធម្មជាតិជាគ្រឿងប្រកបគឺ ទិដ្ឋិ ព្រោះជាគ្រឿងចង

៧-ដែលឈ្មោះថា **គាហៈ** ការចាប់ប្រកាន់ ព្រោះកាន់អារម្មណ៍ទុកមាំ

៨-ដែលឈ្មោះថា **បតិដ្ឋាហៈ** ការប្រកាន់មាំ ព្រោះជាពាហៈដែលមានកម្លាំង

៩-ដែលឈ្មោះថា **អភិនិវេសៈ** ការតាំងមាំ ព្រោះប្រកាន់មាំក្នុងខ្លួន និងរបស់ជាប់ដោយខ្លួនថា ជារបស់ទៀងយឺនយូរ

១០-ដែលឈ្មោះថា **បរាមាសៈ** ការស្ទាបអង្អែល ព្រោះឈានកន្លងសភាវៈ កាន់យកដោយប្រការដទៃ ដោយអំណាចនៃសេចក្ដីទៀងជាដើម

១១-ដែលឈ្មោះថា **កុម្មគ្គៈ** ផ្លូវអាក្រក់ ព្រោះជាផ្លូវអបាយដែលបណ្ឌិតខ្ពើម

១២-ដែលឈ្មោះថា **មិច្ឆាបថៈ** គន្លងខុស ព្រោះមិនមែនផ្លូវនៃសេចក្ដីពិត

១៣-ដែលឈ្មោះថា **មិច្ឆត្តៈ** សេចក្ដីខុស ព្រោះជាសភាពខុសដូចមនុស្សវង្វេងផ្លូវ

១៤-ដែលឈ្មោះថា **តិត្ថាយតនៈ** ធម្មជាតិជាកំណើតនៃសេចក្ដីវិនាស គឺ លទ្ធិដូចជាកំពង់សម្រាប់ឆ្លង ព្រោះជាអណ្ដូងកើត និងជាទីអាស្រ័យកើតឡើងនៃពួកតិរ្ថិយ

១៥-ដែលឈ្មោះថា **វិបរិយេសគ្គាហៈ** ការប្រកាន់ព្រោះស្វែងរកខុស ព្រោះកាន់យកសភាវៈដោយត្រិះរិះ ខុសចាកសេចក្ដីពិត ។

## លក្ខណាទិចតុក្កៈរបស់ទិដ្ឋិ

**១-អយោនិសោ អភិនិវេសលក្ខណា** មានការប្រកាន់ទុកដោយមិនត្រូវទំនង ជាលក្ខណៈ ។

**២-បរាមាសរសោ** មានការប្រកាន់ដោយខុសពីសភាវៈ ជាកិច្ច

**៣-មិច្ឆាភិនិវេសនបច្ចុប្បដ្ឋានា** មានការប្រកាន់មាំ ក្នុងផ្លូវខុស ជាផល

**៤-អរិយានំ អទស្សនកាមតាទិ បទដ្ឋានា** មានការមិនចង់ឃើញព្រះអរិយៈជាដើម ជាហេតុជិត ។

## ៧-មានចេតសិក

**មាន** មានវចនត្ថៈថា **សេយ្យោហមស្មីតិ អាទិនា មញ្ញតីតិ = មានោ** ឈ្មោះថា មានះ ព្រោះអត្ថថា សំគាល់ខ្លួន ដោយលក្ខណៈ មានជាដើមថា "យើងជាអ្នកប្រសើរជាងគេ" ដូច្នេះ ។

## មានះ ២ យ៉ាង

**មានះ** ដែលព្រះសោតាបន្នលះ ហៅថា **អយាថាវមានះ** មាន ៦ គឺ

១-ល្អជាងគេ សំគាល់ខ្លួនថា ស្មើគេ
២-ល្អជាងគេ សំគាល់ខ្លួនថា ទាបជាងគេ
៣-ស្មើគេ សំគាល់ខ្លួនថា ល្អជាងគេ
៤-ស្មើគេ សំគាល់ខ្លួនថា ទាបជាងគេ
៥-ទាបជាងគេ សំគាល់ខ្លួនថា ល្អជាងគេ
៦-ទាបជាងគេ សំគាល់ខ្លួនថា ស្មើគេ ។

មានះ ដែលព្រះអរហន្តលះ ហៅថា **យាថាវមានះ** មាន ៣ គឺ

១-ល្អជាងគេ សំគាល់ថា ល្អជាងគេ
២-ស្មើគេ សំគាល់ថា ស្មើគេ
៣-ទាបជាងគេ សំគាល់ថា ទាបជាងគេ

<u>ក្នុងខុទ្ទកវត្ថុវិភង្គ</u> សម្ដែងនូវមានះ ៣ យ៉ាង គឺ ល្អជាងគេ ១ ស្មើគេ ១ និងទាបជាងគេ ១ យ៉ាងណាមួយ អាស្រ័យជាតិ មានជាតិក្សត្រជាដើម អាស្រ័យគោត្រដែលខ្ពស់ មានគោត្តមគោត្រជាដើម អាស្រ័យត្រកូលធំ អាស្រ័យរូបរាង អាស្រ័យទ្រព្យ អាស្រ័យភាពជាធំ អាស្រ័យនាទីការងារ អាស្រ័យសិល្បៈ អាស្រ័យការសិក្សា និងអាស្រ័យបដិភាណៈ កើតឡើង ៗ

មួយទៀត មានះ មានបរិយាយ (វេវចនៈ) លោកពោលទុកយ៉ាងនេះថា ៖

១- ឈ្មោះថា **អតិមានះ** សេចក្ដីមើលងាយដោយជាតិជាដើម

២- ឈ្មោះថា **មានាតិមានះ** សេចក្ដីឆ្មើងកន្ទ្រើង

៣- ឈ្មោះថា **ឱមានះ** ការប្រកាន់ដ៏ថោកទាប

៤- ឈ្មោះថា **អធិមានះ** សំគាល់ថា សម្រេចធម៌វិសេស

៥- ឈ្មោះថា **អស្មិមានះ** សំគាល់ថា មានអត្តា

៦- ឈ្មោះថា **មិច្ឆាមានះ** សំគាល់ខុស ។

## លក្ខណាទិចតុក្កៈរបស់មានះ

**១-ឧន្នតិលក្ខណោ** មានការលើកខ្លួន ( អួតខ្លួន ) ជាលក្ខណៈ

**២-សម្បគ្គហរសោ** មានការលើកតម្កើង( សរសើរ ) ជាកិច្ច

**៣-កេតុកម្យតាបច្ចុប្បដ្ឋានោ** មានសេចក្ដីត្រូវការដូចជាទង់ ជាផល

**៤-ទិដ្ឋិវិប្បយុត្តលោភបទដ្ឋានោ** មានលោភៈមិនប្រកបដោយទិដ្ឋិ ជាហេតុជិត ។

## ៨-ទោសចេតសិក

**ទោស** មានវចនត្ថៈថា **ទុស្សតីតិ = ទោសោ** ឈ្មោះថា ទោសៈ ព្រោះអត្ថថា ប្រទូសរ៉ាយ ។

កុ្នងវិសុទ្ធិមគ្គ ពោលថា **ទុស្សន្តិ តេន សយំ វា**

**ទុស្សតិ ទុស្សនមត្តមេវ វា តន្តិ = ទោសោ** ឈ្មោះថា ទោសៈ ព្រោះអត្ថថា ជាហេតុប្រទូសរ៉ាយសត្វ ឬឈ្មោះថា ទោសៈ ព្រោះអត្ថថា ប្រទូសរ៉ាយខ្លួនឯង, ឬថា ត្រឹមតែប្រទូសរ៉ាយប៉ុណ្ណោះ ក៏ឈ្មោះថា ទោសៈ ។

ទោសៈ គប្បីឃើញដូចទឹកមូត្រស្អុយលាយដោយថ្នាំពិស

## លក្ខណាទិចតុក្កៈរបស់ទោសៈ

**១-ចណ្ឌិកលក្ខណោ** មានការកាច ជាលក្ខណៈ ដូចអាសិរពិស ដែលត្រូវគេវាយ

**២-វិសប្បនរសោ** មានការរសាប់រសល់ ជាកិច្ច ដូចថ្នាំពិសជ្រាបចូល

**វា អត្តនោ និស្សយទហនរសោ** ឬដុតបំផ្លាញទីនៅរបស់ខ្លួន ជាកិច្ច ដូចភ្លើងឆេះព្រៃ

**៣-ទុស្សនបច្ចុប្បដ្ឋានោ** មានការប្រទូសរ៉ាយ ជាផល ដូចសត្រូវបានឱកាស

**៤-អាឃាតវត្ថុបទដ្ឋានោ** មានអាឃាតវត្ថុ ជាហេតុជិត ។

**ក្នុងធម្មសង្គណី** ពោលអំពីទោសៈជាអាឃាត គឺ

**អាឃាតវត្ថុ ១០**

១. គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ

២. គំនុំកើតឡើងថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ

៣. គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ

៤. គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អាត្មាអញ

៥. គំនុំកើតឡើងថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់ បុគ្គលជាទីស្រឡាញ់ ជាទីពេញចិត្តរបស់

អាត្មាអញ

៦. គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អាត្មាអញ

៧. គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អាត្មាអញ

៨. គំនុំកើតឡើងថា ជនឯណោះកំពុងប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អាត្មាអញ

៩. គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អាត្មាអញ

១០. សេចក្តីក្រោធកើតឡើងក្នុងទីមិនគួរ ដូចពេលដែលដើរ

ជំពប់ ឬ ជាន់បន្ទាជាដើម ។[១]

( អដ្ឋកថាឥតិវុត្តកៈ ទោសសូត្រទី២ មានអាឃាតវត្ថុ ១៩ )

**ប្រភេទរបស់ទោសៈ**[២]

**ចិត្តស្ស អាឃាតោ** : ការគុំគួននៃចិត្ត, **បដិឃាតោ** : ការគុំគួនតប, **បដិឃំ** : សេចក្តីថ្នាំងថ្នាក់, **បដិវិរោមោ** : ការទឹងតប, **កោបោ** : ការទឹងញាប់ញ័រ, **បកោបោ** : ការក្រោធខ្លាំង, **សម្បកោបោ** : ការក្រោធញាប់ញ័រ, **ទោសោ** : ការប្រទូស្ត, **បទោសោ** : ការប្រទូស្តតប, **សម្បទោសោ** : ការប្រទូស្តគ្រប់យ៉ាង, **ចិត្តស្ស ព្យាបត្តិ** : ការខូចចិត្ត, **មនោបទោសោ** : ការប្រទូស្តនៃចិត្ត, **កោមោ** : ការក្រោធ, **កុជ្ឈនា** : ការទឹង, **កុជ្ឈិតត្តំ** : ភាពនៃចិត្តទឹង, **ទោសោ** : សេចក្តីប្រទូស្ត **ទុស្សនា** : អាការប្រទូស្ត, **ទុស្សិតត្តំ** : ភាពនៃចិត្តប្រទូស្ត **ព្យាបត្តិ** : សេចក្តីវិនាស, **ព្យាបជ្ជនា** :

---

១.២. អភិ. សង្គ. ៧៩. ១៩១/១៤២-៣ ។

អាការវិនាស **ព្យាបជ្ជិតត្តំ** : ភាពនៃចិត្តវិនាស, **វិរោធោ** : ការទឹង **បដិវិរោធោ** : ការទឹងតប, **ចណ្ឌិក្កំ** : ភាពនៃចិត្តកាច **អសុរោបោ** : ការពោលពាក្យអសុរោះ, **អនត្តមនតា ចិត្តស្ស** : ការតូចចិត្ត ; នេះហៅថា ទោសៈ ។

## ៩_ឥស្សាចេតសិក

**ឥស្សា** មានវចនត្ថៈថា **ឥស្សតីតិ** = **ឥស្សា** ឈ្មោះថា ឥស្សា ព្រោះប្ញស្សា ។ ឥស្សានេះ ប្រណែនគ្នា មិនឱ្យអ្នកដទៃបានលាភៈ សក្ការៈ សេចក្ដី គោរព សេចក្ដីរាប់អាន និងការបូជាជាដើម ។

## លក្ខណាទិចតុក្កៈរបស់ឥស្សា

**១-បរសម្បត្តីនំ ឧស្សូយនលក្ខណា** មានការប្រណែនសម្បត្តិអ្នកដទៃ ជាលក្ខណៈ

**២-តត្ថេវ អនភិរតិរសា** មានការមិនត្រេកអរក្នុងសម្បត្តិ

អ្នកដទៃ ជាកិច្ច

**៣-វិមុខភាវបច្ចុប្បដ្ឋានា** មានការបែរមុខចេញ ជាផល

**៤-បរសម្បត្តិបទដ្ឋានា** មានសម្បត្តិអ្នកដទៃ ជាហេតុជិត ។

## ១០-មច្ឆរិយចេតសិក

**មច្ឆរិយ** មានវចនត្ថៈថា ៖

**មច្ឆេរស្ស ភាវោ = មច្ឆរិយំ** ភាវៈនៃបុគ្គលអ្នកកំណាញ់ ឈ្មោះថា មច្ឆរិយៈ

<u>**យោជនា**</u> អធិប្បាយថា

ធម្មជាតិដែលប្រព្រឹត្តទៅដោយអាការថា "សេចក្តីអស្ចារ្យនេះ ចូរកុំមានដល់ពួកជនដទៃ សេចក្តីអស្ចារ្យនេះ ចូរមានដល់យើងប៉ុណ្ណោះ" ដូច្នេះ ឈ្មោះថា មច្ឆរិយៈ ។

បណ្ឌិតគប្បីឃើញមច្ឆរិយៈថា ជាសេចក្តីពិការរបស់ចិត្ត ។

## មច្ឆរិយៈ ៥ យ៉ាង

**១-អាវាសមច្ឆរិយំ** សេចក្ដីកំណាញ់អាវាស

**២-កុលមច្ឆរិយំ** សេចក្ដីកំណាញ់ត្រកូល

**៣-លាភមច្ឆរិយំ** សេចក្ដីកំណាញ់លាភ

**៤-វណ្ណមច្ឆរិយំ** សេចក្ដីកំណាញ់វណ្ណៈ

**៥-ធម្មមច្ឆរិយំ** សេចក្ដីកំណាញ់ធម៌ ។

## លក្ខណាទិចតុក្កៈរបស់មច្ឆរិយៈ

**១-លទ្ធានំ វា លភិតព្វានំ អត្តនោ សម្បត្តីនំ និគូហណលក្ខណំ** មានការបិទបាំងសម្បត្តិរបស់ខ្លួនដែលបានហើយ ឬដែលគួរបាន ជាលក្ខណៈ

**២-តាសំយេវ បរេហិ សាធារណភាវអក្ខមនរសំ** មានការមិនពេញចិត្តដែលសម្បត្តិរបស់ខ្លួនទៅជាសាធារណៈដល់ជនដទៃ ជាកិច្ច

**៣-សំកោចនបច្ចុប្បដ្ឋានំ** មានការក្រញូវមុខ ជាផល

**៤-អត្តនោ សម្បត្តិបទដ្ឋានំ** មានសម្បត្តិរបស់ខ្លួន ជាហេតុជិត ។

## ១១-កុក្កុច្ចចេតសិក

**កុក្កុច្ច** មានវចនត្ថៈថា **កុកតស្ស ភាវោ បវត្តនិមិត្តំ = កុក្កុច្ចំ** ភាវៈ គឺ និមិត្ត ជាទីប្រព្រឹត្តទៅនៃកម្មដែលបណ្ឌិតស្អប់ ឈ្មោះថា កុក្កុច្ចៈ ។

កុក្កុច្ចៈនេះ ជាកង្វល់ចិត្ត ដោយប្រារព្ធកម្ម គឺ ទុច្ចរិតដែលធ្វើហើយនិងសុចរិតដែលមិនបានធ្វើ, ជាកម្មដែលបណ្ឌិតស្អប់ ។

គប្បីឃើញកុក្កុច្ចៈនេះ ដូចមនុស្សជាទាសៈ ។

### លក្ខណាទិចតុក្កៈរបស់កុក្កុច្ចៈ

**១-បច្ឆានុតាបនលក្ខណំ** មានការក្តៅក្រហាយចិត្តរឿយ ៗជាខាងក្រោយ ជាលក្ខណៈ

**២-កតាកតានុសោចនរសំ** មានការសោកសៅរឿយ ៗក្នុង

បាបដែលធ្វើហើយ និងបុណ្យនៅមិនទាន់បានធ្វើ ជាកិច្ច

***៣-វិប្បដិសារបច្ចុប្បដ្ឋានំ*** មានការស្តាយក្រោយ ជាផល

***៤-កតាកតបទដ្ឋានំ*** មានបាបដែលធ្វើហើយនិងបុណ្យដែលមិនទាន់បានធ្វើ ជាហេតុជិត ។

## ១២_ថីនចេតសិក

***ថីន*** មានវចនត្ថៈថា ***ថីនតា*** = ***ថីនំ*** សេចក្តីរួញរាឈ្មោះថា ថីនៈ ។

ក៏ថីនៈនេះ គប្បីឃើញថា ជាធម៌បៀតបៀនចិត្ត ឱ្យថយចាកអារម្មណ៍ ។

### លក្ខណាទិចតុក្កៈរបស់ថីនៈ

***១-អនុស្សាហនលក្ខណំ*** មានការមិនឧស្សាហ៍ ជាលក្ខណៈ

***២-វីរិយវិនោទនរសំ*** មានការកំចាត់ការព្យាយាម ជាកិច្ច

***៣-សំសីទនបច្ចុប្បដ្ឋានំ*** មានការលិចចុះ ជាផល

**៤-អរតិវិជម្ភិកាទីសុ អយោនិសោមនសិការបទដ្ឋានំ** មិនមាន យោនិសោមនសិការៈ ក្នុងអរតិ និងក្នុងសេចក្ដីពារែកជាដើម ជាហេតុជិត ។

## ១៣-មិទ្ធចេតសិក

**មិទ្ធ** មានវចនត្ថៈថា **មិជ្ឈនតា = មិទ្ធំ** សេចក្ដីថា សេចក្ដីងោកងុយ ឈ្មោះថា មិទ្ធៈ ។

មិទ្ធៈនេះ ជាធម៌បៀតបៀនចេតសិកឱ្យថយចាកពីអារម្មណ៍ ។

### លក្ខណាទិចតុក្កៈរបស់មិទ្ធៈ

**១-អកម្មញ្ញតា លក្ខណំ** មានភាពមិនគួរដល់ការងារ ជាលក្ខណៈ

**២-ឱនហនរសំ** មានការបិទបាំងសហជាតធម៌ ជាកិច្ច

**៣-លីនតាបច្ចុប្បដ្ឋានំ** មានការរាថយ ចាលចាញ់ ជាផល

**៤-អរតិវិជម្ភិកាទីសុ អយោនិសោមនសិការបទដ្ឋានំ** មាន

អយោនិសោមនសិការៈ ក្នុងអរតិ និងក្នុងសេចក្ដីងោក ងុយជាដើម ជាហេតុជិត ។

**ថីនៈ** និង**មិទ្ធៈ** ចេតសិកទាំង ២ នេះ ប្រកបជាមួយនឹងចិត្តដែលជាសសង្ខារិក ៥ គឺ ក្នុងលោភមូលចិត្ត ៤ និងទោសមូលចិត្ត ១ , ចេតសិកទាំង ២ នេះ កើតរួមគ្នាជានិច្ច ដោយប្រៀបថីនៈ ដូចអណ្ដាតភ្លើង មិទ្ធៈ ដូចពន្លឺ កាលភ្លើងធំ ពន្លឺក៏ច្រើន បើភ្លើងតូច ពន្លឺក៏តិចចុះ ។

## ១៤_វិចិកិច្ឆាចេតសិក

វិចិកិច្ឆាចេតសិក ប្រែថា សេចក្ដីសង្ស័យ បានដល់សេចក្ដីសង្ស័យ ៨ យ៉ាង គឺ ១-សង្ស័យក្នុងព្រះពុទ្ធ ២-សង្ស័យក្នុងព្រះធម៌ ៣-សង្ស័យក្នុងព្រះសង្ឃ ៤-សង្ស័យក្នុងសិក្ខា ៥-សង្ស័យក្នុងអតីតធម៌ ៦-សង្ស័យក្នុងអនាគតធម៌ ៧-សង្ស័យក្នុងអតីតនិងអនាគតធម៌ ៨-សង្ស័យក្នុងបដិច្ចសមុប្បាទ ។

**វិចិកិច្ឆា** មានវិចនត្ថៈថា **វិគតា ចិកិច្ឆាតិ = វិចិកិច្ឆា** ឈ្មោះថា វិចិកិច្ឆា ព្រោះអត្ថថា មានសេចក្ដីពិតក្នុងចិត្តទៅប្រាសហើយ ។

## លក្ខណាទិចតុក្កៈរបស់វិចិកិច្ឆា

**១-សំសយនលក្ខណា** មានការសង្ស័យ ជាលក្ខណៈ

**២-កម្បនរសា** មានការញាប់ញ័រ ជាកិច្ច

**៣-អនិច្ឆយបច្ចុប្បដ្ឋានា** មានការវិនិច្ឆ័យមិនដាច់ ជាផល

**៤-អយោនិសោមនសិការបទដ្ឋានា** មានអយោនិសោមនសិការៈ ជាហេតុជិត ។

អកុសលចេតសិក ១៤ មាន ៥ ន័យ គឺ

១-មោចតុក្កចេតសិក ៤

២-លោតិកចេតសិក ៣

៣-ទោចតុក្កចេតសិក ៤

៤-ថីទុកចេតសិក ២

៥-វិចិកិច្ឆាចេតសិក ១

## សម្តែងអកុសលចេតសិក ១៤

អកុសលចេតសិក ១៤

- មោចតុក្កៈ ៤
  - មោហចេតសិក ១
  - អហិរិកចេតសិក ១
  - អនោត្តប្បចេតសិក ១
  - ឧទ្ធច្ចចេតសិក ១
- លោតិកៈ ៣
  - លោភចេតសិក ១
  - ទិដ្ឋិចេតសិក ១
  - មានចេតសិក ១
- ទោចតុក្កៈ ៤
  - ទោសចេតសិក ១
  - ឥស្សាចេតសិ ១
  - មច្ឆរិយចេតសិក ១
  - កុក្កុច្ចចេតសិក ១
- ថីទុកៈ ២
  - ថីនចេតសិក ១
  - មិទ្ធចេតសិក ១
- ឯកវិចិកិច្ឆា ១ - វិចិកិច្ឆាចេតសិក ១

**ចប់ អកុសលចេតសិក**

## សោភណចេតសិក ២៥

សោភណចេតសិក ជាចេតសិកផ្នែកល្អ មិនប្រកបជាមួយនឹងអកុសលចិត្ត ១២ និងអហេតុកចិត្ត ១៨ ទេ គឺប្រកបជាមួយនឹងចិត្តដែលនៅសល់ ៥៩ ឬ ៩១,

### ចែកចេញជា ៤ ន័យ គឺ

១-សោភណសាធារណចេតសិក ១៩

២-វិរតិចេតសិក ៣

៣-អប្បមញ្ញាចេតសិក ២

៤-បញ្ញាចេតសិក ១

## អធិប្បាយ សោភណសាធារណចេតសិក ១៩

### ១-សទ្ធាចេតសិក

**សទ្ធា** បានដល់ សេចក្តីជឿ សេចក្តីជ្រះថ្លា ក្នុងព្រះពុទ្ធ ក្នុងព្រះធម៌ ក្នុងព្រះសង្ឃ ក្នុងកម្ម ក្នុងផលរបស់កម្ម និងសេចក្តីដែលសត្វមានកម្មជារបស់ខ្លួន ៗ ។

**សទ្ធា** មានវិចនត្ថៈថា **សទ្ទហតីតិ = សទ្ធា. ពុទ្ធាទីសុ**

**បសាទោ** ធម្មជាតិណា រមែងជឿ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា សទ្ធា បានដល់ សេចក្ដីជ្រះថ្លា ក្នុងព្រះពុទ្ធជាម្ចាស់ជាដើម ។

## លោកសន្និវាស មានប្រមាណ ៤

**១-រូបប្បមាណោ** អ្នកកាន់យករូបជាប្រមាណ
**២-ឃោសប្បមាណោ** អ្នកកាន់យកសំឡេងជាប្រមាណ
**៣-លូខប្បមាណោ** អ្នកកាន់យកភាពសៅហ្មងជាប្រមាណ
**៤-ធម្មប្បមាណោ** អ្នកកាន់យកធម៌ជាប្រមាណ ។

ព្រះមានព្រះភាគ កាលទ្រង់មានព្រះជន្មគង់នៅ រមែងជាទីជ្រះថ្លា យ៉ាងក្រៃលែងរបស់លោកសន្និវាសទាំង ៤ នេះ ព្រោះថា អ្នកដែលនិយមក្នុងរូប ឃើញព្រះរូបប្រកបដោយមហាបុរិសលក្ខណៈ ៣២ របស់ព្រះអង្គហើយ រមែងជ្រះថ្លាយ៉ាងក្រៃលែង, អ្នកដែលនិយមក្នុងសំឡេង បានស្ដាប់ព្រះសូរសៀងប្រកបដោយអង្គ ៨ ដូចសំឡេងរបស់មហាព្រហ្មហើយ រមែងជ្រះថ្លាយ៉ាងក្រៃលែង, អ្នកដែលនិយមក្នុង

ការគ្រងសំពត់ដែលសៅហ្មង ឃើញសំពត់មហាបង្សុកូលចីវរ របស់ព្រះអង្គ ដែលបានពីសាកសពរបស់នាងបុណ្ណាទាសី ដែលគេនាំមកចោលក្នុងព្រៃខ្មោចហើយ រមែងជ្រះថ្លាយ៉ាង ក្រៃលែង, អ្នកដែលនិយមក្នុងគុណធម៌ទាំងឡាយ ក៏គុណធម៌ របស់អ្នកដទៃដែលនឹងស្មើដោយគុណ មានសីលាទិគុណជា ដើមរបស់ព្រះពុទ្ធជាម្ចាស់ រមែងមិនមានទេ ។

ចែកសត្វទាំងអស់ចេញជាបីចំណែក ពីរចំណែកកាន់ យករូបជាប្រមាណ មួយចំណែកមិនកាន់យករូបជាប្រមាណ ។ ចែកសត្វទាំងអស់ចេញជាប្រាំចំណែក បួនចំណែកកាន់យក សំឡេងគឹកកងជាប្រមាណ មួយចំណែកមិនកាន់យកសំឡេង គឹកកងជាប្រមាណ ។ ចែកសត្វទាំងអស់ចេញជាដប់ចំណែក ប្រាំបួនចំណែកកាន់យកសេចក្តីសៅហ្មងជាប្រមាណ មួយ ចំណែកមិនកាន់យកសេចក្តីសៅហ្មងជាប្រមាណ ។ កាល ចែកសត្វទាំងអស់ចេញជាមួយសែនចំណែក តែមួយចំណែក ប៉ុណ្ណោះកាន់យកធម៌ជាប្រមាណ ដែលនៅសល់គប្បីជ្រាបថា

មិនកាន់យកជម៏ជាប្រមាណទេ ។[១]

## លក្ខណាទិចតុក្កៈរបស់សទ្ធា

**១-សទ្ទហនលក្ខណា** មានការជឿ ជាលក្ខណៈ

**២-សម្បសាទនរសា** មានការធ្វើឱ្យថ្លូវថង់ ជាកិច្ច ដូចកែវមណី ធ្វើទឹកឱ្យថ្លា

**៣-អកាលុស្សិយបច្ចុប្បដ្ឋានា** មានការមិនល្អក់កករ ជាផល

**៤-សទ្ធេយ្យវត្ថុបទដ្ឋានា** មានវត្ថុជាទីតាំងនៃសេចក្ដីជឿ ជាហេតុជិត ។

## សទ្ធាមានលក្ខណៈ ៣ យ៉ាងទៀត

១-មានការជឿជាលក្ខណៈ (ឱកប្បនលក្ខណា) ២-មានការជឿមាំជាលក្ខណៈ ៣-មានការត្រាច់ទៅជាលក្ខណៈ (សម្បក្ខន្ទលក្ខណា) ។ ចំពោះហេតុន័យមួយទៀតថា មាន

---

១. មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយចតុកនិបាត រូបសូត្រ ។

សោតាបត្តិយង្គ ជាហេតុជិត ។

## ២_សតិចេតសិក

**សតិ** មានវចនត្ថៈថា **សរណំ = សតិ អសម្មោសោ** សេចក្តីរលឹក ឈ្មោះថា សតិ បានដល់ សេចក្តីមិនវង្វេងភ្លេច ។

មួយទៀត **សរន្តិ ឯតាយ សយំ វា សរតិ សរណមត្តមេវ វា ឯសាតិ = សតិ** បុគ្គលរមែងរលឹកបាន ដោយធម្មជាតិនោះ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **សតិ.** ឬធម្មជាតិនោះ រមែងរលឹកបានខ្លួនឯង ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **សតិ** ឬថា ធម្មជាតិនោះ ត្រឹមតែជាការរលឹកប៉ុណ្ណោះ ព្រោះហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា **សតិ** គឺ សេចក្តីរលឹកបាន ។

### លក្ខណាទិចតុក្កៈរបស់សតិ

**១_អបិលាបនលក្ខណា** មានការរលឹកបាន មិនរវើរវាយ ជា

លក្ខណៈ

**២-អសម្មោសរសោ** មានការមិនវង្វេងភ្លេច ជាកិច្ច

**៣-វិសយាភិមុខភាវបច្ចុបដ្ឋានា** មានការប្រាថ្នាចំពោះអារម្មណ៍ ជាផល

**៤-ថិរសញ្ញាបទដ្ឋានា កាយាទិសតិបទដ្ឋានា វា** មានការចាំប្រាកដ ឬថា មានសតិប្បដ្ឋាន ក្នុងកាយជាដើម ជាហេតុជិត ។

## ៣-ហិរិចេតសិក

**ហិរិ** មានវចនត្ថៈថា : **ហិរិយតិ កាយទុច្ចរិតាទីហិ ជិគុច្ឆតីតិ** = **ហិរិ** ធម្មជាតិ ដែលឈ្មោះថា **ហិរិ** ព្រោះអត្ថថា ខ្មាស គឺរង្កៀសចំពោះទុច្ចរិត មានកាយទុច្ចរិតជាដើម ។

### លក្ខណាទិចតុក្កៈរបស់ហិរិ

**១-បាបតោ ជិគុច្ឆនលក្ខណា** មានការរង្កៀសចំពោះបាប ជា

លក្ខណៈ

២-បាបានំ អករណរសា មានការមិនធ្វើបាប ជាកិច្ច

៣-បាបតោ សង្កោចនបច្ចុប្បដ្ឋានា មានការថយចាកពីបាប ជាផល

៤-អត្តគារវបទដ្ឋានា មានការគោរពខ្លួន ជាហេតុជិត ។

## ៤-ឱត្តប្បចេតសិក

ឱត្តប្ប មានវចនត្ថៈថា **តេហិយេវ ឱត្តប្បតីតិ** = **ឱត្តប្បំ** ធម្មជាតិណា រមែងក្រែងខ្លាចចំពោះទុច្ចរិតទាំងនោះឯង ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ឱត្តប្បៈ ។

### លក្ខណាទិចតុក្កៈរបស់ឱត្តប្បៈ

១-ឧត្តាសលក្ខណំ មានការតក់ស្លុត ជាលក្ខណៈ

២-បាបានំ អករណរសំ មានការមិនធ្វើបាប ជាកិច្ច

៣-បាបតោ សង្កោចនបច្ចុប្បដ្ឋានំ មានការថយចាកបាប ជាផល

៤-បរគារវបទដ្ឋានំ មានការគោរពអ្នកដទៃ ជាហេតុជិត ។

ពិតមែន ហិរិ មានការគោរពខ្លួន ទើបមិនធ្វើបាប ដោយការខ្មាស ដូចស្រីក្រមុំមានត្រកូល រង្កៀស(ខ្ពើម)វត្ថុបដិកូល, ចំណែកឱត្តប្បៈ មានការគោរពអ្នកដទៃ ទើបមិនហ៊ានធ្វើបាប ព្រោះការក្រែងខ្លាច ដូចស្រីពេស្យា មានការក្រែងខ្លាចអ្នកដទៃ ។

ហិរិ និងឱត្តប្បនេះ លោកហៅថា លោកបាលធម៌[១] (ធម៌រក្សានូវសត្វលោក) ជាធម៌យ៉ាងស្ងប់ មិនរាយមាយ ។

## ៥_អលោភចេតសិក

***អលោភ*** មានវចនត្ថៈថា : ***លោភបដិបក្ខោ* = *អលោភោ*** ធម៌ដែលបដិបក្ខចំពោះលោភៈ ឈ្មោះថា អលោភៈ ។

មួយទៀត ***នលុព្ភន្តិ តេន សយំ វា ន លុព្ភតិ អលុព្ភនមត្តមេវ វា តន្តិ* = *អលោភោ*** សត្វទាំងឡាយ មិន

---

១. អង្គុ. ទុក. កម្មករណវគ្គ. ៤០. ២៥៥/១១៣ ។

លោកដោយធម៌នោះ ហេតុនោះ ធម៌នោះ ឈ្មោះថា អលោភៈ ឬធម៌ណា ខ្លួនឯងមិនលោភ ធម៌នោះ ក៏ឈ្មោះថា អលោភៈ ឬថា ធម៌នោះ ត្រឹមតែមិនលោភប៉ុណ្ណោះ ក៏ឈ្មោះថា **អលោភៈ ។**

## លក្ខណាទិចតុក្កៈរបស់អលោភៈ

**១-អលគ្គភាវលក្ខណោ** មានការមិនជាប់នៅក្នុងអារម្មណ៍ ជាលក្ខណៈ ដូចដំណក់ទឹក មិនជាប់ក្នុងត្របកផ្កាឈូក

**២-អបរិគ្គហរសោ** មានការមិនហួងហែង ជាកិច្ច ដូចអ្នកដែលរួចផុតហើយ

**៣-អនល្លីនភាវបច្ចុប្បដ្ឋានោ** មានការមិនប្រកាន់មាំក្នុងអារម្មណ៍ ជាផល ដូចអ្នកធ្លាក់ទៅក្នុងរណ្តៅស្មោគគ្រោគ

**៤-យោនិសោមនសិការបទដ្ឋានោ** មានយោនិសោមនសិការៈ ជាហេតុជិត ។

## ៦-អទោសចេតសិក

**អទោស** មានវិគ្រោះថា : **ទោសបដិបក្ខោ** = **អទោសោ** ធម៌ដែលបដិបក្ខចំពោះទោសៈ ឈ្មោះថា អទោសៈ ។ ន័យដ៏សេស ដូចអលោភៈ ។

### លក្ខណាទិចតុក្កៈរបស់អទោសៈ

**១-អចណ្ឌិក្កលក្ខណោ** មានការមិនកាច ជាលក្ខណៈ ដូចមិត្តអ្នកអនុគ្រោះ

**២-អាឃាតវិនយរសោ** មានការកំចាត់អាឃាត ជាកិច្ច

**៣-សោមភាវបច្ចុប្បដ្ឋានោ** មានសេចក្តីត្រជាក់ ជាផល ដូចព្រះចន្ទពេញវង់

**៤-យោនិសោមនសិការបទដ្ឋានោ** មានយោនិសោមនសការៈជាហេតុជិត ។

## ៧_តត្រមជ្ឈត្តតាចេតសិក

តត្រមជ្ឈត្តតា មានវិគ្រោះថា **តេសុ តេសុ ធម្មេសុ មជ្ឈត្តតា = តត្រមជ្ឈត្តតា** ភាពជាកណ្តាលក្នុងធម៌នោះ ៗ ឈ្មោះថា តត្រមជ្ឈត្តតា ។

### លក្ខណាទិចតុក្កៈរបស់តត្រមជ្ឈត្តតា

**១-ចិត្តចេតសិកានំ សមវាហិតលក្ខណា** មានការនាំចិត្តនិងចេតសិកទៅដោយស្មើជានិច្ច ជាលក្ខណៈ

**២-ឩនាធិកតានិវារណរសា** មានការហាមនូវភាពលើសនិងខ្វះ ជាកិច្ច

**៣-មជ្ឈត្តភាវបច្ចុប្បដ្ឋានា** មានភាពជាកណ្តាល ជាផល

**៤-សម្បយុត្តបទដ្ឋានា** មានសម្បយុត្តធម៌ ជាហេតុជិត ។

តត្រមជ្ឈត្តតាចេតសិកនេះ មានន័យច្រើន បណ្ឌិតគប្បីឃើញដោយភាពព្រងើយនៃចិត្ត និងចេតសិកទាំងឡាយ ដូចសារថី សម្លឹងមើលព្រងើយ ៗ នូវសេះអាជានេយ្យដែលរត់ទៅស្មើល្អហើយ ដូច្នោះ ។

## យុគលធម៌ ៦ គូ

យុគលធម៌គូទី ១ : **៨-កាយបស្សទ្ធិ ៩-ចិត្តបស្សទ្ធិ**

ពាក្យថា **កាយបស្សទ្ធិ** បានដល់ ស្ងប់នាមខន្ធ ៣ គឺ វេទនា សញ្ញា សង្ខារក្ខន្ធ, ចិត្តបស្សទ្ធិ បានដល់ ស្ងប់វិញ្ញាណក្ខន្ធ ។

**បស្សទ្ធិ** មានវិចនត្ថៈថា **កាយស្សបស្សម្ភនំ = កាយបស្សទ្ធិ** សេចក្តីស្ងប់កាយ ឈ្មោះថា កាយបស្សទ្ធិ ។ **ចិត្តស្ស បស្សម្ភនំ = ចិត្តបស្សទ្ធិ** សេចក្តីស្ងប់ចិត្ត ឈ្មោះថា ចិត្តបស្សទ្ធិ ។

### លក្ខណាទិចតុក្កៈរបស់បស្សទ្ធិ

**១-កាយចិត្តានំ ទរថវូបសមលក្ខណា** មានការស្ងប់នាមខន្ធ ៣ និងចិត្តជាលក្ខណៈ

**២-កាយចិត្តទរថនិម្មទ្ទនរសា** មានការកំចាត់ភាពក្តៅក្រហាយរបស់កាយនិងចិត្ត ជាកិច្ច

**៣-កាយចិត្តានំ អបរិប្ផន្ទន សីតិភាវបច្ចុប្បដ្ឋានា** មានភាពស្ងប់ត្រជាក់ មិនក្តៅ ផ្សាំនៃនាម ខន្ធ ៣ និងចិត្ត ជាផល

**៤-កាយចិត្តបទដ្ឋានា** មាននាមខន្ធ ៤ ជាហេតុជិត ។

យុគលធម៌គូទី ២ : **១០-កាយលហុតា ១១-ចិត្តលហុតា**

**លហុតា** មានវចនត្ថៈថា **កាយស្ស លហុភាវោ** = **កាយលហុតា** សេចក្តីស្រាលនៃកាយ ឈ្មោះថា កាយលហុតា, **ចិត្តស្ស លហុភាវោ** = **ចិត្តលហុតា** សេចក្តីស្រាលនៃចិត្ត ឈ្មោះថា ចិត្តលហុតា ។

## លក្ខណាទិចតុក្កៈរបស់លហុតា

**១-កាយចិត្តគរុភាវរូបសមលក្ខណា** មានការស្ងប់ភាពធ្ងន់របស់កាយ និងចិត្ត ជាលក្ខណៈ

**២-កាយចិត្តគរុភាវនិម្មទ្ទនរសា** មានការកំចាត់ភាពធ្ងន់របស់កាយនិងចិត្ត ជាកិច្ច

**៣-កាយចិត្តានំ អទន្ធតាបច្ចុប្បដ្ឋានា** មានការមិនយឺតយូររបស់កាយនិងចិត្ត ជាផល

**៤-កាយចិត្តបទដ្ឋានា** មាននាមខន្ធ ៤ ជាហេតុជិត ។

យុគលធម៌គូទី ៣ : **១២-កាយមុទុតា ១៣-ចិត្តមុទុតា**

**មុទុតា** មានវចនត្ថៈថា **កាយស្ស មុទុភាវោ = កាយមុទុតា** ភាពទន់នៃកាយ ឈ្មោះថា កាយមុទុតា ។ **ចិត្តស្ស មទុភាវោ = ចិត្តមុទុតា** ភាពទន់នៃចិត្ត ឈ្មោះថា ចិត្តមុទុតា ។

## លក្ខណាទិចតុក្កៈរបស់មុទុតា

**១-កាយចិត្តថទ្ធភាវវូបសមលក្ខណា** មានការស្ងប់ភាពរឹងរបស់នាមខន្ធ ៣ និង ចិត្ត ជាលក្ខណៈ

**២-កាយចិត្តថទ្ធភាវនិម្មទ្ទនរសា** មានការកំចាត់ភាពរឹងរបស់កាយនិងចិត្ត ជាកិច្ច

**៣-អប្បដិឃាតបច្ចុប្បដ្ឋានា** មានភាពមិនជំទាស់ ជាផល
**៤-កាយចិត្តបទដ្ឋានា** មាននាមខន្ធ ៤ ជាហេតុជិត ។

យុគលធម៌គូទី៤ **១៨-កាយកម្មញ្ញតា ១៩-ចិត្តកម្មញ្ញតា**

**កម្មញ្ញតា** មានវចនត្ថៈថា **កាយស្ស កម្មញ្ញភាវោ** = **កាយកម្មញ្ញតា** សេចក្តីគួរដល់ការងារនៃកាយ ឈ្មោះថា កាយកម្មញ្ញតា ។ **ចិត្តស្ស កម្មញ្ញភាវោ** = **ចិត្តកម្មញ្ញតា** សេចក្តីគួរដល់ការងារនៃចិត្ត ឈ្មោះថា ចិត្តកម្មញ្ញតា ។

## លក្ខណាទិចតុក្កៈរបស់កម្មញ្ញតា

**១-កាយចិត្តានំ អកម្មញ្ញភាវវូបសមលក្ខណា** មានការរម្ងាប់កាយនិងចិត្តដែលមិនគួរដល់ការងារ ជាលក្ខណៈ

**២-កាយចិត្តាកម្មញ្ញភាវនិម្មទ្ទនរសា** មានការកំចាត់ភាពមិនគួរដល់ការងាររបស់កាយ និងចិត្ត ជាកិច្ច

**៣-កាយចិត្តានំ អារម្មណករណសម្បត្តិបច្ចុប្បដ្ឋានា** មានការ

ដល់ព្រមក្នុងការធ្វើអារម្មណ៍ឱ្យកាយនិងចិត្ត ជាផល

**៤-កាយចិត្តបទដ្ឋានា** មាននាមខន្ធ ៤ ជាហេតុជិត ។

យុគលធម៌គូទី៥ **១៦-កាយបាគុញ្ញតា ១៧-ចិត្តបាគុញ្ញតា**

**បាគុញ្ញតា** មានវចនត្ថៈថា : **កាយស្ស បាគុញ្ញភាវោ** = **កាយបាគុញ្ញតា** ការស្ទាត់ជំនាញនៃកាយ ឈ្មោះថា កាយបាគុញ្ញតា ។

**ចិត្តស្ស បាគុញ្ញភាវោ** = **ចិត្តបាគុញ្ញតា** ការស្ទាត់ជំនាញនៃចិត្ត ឈ្មោះថា ចិត្តបាគុញ្ញតា ។

## លក្ខណាទិចតុក្កៈរបស់បាគុញ្ញតា

**១-កាយចិត្តានំ គេលញ្ញរូបសមលក្ខណា** មានការស្ងប់ភាពឈឺរបស់កាយនិងចិត្ត ជាលក្ខណៈ

**២-កាយចិត្តគេលញ្ញនិម្មទ្ទនរសា** មានការកំចាត់អាពាធរបស់កាយនិងចិត្ត ជាកិច្ច

**៣-និរាទីនវបច្ចុប្បដ្ឋានា** មានការប្រាសចាកទោស ជាផល
**៤-កាយចិត្តបទដ្ឋានា** មាននាមខន្ធ ៤ ជាហេតុជិត ។

យុគលធម៌គូទី ៦ : **១៨-កាយុជុកតា ១៩-ចិត្តុជុកតា**

**ឧជុកតា** មានវចនត្ថៈថា **កាយស្ស ឧជុកភាវោ** = **កាយុជុកតា** សេចក្តីត្រង់របស់កាយ ឈ្មោះថា កាយុជុកតា ។ **ចិត្តស្ស ឧជុកភាវោ** = **ចិត្តុជុកតា** សេចក្តីត្រង់របស់ចិត្ត ឈ្មោះថា ចិត្តុជុកតា ។

## លក្ខណាទិចតុក្កៈរបស់ឧជុកតា

**១-កាយចិត្តានំ អជ្ជវ លក្ខណា** មានភាពត្រង់នៃកាយ និងចិត្ត ជាលក្ខណៈ
**២-កាយចិត្តកុដិលភាវនិម្មទ្ទនរសា** មានការកំចាត់សេចក្តីមិនត្រង់របស់កាយ និងចិត្ត ជាកិច្ច
**៣-អជិម្ហតាបច្ចុប្បដ្ឋានា** មានភាពត្រង់របស់កាយ និងចិត្ត ជាផល

៤-កាយចិត្តបទដ្ឋានា មាននាមខន្ធ ៤ ជាហេតុជិត ។

**យុគលធម៌ ៦ ជាបដិបក្ខចំពោះបាបធម៌**

គូទី ១ **បស្សទ្ធិ** ជាបដិបក្ខចំពោះឧទ្ធច្ចៈ

គូទី ២ **លហុតា** ជាបដិបក្ខចំពោះថីនៈ មិទ្ធៈ

គូទី ៣ **មុទុតា** ជាបដិបក្ខចំពោះទិដ្ឋិ មានះ

គូទី ៤ **កម្មញ្ញតា** ជាបដិបក្ខចំពោះនីវរណៈដែលនៅសល់

គូទី ៥ **បាគុញ្ញតា** ជាបដិបក្ខចំពោះការមិនមានសទ្ធា

គូទី ៦ **ឧជុកតា** ជាបដិបក្ខចំពោះមាយា និងសាឋេយ្យៈ ជាដើម ។

## វិរតិចេតសិក ៣

១-សម្មាវាចាចេតសិក បានដល់ វាចាប្រពៃ
២-សម្មាកម្មន្តចេតសិក បានដល់ ការងារប្រពៃ
៣-សម្មាអាជីវចេតសិក បានដល់ អាជីវៈប្រពៃ

## ២០-សម្មាវាចាចេតសិក

សម្មាវាចា មានវចនត្ថៈថា

**សម្មា វទន្តិ ឯតាយាតិ = សម្មាវាចា វចីទុច្ចរិតវិរតិ**
វិរតិ ឈ្មោះថា សម្មាវាចា ព្រោះអត្ថថា ជាគ្រឿងនិយាយដោយប្រពៃនៃបុគ្គល បានដល់ ការវៀរចាកវចីទុច្ចរិត ៤ ។

### សម្មាវាចា ៤

១-ចេតនាវៀរចាកការនិយាយកុហក ឆបោក
២-ចេតនាវៀរចាកការនិយាយញុះញង់ បំបែកបំបាក់
៣-ចេតនាវៀរចាកការនិយាយពាក្យអាក្រក់ ជេរប្រទេច
៤-ចេតនាវៀរចាកការនិយាយរោយរាយ ឥតប្រយោជន៍

### លក្ខណាទិចតុក្កៈរបស់សម្មាវាចា

**១-វចីទុច្ចរិតវត្ថូនំ អវីតិក្កមលក្ខណា** មានការមិនកន្លងវត្ថុដែលជាទីតាំងនៃវចីទុច្ចរិត ជាលក្ខណៈ

**២-វចីទុច្ចរិតវត្ថុតោ សង្កោចនរសា** មានការថយចាកវត្ថុដែលជាទីតាំងនៃវចីទុច្ចរិត ជាកិច្ច

**៣-តស្ស អក្រិយបច្ចុប្បដ្ឋានា** មានការមិនធ្វើវចីទុច្ចរិតនោះជាផល

**៤-សទ្ធាហិរោត្តប្បអប្បិច្ឆតាទិគុណបទដ្ឋានា** មានគុណ គឺ សទ្ធា ហិរិ ឱត្តប្បៈ សេចក្តីប្រាថ្នាតិចជាដើម ជាហេតុជិត ។

## ២១-សម្មាកម្មន្តចេតសិក

**សម្មាកម្មន្ត** មានវចនត្ថៈថា : **សម្មា បវត្តោ កម្មន្តោ = សម្មាកម្មន្តោ កាយទុច្ចរិតវិរតិ** ការងារដែលប្រព្រឹត្តទៅដោយប្រពៃ ឈ្មោះថា សម្មាកម្មន្តៈ បានដល់ ចេតនាជាគ្រឿងវៀរចាកកាយទុច្ចរិត ។

## សម្មាកម្មន្តៈ ៣

១-ចេតនាវៀរចាកការសម្លាប់សត្វ

២-ចេតនាវៀរចាកការលួចទ្រព្យគេ

៣-ចេតនាវៀរចាកការប្រព្រឹត្តិខុសក្នុងកាម

## លក្ខណាទិចតុក្កៈរបស់សម្មាកម្មន្តៈ

**១-កាយទុច្ចរិតវត្ថូនំ អវីតិក្កមលក្ខណោ** មានការមិនកន្លង

វត្ថុដែលជាទីតាំងនៃកាយទុច្ចរិត ជាលក្ខណៈ

**២-កាយទុច្ចរិតវត្ថុតោ សង្កោចនរសោ** មានការថយចាក

វត្ថុដែលជាទីតាំងនៃកាយទុច្ចរិត ជាកិច្ច

**៣-តស្ស អក្រិយបច្ចុប្បដ្ឋានោ** មានការមិនធ្វើកាយ

ទុច្ចរិតនោះ ជាផល

**៤-សទ្ធាហិរោត្តប្បអប្បិច្ឆតាទិគុណបទដ្ឋានោ** មានគុណ គឺ សទ្ធា

ហិរិ ឱត្តប្បៈ សេចក្ដីប្រាថ្នាតិចជាដើម ជាហេតុជិត ។

## ២២_សម្មាអាជីវចេតសិក

***សម្មាអាជីវ*** មានវចនត្ថៈថា : ***សម្មា អាជីវន្តិ ឯតេនាតិ = សម្មាអាជីវោ មិច្ឆាជីវវិរតិ*** វិរតិ ឈ្មោះថា សម្មាអាជីវៈ ព្រោះអត្ថថា ជាគ្រឿងចិញ្ចឹមជីវិត ដោយប្រពៃនៃសត្វទាំងឡាយ បានដល់ ចេតនាវៀរចាកមិច្ឆាអាជីវៈ ។

សម្មាអាជីវៈ មាន ៧ យ៉ាង គឺ វៀរចាកកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ដែលមានអាជីវៈជាហេតុ, ឬមានច្រើនយ៉ាង ដោយអំណាចនៃការវៀរចាកការកុហក បោកបញ្ឆោតជាដើម ។

### លក្ខណាទិចតុក្កៈរបស់សម្មាអាជីវៈ

***១_តិវិធកាយទុច្ចរិតចតុព្វិធវចីទុច្ចរិតវត្ថូនំ អវីតិក្កមលក្ខណោ***

មានការមិនកន្លងវត្ថុដែលជាទីតាំងនៃកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ជាលក្ខណៈ

***២_តេសំ វត្ថុតោ សង្កោចនរសោ*** មានការថយចាកវត្ថុដែល

ជាទីតាំងនៃ កាយទុច្ចរិត៣ និងវចីទុច្ចរិត៤ ជាកិច្ច ។

**៣-តេសំ ទុច្ចរិតានំ អក្រិយបច្ចុប្បដ្ឋានោ** មានការមិនធ្វើទុច្ចរិតនោះ ជាផល

**៤-សទ្ធាហិរោត្តប្បាទិគុណបទដ្ឋានោ** មានគុណ គឺ សទ្ធា ហិរិ ឱត្តប្បៈជាដើម ជាហេតុជិត ។

## អធិប្បាយវិរតិ ៣

ភាវៈនៃការវៀរចាកបាប ឈ្មោះថា វិរតិចេតនា ឬ ហៅថា វិរតិ មាន ៣ ប្រភេទ គឺ ៖

១-សម្បត្តវិរតិ ២-សមាទានវិរតិ ៣-សមុច្ឆេទវិរតិ

* **សម្បត្តវិរតិ** បានដល់ ការវៀរចាកបាប ដោយអធ្យាស្រ័យរបស់ខ្លួន ដូចក្នុងខណៈដែលកំពុងមានវិរមិតព្វវត្ថុ ( វត្ថុត្រូវវៀរ ) ប្រាកដចំពោះមុខហើយ ក៏មិនប្រព្រឹត្តកន្លង ។

* **សមាទានវិរតិ** បានដល់ ការវៀរចាកបាប ដោយសមាទាន( ការកាន់យកដោយល្អ ) នូវសិក្ខាបទដែល

បញ្ញត្តទុក មានសីល ៥ សីល ៨ ជាដើម ។

* **សមុច្ឆេទវិរតិ** បានដល់ ការវៀរចាកបាប ដែលកាត់ផ្តាច់ ដោយអរិយមគ្គ ។

## អប្បមញ្ញាចេតសិក ២

### ១-ករុណាចេតសិក ២-មុទិតាចេតសិក

**អប្បមញ្ញា** មានវចនត្ថៈថា **អប្បមាណេសុ សត្តេសុ ភវតីតិ = អប្បមញ្ញា** ធម្មជាតិ ឈ្មោះថា អប្បមញ្ញា ព្រោះអត្ថថា ប្រព្រឹត្តទៅក្នុងសត្វមិនមានប្រមាណ ។

## ២៣-ករុណាចេតសិក

**ករុណា** មានវិគ្រោះថា **បរទុក្ខេ សតិ សាធូនំ ហទយខេទំ ករោតីតិ = ករុណា** : ធម្មជាតិណា កាលសត្វដទៃមានទុក្ខ រមែងធ្វើសេចក្តីលំបាកចិត្ត ឱ្យសាធុជនទាំងឡាយ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ករុណា ។[1]

---

១. មានពិស្តារក្នុងយោជនា ។

## លក្ខណាទិចតុក្កៈរបស់ករុណា

**១-បរទុក្ខាបនយកាមតាលក្ខណា** មានសេចក្ដីត្រូវការបំបាត់ទុក្ខអ្នកដទៃ ជាលក្ខណៈ

**២-បរទុក្ខាសហានរសា** មានការអត់ធន់មិនបាននូវទុក្ខអ្នកដទៃ ជាកិច្ច

**៣-អវិហឹសា បច្ចុប្បដ្ឋានា** មានការមិនបៀតបៀន ជាផល

**៤-ទុក្ខាភិភូតានំ អានាថភាវទស្សនបទដ្ឋានា** មានការឃើញសត្វដែលទុក្ខគ្របសង្កត់ហើយ មិនមានទីពឹង ជាហេតុជិត ។

## សម្បត្តិរបស់ករុណាជាដើម

**-វិហឹសូបសមោ សម្បត្តិ** ករុណាមានការចូលទៅរម្ងាប់សេចក្ដីបៀតបៀន ជាសម្បត្តិ,

**-សោកសម្ភវោ វិបត្តិ** មានការកើតឡើងនៃសេចក្ដីសោកជាការវិបត្តិ

**-គេហសិតំ ទោមនស្សំ អាសន្នបច្ចត្ថិកា** មានការខូចចិត្តដែល

អាស្រ័យកាមគុណ ជាសត្រូវជិត,

-*វិហឹសា* **ទូរបច្ចត្ថិកា** មានការបៀតបៀនសត្វ ជាសត្រូវឆ្ងាយ ។

## ២៤_មុទិតាចេតសិក

**មុទិតា** មានវិគ្រោះថា **មោទន្តិ ឯតាយាតិ = មុទិតា** បុគ្គលរមែងត្រេកអរ ដោយធម្មជាតិនេះ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា មុទិតា ។

### លក្ខណាទិចតុក្កៈរបស់មុទិតា

**១-បរសម្បត្តិអនុមោទនលក្ខណា** មានការសរសើរសម្បត្តិរបស់អ្នកដទៃ ជាលក្ខណៈ

**២-អនិស្សាយនរសា** មានការមិនច្រណែន ជាកិច្ច

**៣-អរតិវិឃាតបច្ចុប្បដ្ឋានា** មានការកំចាត់អរតិ( ការមិនត្រេកអរ ) ជាផល

**៤-បរសម្បត្តិទស្សនបទដ្ឋានា** មានការឃើញសម្បត្តិរបស់សត្វដទៃ ជាហេតុជិត ។

## សម្បត្តិរបស់មុទិតាជាដើម

**-អរតិវូបសមោ សម្បត្តិ** មុទិតា មានការចូលទៅរម្ងាប់អរតិ ជាសម្បត្តិ,

**-បហាសសម្ភវោ វិបត្តិ** មានសេចក្ដីរីករាយ ជាការវិបត្តិ

**-គេហសិតំ សោមនស្សំ អាសន្នបច្ចត្ថិកា** មានសោមនស្សដែលអាស្រ័យកាមគុណ ជាសត្រូវជិត,

**-អរតិទូរបច្ចត្ថិកា** មានការមិនត្រេកអរ ជាសត្រូវឆ្ងាយ ។

## អប្បមញ្ញា ៤

**អប្បមញ្ញា ៤** គឺ មេត្តា ករុណា មុទិតា ឧបេក្ខា

ក្នុងអធិការនេះ លោកសម្ដែងចំពោះករុណា និងមុទិតា, ចំណែកមេត្តា ក៏គឺ អទោសចេតសិក, និងឧបេក្ខា ក៏គឺ តត្រមជ្ឈត្តតាចេតសិកនុ៎ះឯង, ដោយហេតុនោះ អាចារ្យ

ក្នុងកាលមុន ទើបពោលទុកថា ៖

អព្យាបាទេន មេត្តា ហិ តត្រមជ្ឈត្តតាយ ច
ឧបេក្ខា គហិតា យស្មា តស្មា ន គហិតា ឧភោ ។

*ក៏ព្រោះព្រះមានព្រះភាគ ទ្រង់កាន់យកមេត្តាដោយការមិនបៀតបៀន និងឧបេក្ខាដោយតត្រមជ្ឈត្តតា ដូច្នោះ អាចារ្យទាំងឡាយ ទើបមិនកាន់យកក្នុងទីនេះ ។*

## ២៥_បញ្ញិន្ទ្រិយចេតសិក

*បញ្ញា* មានវិគ្រោះថា-

***បជានាតីតិ = បញ្ញា*** *ឈ្មោះថា បញ្ញា ព្រោះអត្ថថា ដឹងទូទៅ គឺ ដឹងអរិយសច្ចៈជាដើម, បញ្ញានុ៎ះឯង ជាឥន្ទ្រិយ ព្រោះហេតុនោះ ទើបឈ្មោះថា បញ្ញិន្ទ្រិយ ។*

*សញ្ញា វិញ្ញាណ បញ្ញា ផ្សេងគ្នាយ៉ាងណា ?*

***សញ្ញា*** *ធ្វើនាទីត្រឹមតែចាំ ដោយអំណាចនៃការចាំ*

ពណ៌ក៏ជាដើមប៉ុណ្ណោះ មិនអាចចាក់ធ្លុះលក្ខណៈ,

**វិញ្ញាណ** រមែងដឹងអារម្មណ៍ឱ្យសម្រេចដល់ការយល់ចូលចិត្ត ចាក់ធ្លុះលក្ខណៈ[១], តែទោះបីទំទូលំទូលាយ ក៏មិនអាចសម្រេចមគ្គផលបានឡើយ ។

ចំណែក**បញ្ញា** រមែងធ្វើកិច្ចបានទាំង ៣ យ៉ាង ។

## លក្ខណាទិចតុក្កៈរបស់បញ្ញា

**១-ធម្មសភាវបដិវេធលក្ខណា** មានការចាក់ធ្លុះសភាវៈនៃធម៌ជាលក្ខណៈ

**២-ធម្មានំ សភាវបដិច្ឆាទកមោហន្ធការវិទ្ធំសនរសា** មានការកំចាត់ងងឹត គឺ មោហៈដែលបិទបាំងសភាវធម៌ ជាកិច្ច

**៣-អសម្មោហបច្ចុប្បដ្ឋានា** មានការមិនវង្វេងភ្លេច ជាផល

**៤-សមាធិ តស្សា បទដ្ឋានា** មានសមាធិ ជាហេតុជិត ។

ព្រោះព្រះបាលីថា "**សមាហិតោ ភិក្ខវេ ភិក្ខុ យថាភូតំ បជា**

**នាតិ :** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តតំកល់មាំហើយ រមែងដឹងច្បាស់តាមសេចក្តីពិត”[២] ។

## លក្ខណាទិចតុក្កៈរបស់បញ្ញា (មួយន័យទៀត)

**១-យថាភូតបដិវេធលក្ខណា** មានការចាក់ធ្លុះធម៌តាមសេចក្តីពិត ជាលក្ខណៈ

**២-វិសយោភាសនរសា** មានការធ្វើអារម្មណ៍ឱ្យភ្លឺ ជាកិច្ច

**៣-អសម្មោហបច្ចុប្បដ្ឋានា** មានការមិនវង្វេងភ្លេច ជាផល

**៤-យោនិសោមនសិការបទដ្ឋានា** មានយោនិសោមនសិការៈ ជាហេតុជិត

**តិហេតុកបដិសន្ធិកតាបទដ្ឋានា វា** ឬមានតិហេតុកបដិសន្ធិ ជាហេតុជិត ។

---

១. អភិធម្មត្ថវិភាវិនី ។

២. សំយុ. ខន្ធ. នកុលបិតវគ្គ. ៣៣. ២៧/៣៣ ។

បញ្ញាចេតសិកនេះ កាលកើតឡើង រមែងដឹងទូទៅ ដល់ធម៌ទាំងដែលជាកុសល អកុសល, ធម៌ដែលគួរសេព ធម៌ដែលមិនគួរសេព, ដឹងធម៌ដែលអាក្រក់ ធម៌ដែលប្រណីត, ធម៌ដែលចូលគ្នាបាន និងធម៌ដែលចូលគ្នាមិនបាន, ដូចពេទ្យអ្នកឆ្លាតអាចផ្សំភេសជ្ជៈគឺ ថ្នាំ ដែលជាទីសប្បាយដល់អ្នកជម្ងឺជាដើម ដូច្នោះ ។

## កម្មស្សកតាបញ្ញា ១០ យ៉ាង

***កម្មស្សកតាបញ្ញា*** បានដល់ បញ្ញាដឹងថា សត្វមានកម្មជារបស់ខ្លួន លោកហៅថា "***ទសវត្ថុសម្មាទិដ្ឋិ***" មានវត្ថុ១០គឺ ៖

***១-អត្ថិ ទិន្នំ*** យល់ថា ទានដែលគេឱ្យហើយ មានផល

***២-អត្ថិ យិដ្ឋំ*** យល់ថា ការបូជាធំ មានផល

***៣-អត្ថិ ហុតំ*** យល់ថា ការបូជាតូច មានផល

***៤-អត្ថិ សុកតទុក្កតានំ កម្មានំ វិបាកោ*** យល់ថា ផលវិបាករបស់កម្មដែលគេធ្វើល្អ និងធ្វើអាក្រក់ មាន

***៥-អត្ថិ អយំ លោកោ*** យល់ថា (សត្វដែលមកកើតក្នុង)

លោកនេះ មាន

៦-**អត្ថិ បរោ លោកោ** យល់ថា (សត្វដែលកើតក្នុង)លោកខាងមុខ មាន

៧-**អត្ថិ មាតា** យល់ថា គុណមាតា មាន

៨-**អត្ថិ បិតា** យល់ថា គុណបិតា មាន

៩-**អត្ថិ សត្តា ឧបបាតិកា** យល់ថា ពួកសត្វជាឧបបាតិកកំណើត មាន

១០- **អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា** យល់ថា ពួកសមណព្រាហ្មណ៍ក្នុងលោកជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិត្រឹមត្រូវ ដែលធ្វើឱ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយសម្តែងបាន មាន ។[១]

សោភណចេតសិក ២៥ នេះ ប្រកបបានតែចំពោះ

---

១. អភិ. សង្គ. សុត្តន្តិកទុកនិក្ខេប. ៧៩. ៣៧១/២៣៩ ។

សោភណចិត្ត ៥៩ ឬ ៩១ ប៉ុណ្ណោះ មិនប្រកបជាមួយ អសោភណ គឺ អកុសលចិត្ត ១២ អហេតុកចិត្ត ១៨ ដូច្នោះ ទើបលោកសម្ដែងទុក ៤ ន័យ ។

* ន័យទី ១ ចេតសិក ១៩ ឈ្មោះថា សោភណសាធារណចេតសិក គឺ ១.សទ្ធាចេតសិក ២.សតិចេតសិក ៣.ហិរិចេតសិក ៤.ឱត្តប្បចេតសិក ៥.អលោភចេតសិក ៦.អទោសចេតសិក ៧. តត្រមជ្ឈត្តតាចេតសិក
៨.កាយបស្សទ្ធិចេតសិក ៩.ចិត្តបស្សទ្ធិចេតសិក
១០.កាយលហុតាចេតសិក ១១.ចិត្តលហុតាចេតសិក
១២.កាយមុទុតាចេតសិក ១៣.ចិត្តមុទុតាចេតសិក
១៤.កាយកម្មញ្ញតាចេតសិក ១៥.ចិត្តកម្មញ្ញតាចេតសិក
១៦.កាយបាគុញ្ញតាចេតសិក ១៧.ចិត្តបាគុញ្ញតាចេតសិក
១៨.កាយជុកតាចេតសិក ១៩.ចិត្តជុកតាចេតសិក ។

* ចេតសិកនេះ ប្រកបជាមួយសោភណចិត្ត បានទាំង ៥៩ ឬ៩១ គឺ ពេលណាដែលសោភណចិត្តទាំង ៥៩ឬ៩១ ណា

មួយកើតឡើង សោភណសាធារណចេតសិកទាំង ១៩ នេះ ត្រូវកើតរួមជាមួយនឹងចិត្តទាំងនោះជានិច្ច មិនវៀរឡើយ, ចេតសិកនេះ ទើបឈ្មោះថា សោភណសាធារណចេតសិក ។

* ន័យទី ២ ចេតសិក៣ ឈ្មោះថា វិរតិចេតសិក គឺ សម្មាវាចាចេតសិក ១ សម្មាកម្មន្តចេតសិក ១ សម្មាអាជីវចេតសិក ១, ចេតសិកនេះ ប្រកបជាមួយនឹងចិត្តបាន ១៦ ឬ ៤៨ គឺ ប្រកបជាមួយមហាកុសលចិត្ត ៨ លោកុត្តរចិត្ត ៨ ឬ ៤០ ។

* ន័យទី ៣ ចេតសិក ២ ឈ្មោះថា អប្បមញ្ញាចេតសិក គឺ ករុណាចេតសិក ១ មុទិតាចេតសិក ១, ចេតសិក ២ នេះ ប្រកបជាមួយនឹងចិត្ត បាន ២៨ គឺ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ រូបាវចរចិត្ត ១២ (វៀររូបាវចរបញ្ចមជ្ឈានចិត្ត ៣)

* ន័យទី ៤ បញ្ញាចេតសិក ឬបញ្ញិន្ទ្រិយចេតសិក ប្រកបជាមួយនឹងចិត្តបាន ៤៧ ឬ៧៩ គឺកាមាវចរសោភណ

ចិត្ត ១២ មហគ្គត ២៧ លោកុត្តរ ៨ ឬ ៤០, ចំណែកលោកុត្តរបញ្ញានោះ ជាបញ្ញាដែលមិនដឹងលោកិយា-រម្មណ៍ទេ ដឹងតែនិព្វានារម្មណ៍ ដែលជាអារម្មណ៍ផុតចាកការតាក់តែង បានដល់ បញ្ញាដែលនៅក្នុងលោកុត្តរចិត្ត ៨ ឬ ៤០ ។

## សម្ដែងបញ្ញាចេតសិក ប្រកបជាមួយនឹងចិត្ត ៧៩

- បញ្ញាចេតសិក
  - លោកិយបញ្ញា ៣៩
    - ក្នុងមហាកុសលញាណសម្បយុត្ត ៤
    - ក្នុងមហាវិបាកញាណសម្បយុត្ត ៤
    - ក្នុងមហាកិរិយាញាណសម្បយុត្ត ៤
    - ក្នុងមហគ្គតកុសល ៩
    - ក្នុងមហគ្គតវិបាក ៩
    - ក្នុងមហគ្គតកិរិយា ៩
  - លោកុត្តរបញ្ញា ៨ឬ៤០
    - ក្នុងមគ្គចិត្ត ៤ ឬ ២០
    - ក្នុងផលចិត្ត ៤ ឬ ២០

## សម្ដែងសោភណចេតសិក ២៥

សោភណចេតសិក ២៥

- សោភណសាធារណចេតសិក ១៩
  - សទ្ធា ១ សតិ ១
  - ហិរិ ១ ឱត្តប្បៈ ១
  - អលោភៈ ១ អទោសៈ ១
  - តត្រមជ្ឈត្តតា ១
  - បស្សទ្ធិ ២ លហុតា ២
  - មុទុតា ២ កម្មញ្ញតា ២
  - បាគុញ្ញតា ២ ឧជុកតា ២
- វិរតិចេតសិក ៣
  - សម្មាវាចា ១
  - សម្មាកម្មន្ត ១
  - សម្មាអាជីវ ១
- អប្បមញ្ញាចេតសិក ២
  -ករុណា ១
  - មុទិតា ១
- បញ្ញិន្ទ្រិយចេតសិក ១ - បញ្ញា ១

**ចប់ សភាវធម៌ ៥២**

# សម្បយោគន័យ

## សង្គហគាថា

៣. តេសំ ចិត្តាវិយុត្តានំ    យថាយោគមិតោ បរំ

ចិត្តុប្បាទេសុ បច្ចេកំ    សម្បយោគោ បវុច្ចតិ ។

*ពាក្យខាងមុខនេះ ខ្ញុំនឹងពោលសម្បយោគ (ការប្រកប) នៃចេតសិកទាំងនោះ ដែលមិនប្រាសចាកពីចិត្ត តាមដែលប្រកបបានក្នុងចិត្តុប្បាទទាំងឡាយនីមួយ ៗ តទៅ ។*

*ចេតសិកនេះ មានវិគ្រោះថា **ចិត្តេន សហ អវិយុត្តាតិ = ចិត្តាវិយុត្តា** ចេតសិក ដែលឈ្មោះថា "ចិត្តាវិយុត្តា" ព្រោះមិនប្រាសចាកពីចិត្ត, ក៏ចិត្តព្រមទាំងសម្បយុត្តធម៌ ហៅថា ចិត្តុប្បាទ ។*

***សម្បយុត្តៈ សម្បយោគៈ** និងសង្គហៈ ផ្សេងគ្នាយ៉ាងណា ?*

***សម្បយុត្តៈ*** *ប្រែថា ប្រកបហើយ បានដល់ ចិត្ត ប្រកបជាមួយចេតសិក ដូចពាក្យថា* ***"ទិដ្ឋិគតសម្បយុត្ត"*** *ប្រែថា ចិត្តប្រកបដោយការយល់ខុស,* ***"បដិឃសម្បយុត្តំ"*** *ប្រែថា ចិត្តប្រកបដោយសេចក្តីខឹងក្រោធ ។*

***សម្បយោគៈ*** *ប្រែថា ការប្រកបរួមគ្នា បានដល់ ការ ប្រកបរួមគ្នារបស់ចេតសិកទាំងឡាយ ដែលមិនប្រាសចាកពី ចិត្ត ។*

***សង្គហៈ*** *ប្រែថា ការរួបរួម ឬការសង្គ្រោះក្នុងទីនេះ លោកប្រាថ្នាយកការរាប់ចំនួនចេតសិកក្នុងចិត្ត ៨៩ ឬ១២១ ។*

## សង្គហគាថា

៤. សត្ត សព្វត្ថ យុជ្ជន្តិ យថាយោគំ បកិណ្ណកា

ចុទ្ទសាកុសលេស្វេវ សោភណេសេ្វវ សោភណា ។

*សព្វចិត្តសាធារណចេតសិក ៧ ប្រកបក្នុងចិត្តទាំង អស់. បកិណ្ណកចេតសិក ៦ ប្រកបក្នុងចិត្តបាន*

តាមសមគួរ. អកុសលចេតសិក ១៤ ប្រកបចូលក្នុងអកុសលចិត្តទាំង១២. សោភណចេតសិក២៥ ប្រកបក្នុងសោភណចិត្ត ៥៩ ឬ ៩១ ប៉ុណ្ណោះ ។

សង្គហគាថាទី ៤ នេះ សម្ដែងសម្បយោគដោយសង្ខេបទុក ៤ ន័យ គឺ

| | | |
|---|---|---|
| សព្វចិត្តសាធារណចេតសិក | ៧ | ជាន័យទី ១ |
| បកិណ្ណកចេតសិក | ៦ | ជាន័យទី ២ |
| អកុសលចេតសិក | ១៤ | ជាន័យទី ៣ |
| សោភណចេតសិក | ២៥ | ជាន័យទី ៤ |

<u>សម្បយោគដោយពិស្ដារ</u> មាន ១៦ ន័យ គឺ

<u>អញ្ញសមានាចេតសិក</u> តាំងពីន័យទី ១- ៧

* <u>ន័យទី ១</u> បានដល់ សព្វចិត្តសាធារណចេតសិក ៧ មានផស្សៈជាដើម ប្រកបជាមួយចិត្តបានទាំងអស់
* <u>ន័យទី ២</u> បានដល់ វិតក្កៈ ប្រកបជាមួយចិត្តបាន

៥៥ ប្រកបមិនបាន ៦៦

* ន័យទី ៣ បានដល់ វិចារៈ ប្រកបជាមួយចិត្តបាន ៦៦ ប្រកបមិនបាន ៥៥

* ន័យទី ៤ បានដល់ អធិមោក្ខៈ ប្រកបជាមួយចិត្តបាន ៧៨ ប្រកបមិនបាន ១១

* ន័យទី ៥ បានដល់ វិរិយៈ ប្រកបជាមួយចិត្តបាន ៧៣ ប្រកបមិនបាន ១៦

* ន័យទី ៦ បានដល់ បីតិ ប្រកបជាមួយចិត្តបាន ៥១ ប្រកបមិនបាន ៧០

* ន័យទី ៧ បានដល់ ឆន្ទៈ ប្រកបជាមួយចិត្តបាន ៦៩ឬ ១០១ ប្រកបមិនបាន ២០ ។

**អកុសលចេតសិក** តាំងតែពីន័យទី ៨-១២ គឺ -

* ន័យទី ៨ បានដល់ មោចតុក្កៈ ៤ ប្រកបជាមួយ អកុសលចិត្តបាន ១២

* ន័យទី ៩ បានដល់ លោតិកៈ ៣ ប្រកបជាមួយលោភ

មូលចិត្តបាន ៨

* ន័យទី ១០ បានដល់ ទោចតុក្កៈ ៤ ប្រកបជាមួយទោសមូលចិត្ត ២

* ន័យទី ១១ បានដល់ ថីទុកៈ ២ ប្រកបជាមួយអកុសលចិត្តសសង្ខារិក ៥

* ន័យទី ១២ បានដល់ វិចិកិច្ឆា ប្រកបជាមួយវិចិកិច្ឆាសម្បយុត្តចិត្ត ១

**សោភណចេតសិក** តាំងតែពីន័យទី ១៣-១៦ គឺ

* ន័យទី ១៣ បានដល់ សោភណសាមារណចេតសិក ១៩ ប្រកបជាមួយសោភណចិត្ត ៥៩ ឬ ៩១

* ន័យទី ១៤ បានដល់ វិរតិចេតសិក ៣ ប្រកបជាមួយសោភណចិត្ត ១៦ ឬ ៤៨

* ន័យទី ១៥ បានដល់ អប្បមញ្ញាចេតសិក ២ ប្រកបជាមួយសោភណចិត្តបាន ២៨

* ន័យទី ១៦ បានដល់ បញ្ញាចេតសិក ប្រកបជាមួយ

សោភណចិត្តបាន ៤៧ ឬ៧៩

## អធិប្បាយសម្បយោគ ១៦ ន័យ

* ន័យទី ១ គឺ សព្វចិត្តសាធារណចេតសិក ៧ ប្រកបជាមួយចិត្តបានទាំងអស់នោះ មានសេចក្តីច្បាស់ហើយ ។

* ន័យទី ២-៧ បានដល់ បកិណ្ណកចេតសិក ៦ នោះ

មានសង្គហគាថាទី ៥ និងទី ៦ អធិប្បាយពន្យល់សេចក្តីទុកដូចតទៅនេះ ៖

## សង្គហគាថា

៥. ឆសដ្ឋី បញ្ចបញ្ញាស ឯកាទស ច សោឡស
សត្តតិ វីសតិ ចេវ បកិណ្ណកវិវជ្ជិតា ។

**ចិត្តវៀរចាកបកិណ្ណកចេតសិក ៦ បានដល់ ចិត្តដែលវៀរចាកវិតក្កៈ ៦៦. វៀរវិចារៈ ៥៥. វៀរអធិមោក្ខៈ ១១. វៀរវីរិយៈ ១៦. វៀរបីតិ**

៧០. វៀរឆន្ទៈ ២០ ។

៦. បញ្ចបញ្ញាស ឆសដ្ឋ្យ ដ្ឋសត្តតិ តិសត្តតិ
ឯកបញ្ញាស ចេកូន សត្តតិ សប្បកិណ្ណកា ។
ចិត្តដែលមានបកិណ្ណកចេតសិកប្រកប គឺ ចិត្ត
ដែលមានវិតក្កៈប្រកប ៥៥. មានវិចារៈប្រកប
៦៦. មានអធិមោក្ខៈប្រកប ៧៨. មានវិរិយៈ
ប្រកប ៧៣. មានបីតិប្រកប ៥១. និងមានឆន្ទៈ
ប្រកប ៦៩ ។

## អធិប្បាយ

*<u>ន័យទី ២</u> **វិតក្កចេតសិក** ប្រកបជាមួយចិត្តបាន ៥៥ គឺ -

-អកុសលចិត្ត ១២ -អហេតុកចិត្ត ៨ (វៀរទ្វិបញ្ចវិញ្ញាណ)

-កាមាវចរសោភណចិត្ត ២៤ -បឋមជ្ឈានចិត្ត ១១

**វិតក្កចេតសិក** មិនប្រកបជាមួយចិត្ត ៦៦ គឺ

-ទ្វិបញ្ចវិញ្ញាណ ១០ -ទុតិយជ្ឈានចិត្ត ១១

-តតិយជ្ឈានចិត្ត ១១ -ចតុត្ថជ្ឈានចិត្ត ១១

-បញ្ចមជ្ឈានចិត្ត ២៣

*ន័យទី ៣ **វិចារចេតសិក** ប្រកបជាមួយចិត្តបាន ៦៦ គឺ -

-អកុសលចិត្ត ១២ | -បឋមជ្ឈានចិត្ត ១១

-អហេតុកចិត្ត ៨ | -ទុតិយជ្ឈានចិត្ត ១១

-កាមាវចរសោភណចិត្ត ២៤

**វិចារចេតសិក** មិនប្រកបជាមួយចិត្ត ៥៥ គឺ

-ទ្វិបញ្ចវិញ្ញាណ ១០ -តតិយជ្ឈានចិត្ត ១១

-ចតុត្ថជ្ឈានចិត្ត ១១ -បញ្ចមជ្ឈានចិត្ត ២៣

*ន័យទី ៤ **អធិមោក្ខចេតសិក** ប្រកបជាមួយចិត្ត បាន ៧៨ ឬ ១១០ គឺ

អកុសលចិត្ត( វៀរវិចិកិច្ឆាចិត្ត )១១, អហេតុកចិត្ត ៨ ( វៀរទ្វិបញ្ចវិញ្ញាណ )

កាមាវចរសោភណចិត្ត ២៤, មហគ្គតចិត្ត ២៧,

លោកុត្តរចិត្ត ៨ ឬ ៤០

**អធិមោក្ខចេតសិក** មិនប្រកបជាមួយចិត្ត ១១ គឺ

-វិចិកិច្ឆាសម្បយុត្តចិត្ត ១ -ទ្វិបញ្ចវិញ្ញាណ ១០

*ន័យទី ៥ **វិរិយចេតសិក** ប្រកបជាមួយចិត្តបាន ៧៣ ឬ ១០ ៥ គឺ

| | |
|---|---|
| -អកុសលចិត្ត ១២ | -កាមាវចរសោភណចិត្ត ២៤ |
| -មនោទ្វារាវជ្ជនចិត្ត ១ | -មហគ្គតចិត្ត ២៧ |
| -ហសិតុប្បាទចិត្ត ១ | -លោកុត្តរចិត្ត ៨ ឬ ៤០ |

**វិរិយចេតសិក** មិនប្រកបជាមួយចិត្ត ១៦ គឺ

អហេតុកចិត្ត ១៦

*ន័យទី ៦ **បីតិចេតសិក** ប្រកបជាមួយចិត្តបាន ៥១ គឺ

-សោមនស្សលោភមូលចិត្ត ៤

-សោមនស្ស អហេតុកវិបាកមនោវិញ្ញាណធាតុ ១

-សោមនស្សហសិតុប្បាទចិត្ត ១

-សោមនស្សកាមាវចរសោភណចិត្ត ១២

-បឋមជ្ឈានចិត្ត១១ -ទុតិយជ្ឈានចិត្ត១១ -តតិយជ្ឈានចិត្ត១១

**បីតិចេតសិក** មិនប្រកបជាមួយចិត្ត ៧០ គឺ -

| | | | |
|---|---|---|---|
| -ឧបេក្ខាលោភមូលចិត្ត | ៤ | -កាយវិញ្ញាណ | ២ |
| -ទោសមូលចិត្ត | ២ | -ឧបេក្ខាកាមាវចរសោភណចិត្ត | ១២ |
| -មោហមូលចិត្ត | ២ | -ចតុត្ថជ្ឈានចិត្ត | ១១ |
| -ឧបេក្ខាអហេតុកៈ | ១៤ | -បញ្ចមជ្ឈានចិត្ត | ២៣ |

*ន័យទី ៧ **ឆន្ទចេតសិក** ប្រកបជាមួយចិត្តបាន ៦៩ ឬ ១០១ គឺ

-លោភមូលចិត្ត៨ -ទោសមូលចិត្ត២ -កាមាវចរសោភណចិត្ត២៤ -មហគ្គតចិត្ត២៧ -លោកុត្តរចិត្ត ៨ឬ៤០

**ឆន្ទចេតសិក** មិនប្រកបជាមួយចិត្ត ២០ គឺ

-មោហមូលចិត្ត ២ -អហេតុកចិត្ត ១៨

ការដែលរាប់ចិត្តដោយសង្ខេប ឬដោយពិស្តារនោះ បើចេតសិកណា ប្រកបជាមួយលោកុត្តរចិត្តទាំងអស់ ក៏រាប់ចិត្តនោះ ដោយសង្ខេប គឺ ៨៩, បើចេតសិកណា ប្រកបជា

មួយលោកុត្តរចិត្ត មិនបានទាំងអស់ទេ ក៏រាប់ចិត្តនោះដោយពិស្តារ ។

មួយទៀត វិតក្កៈនិងវិចារៈដែលប្រកបជាមួយលោកុត្តរចិត្ត ដែលពោលហើយនោះ ជាការរាប់លោកុត្តរចិត្តរបស់ព្រះអរិយបុគ្គលដែលបានឈាន បើវិតក្កៈ និងវិចារៈរបស់ព្រះអរិយបុគ្គលជាសុក្ខវិបស្សកៈហើយ, វិតក្កៈ និងវិចារៈនោះ ក៏ប្រកបជាមួយនឹងលោកុត្តរចិត្ត បានទាំងអស់ (៨) ។ ចំណែកបីតិចេតសិក បើលោកុត្តរចិត្តនោះ កើតព្រមនឹងសោមនស្សវេទនា បីតិក៏ប្រកបបាន, បើលោកុត្តរចិត្តនោះ កើតព្រមនឹងឧបេក្ខាវេទនា បីតិក៏មិនអាចប្រកបបាន ។

## អកុសលចេតសិក ១៤
## ប្រកបជាមួយអកុសលចិត្ត ១២ តាំងពីន័យទី ៨- ១២
## ដូចតទៅនេះ គឺ

* ន័យទី ៨ មោចតុក្កៈ ប្រកបជាមួយអកុសលចិត្ត ១២

* ន័យទី ៩ លោភិកៈ ប្រកបជាមួយលោភមូលចិត្ត ៨
* ន័យទី ១០ ទោចតុក្កៈ ប្រកបជាមួយទោសមូលចិត្ត ២
* ន័យទី ១១ ថីទុកៈ ប្រកបនឹងអកុសលចិត្តសសង្ខារិក៥
* ន័យទី ១២ វិចិកិច្ឆា ប្រកបនឹងវិចិកិច្ឆាសម្បយុត្តចិត្ត១

អកុសលចេតសិក១៤ មានសង្គហគាថាទី៧ ពោលទុក ២ គាថា ដូចតទៅនេះ-

**សង្គហគាថា**

៧. សព្វាបុញ្ញេសុ ចត្តារោ លោភមូលេ តយោ គតា
ទោសមូលេសុ ចត្តារោ សសង្ខារេ ទ្វយន្តថា ។
វិចិកិច្ឆា វិចិកិច្ឆា ចិត្តេ ចាតិ ចតុទ្ទស
ទ្វាទសាកុសលេស្វេវ សម្បយុជ្ជន្តិ បញ្ចធា ។

អកុសលចេតសិក ១៤ ប្រកបជាមួយអកុសលចិត្តទាំង ១២ មាន ៥ ន័យ គឺ ន័យទី ១ មោចតុក្កចេតសិក ប្រកបក្នុងអកុសលចិត្តទាំងអស់, ន័យទី

២ លោភិកចេតសិក ប្រកបក្នុងលោភមូលចិត្ត៨, ន័យទី ៣ ទោចតុក្កចេតសិក ប្រកបក្នុងទោសមូលចិត្ត ២, ន័យទី ៤ ថីទុកចេតសិក ប្រកបក្នុងអកុសលចិត្តសសង្ខារិក ៥, ន័យទី ៥ វិចិកិច្ឆាចេតសិក ប្រកបក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១ ។

សោភណចេតសិក ២៥

ប្រកបជាមួយសោភណចិត្ត ៥៩ ឬ ៩១

តាំងពីន័យទី ១៣ ដល់ទី ១៦ រួម ៤ ន័យ

* ន័យទី ១៣ សោភណសាមារណចេតសិក ១៩ ប្រកបជាមួយនឹងសោភណចិត្ត ៥៩ ឬ ៩១
* ន័យទី ១៤ វិរតិចេតសិក ៣ ប្រកបជាមួយសោភណចិត្ត ១៦ ឬ ៤៨
* ន័យទី ១៥ អប្បមញ្ញាចេតសិក ២ ប្រកបជាមួយសោភណចិត្ត បាន ២៨
* ន័យទី ១៦ បញ្ញាចេតសិក ១ ប្រកបជាមួយសោភណ

ចិត្ត បាន ៤៧ ឬ ៧៩

សោភណចេតសិក ២៥ មានសង្គហគាថាទី ៨ ពោលទុក ២ គាថា ដូចតទៅនេះ ៖

## សង្គហគាថា

៨. ឯកូនវីសតិ ធម្មា ជាយន្តេកូនសដ្ឋិសុ
តយោ សោឡស ចិត្តេសុ អដ្ឋវីសតិយំ ទ្វយំ ។
បញ្ញា បកាសិតា សត្ត ចត្តាឡីស វិធេសុបិ
សម្បយុត្តា ចតុធេវំ សោភណេ ស្វេវ សោភណា ។

សោភណចេតសិក២៥ រមែងកើតក្នុងសោភណចិត្ត ៥៩ ឬ ៩១ មាន ៤ ន័យ. ន័យទី១ សោភណសាធារណចេតសិក ១៩ កើតក្នុងសោភណចិត្ត ៥៩ ឬ៩១ . ន័យទី២ វិរតិចេតសិក៣ កើតក្នុងចិត្ត១៦ ឬ៤៨. ន័យទី៣ អប្បមញ្ញាចេតសិក២ កើតក្នុងចិត្ត២៨ . ន័យទី៤ បញ្ញាចេតសិក១ បណ្ឌិតប្រកាសទុកក្នុងចិត្ត៤៧ ឬ៧៩ ដោយប្រការដូច្នេះ ។

# អធិប្បាយ

១-សោភណសាធារណចេតសិក ១៩ មានសទ្ធាជាដើម ប្រកបបានទូទៅក្នុងសោភណចិត្ត ៥៩ ឬ ៩១ គឺ កាមាវចរសោភណចិត្ត ២៤ មហគ្គតចិត្ត ២៧ , លោកុត្តរចិត្ត ៨ ឬ ៤០ ។

២-វិរតិចេតសិក ៣ គឺ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ប្រកបជាមួយសោភណចិត្តបាន ១៦ ឬ៤៨ គឺ មហាកុសលចិត្ត ៨, លោកុត្តរចិត្ត ៨ ឬ៤០ ។

វិរតិចេតសិក ៣ នេះ កើតក្នុងមហាកុសលចិត្ត ៨ រមែងមិនកើតព្រមគ្នាទាំង ៣ ទេ ព្រោះមានអារម្មណ៍ផ្សេងគ្នា, តែកាលកើតក្នុងលោកុត្តរចិត្ត ៨ ឬ ៤០ រមែងកើតបានព្រមគ្នាទាំង ៣ ព្រោះជាអង្គមគ្គ មានព្រះនិព្វានជាអារម្មណ៍ តែមួយដូចគ្នា ។

វិរតិចេតសិក ៣ នេះ មិនកើតក្នុងមហាវិបាកចិត្ត ៨ មហាកិរិយាចិត្ត ៨ និងមហគ្គតចិត្ត ២៧, ព្រោះមហាវិបាក

ចិត្ត ៨ មិនមានវិរមិតព្វវត្ថុ(វត្ថុគប្បីវៀរ) និងព្រោះមហាកិរិយាចិត្ត ៨ ជាចិត្តរបស់ព្រះអរហន្ត ដែលលោកបានប្រហារទុច្ចរិតកម្ម ដោយសមុច្ឆេទប្បហានៈហើយ និងដែលមិនកើតក្នុងមហគ្គតចិត្ត ២៧ នោះ ព្រោះមហគ្គតចិត្ត ២៧ មានអារម្មណ៍ជាមហគ្គត មិនមានវិរមិតព្វវត្ថុ ។

៣-អប្បមញ្ញាចេតសិក ២ គឺ ករុណានិងមុទិតាចេតសិកកើតក្នុងចិត្ត ២៨ គឺ

មហាកុសលចិត្ត៨, មហាកិរិយាចិត្ត៨, រូបាវចរចិត្ត១២ (វៀរបញ្ចមជ្ឈាន),

+ អប្បមញ្ញាចេតសិក ២ នេះ គេចិអាចារ្យពោលថាកើតក្នុងចិត្ត ២០ គឺ -

មហាកុសលសោមនស្សចិត្ត ៤, មហាកិរិយាសោមនស្សចិត្ត ៤ , រូបាវចរចិត្ត ១២ ។

មិនកើតក្នុងមហាកុសលចិត្ត និងមហាកិរិយាចិត្តដែលជាឧបេក្ខាវេទនា ។

+ អដ្ឋកថាចារ្យពោលថា ការយល់របស់កេចិអាចារ្យ ត្រូវពាក់កណ្ដាល ខុសពាក់កណ្ដាល, ដែលត្រូវនោះ គឺ អ្នកចម្រើនករុណា និងមុទិតាកម្មដ្ឋាននោះ ផ្ដេកដើម ៗ កាល នៅជាបរិកម្មភាវនា និងជាបរិកម្មនិមិត្ត ដែលមិនទាន់ដល់ ឧគ្គហនិមិត្ត, ករុណា និងមុទិតា រមែងកើតដោយចិត្តដែលជា សោមនស្សវេទនា តែកាលចម្រើនករុណា និងមុទិតាកម្មដ្ឋាន នោះ ទៅដរាបដល់ឧគ្គហនិមិត្តជំនាញល្អហើយ ករុណា និង មុទិតា រមែងអាចកើតជាមួយនឹងចិត្តដែលជាសោមនស្ស វេទនាក៏បាន កើតជាមួយនឹងចិត្តដែលជាឧបេក្ខាវេទនាក៏បាន ដូច្នោះ កាលដែលពោលថា ករុណា និងមុទិតាចេតសិក មិន កើតនៅក្នុងឧបេក្ខាវេទនា មិនត្រឹមត្រូវទេ ។

អប្បមញ្ញាចេតសិក ២ នេះ មិនកើតក្នុងមហាវិបាក ចិត្ត ៨ ក្នុងរូបាវចរបញ្ចមជ្ឈានចិត្ត ៣ ក្នុងអរូបាវចរចិត្ត ១២ និងលោកុត្តរចិត្ត ៨ ឬ ៤០ នោះ ព្រោះមហាវិបាកចិត្ត ៨ នឹងកើតឡើងបាន ក៏ត្រូវអាស្រ័យកាមារម្មណ៍ ដែលជា

អារម្មណ៍បរមត្ថ ចំណែកអប្បមញ្ញាចេតសិក មានទុក្ខិតសត្ត បញ្ញត្តិ និងសុខិតសត្តបញ្ញត្តិជាអារម្មណ៍ ដែលមិនប្រកបជាមួយនឹងរូបាវចរបញ្ចមជ្ឈានចិត្ត ៣, ព្រោះរូបាវចរបញ្ចមជ្ឈានចិត្ត ៣, មានមជ្ឈត្តសត្តបញ្ញត្តិជាអារម្មណ៍, ដែលមិនកើតក្នុងអរូបាវចរ ១២, ព្រោះអរូបាវចរទាំងនោះ មានអារម្មណ៍ប្រណីតជាង, និងដែលមិនកើតក្នុងលោកុត្តរ ៨ ឬ ៤០ នោះ ព្រោះលោកុត្តរចិត្ត មាននិព្វានជាអារម្មណ៍ ។

៤-បញ្ញាចេតសិក ១ កើតក្នុងចិត្ត បាន ៤៧ ឬ ៧៩ គឺ កាមាវចរសោភណញាណសម្បយុត្តចិត្ត ១២, មហគ្គតចិត្ត ២៧, លោកុត្តរចិត្ត ៨ ឬ៤០

## អនិយតយោគី និងនិយតយោគីចេតសិក

អនិយតយោគីចេតសិក បានដល់ ចេតសិក ១១ មានឥស្សាជាដើម កើតក្នុងចិត្តបានមិនប្រាកដ គឺ គ្រាខ្លះក៏ប្រកប គ្រាខ្លះក៏មិនប្រកប, ក្នុងខណៈដែលនឹងប្រកបជាមួយចិត្ត មិន

ប្រកបព្រមគ្នាខ្លះ ប្រកបព្រមគ្នាខ្លះ ។ ចំណែកនិយតយោគីចេតសិក បានដល់ ចេតសិក ៤១ ដែលនៅសល់អំពីចេតសិកដែលពោលហើយ រមែងប្រកបជាមួយនឹងចិត្តបានពិតប្រាកដ តាមន័យដែលពោលទុកក្នុងសង្គហគាថាទី ៩ ( រួម ២ គាថា ) ដូចតទៅ ៖

## សង្គហគាថា

៩. ឥស្សាមច្ឆេរកុក្កុច្ច    វិរតិករុណាទយោ
នានា កទាចិ មានោ ច    ថីនមិទ្ធំ តថា សហ ។
យថាវុត្តានុសារេន    សេសា និយតយោគិនោ
សង្គហញ្ច បវក្ខាមិ    តេសន្ទានិ យថារហំ ។

*អនិយតយោគីចេតសិក ១១ គឺ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ លោកិយ វិរតិ ៣ ករុណា និងមុទិតា រួម ចេតសិក ៨ នេះ ប្រកបជាមួយ ចិត្តបាន គ្រាខ្លះ មិនប្រកបព្រមគ្នា ហៅថា នានាកទាចិចេតសិក ។*

មានះចេតសិក ១ ក៏ប្រកបជាមួយចិត្ត បានគ្រាខ្លះ ហៅថា កទាចិចេតសិក ។ ថីនៈនិងមិទ្ធៈ ក៏ប្រកបជាមួយចិត្តបានគ្រាខ្លះ តែថីនៈនិងមិទ្ធៈ( ទាំង ២ ) ប្រកបជាមួយចិត្តបានព្រមគ្នា ហៅថា សហកទាចិចេតសិក ។ ចេតសិក ៤១ នៅសល់អំពីន័យដែលពោលហើយ ជានិយតយោគីចេតសិក ។ ឥឡូវនេះ ខ្ញុំនឹងពោលសង្គហន័យនៃចិត្ត និងចេតសិកទាំងនោះ តាមសមគួរ ។

## អធិប្បាយអនិយតយោគីជាដើម

គាថានេះ បែកចេតសិក ៥២ ចេញជា ២ ពួក គឺ

១-**អនិយតយោគីចេតសិក** ( ដែលប្រកបក្នុងចិត្ត មិនប្រាកដ )

២-**និយតយោគីចេតសិក** ( ដែលប្រកបក្នុងចិត្ត ពិតប្រាកដ )

អនិយតយោគីចេតសិក បានដល់ ចេតសិក ១១ គឺ មានះ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ ថីនៈ មិទ្ធៈ លោកិយវិរតិ ៣

និងអប្បមញ្ញា ២ ។

ចេតសិក ១១ នេះ ចែកចេញជា ៣ ប្រភេទ គឺ

១-នានាកទាចិចេតសិក មាន ៨

២-កទាចិចេតសិក មាន ១

៣-សហាកទាចិចេតសិក មាន ២

## នានាកទាចិចេតសិក

* ចេតសិកទាំង ៨ នេះ គឺ ៖

-ទោចតុក្កៈ ៣ គឺ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ (វៀរទោសៈ)

-លោកិយវិរតិ ៣ គឺ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ

-អប្បមញ្ញា ២ គឺ ករុណា មុទិតា

ជាចេតសិកប្រកបជាមួយចិត្ត មិនបានប្រាកដទេ គឺ គ្រាខ្លះក៏ប្រកប គ្រាខ្លះក៏មិនប្រកប, កាលប្រកបក្នុងចិត្ត (ចេតសិក ៨ នេះ) ក៏ប្រកបម្ដងមួយ ៗ ប៉ុណ្ណោះ មិនប្រកបព្រមនឹងចេតសិក ៧ ទៀតឡើយ, ព្រោះដូច្នោះ ទើប

ហៅថា **នានាកទាចិចេតសិក ។**

## កទាចិចេតសិក

**មានះចេតសិកនេះ** កាលកើត រមែងប្រកបជាមួយនឹងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ណាមួយ គ្រាខ្លះក៏មិនប្រកប បើមានសេចក្តីសំគាល់ថា ខ្លួនមាន ឬមានសេចក្តីប្រកាន់ថា យើងល្អជាងគេជាដើម មានះចេតសិកនេះ ក៏កើតឡើងរួមជាមួយលោភមូលចិត្ត ៤ នោះ ដែលមិនប្រកបជាមួយនឹងសេចក្តីឃើញខុសទេ ចេតសិកនេះ ទើបចាត់នៅក្នុងប្រភេទដែលមិនប្រាកដ ព្រោះដូច្នោះ ទើបលោកហៅថា **កទាចិចេតសិក ។**

## សហកទាចិចេតសិក

ថីនៈនិងមិទ្ធចេតសិកទាំង ២ នេះ កើតរួមជាមួយគ្នាជានិច្ច មិនប្រាសចាកគ្នា, តែក៏ចាត់ចូលនៅក្នុងប្រភេទ

ចេតសិកដែលមិនប្រាកដដែរ ព្រោះគ្រាខ្លះក៏ប្រកបជាមួយចិត្ត គ្រាខ្លះក៏មិនប្រកប បើចិត្តជាអសង្ខារិក ជាចិត្តមានកម្លាំង ថីនៈ និងមិទ្ធៈ ក៏មិនចូលទៅប្រកប, បើខណៈចិត្តនោះជាសសង្ខារិក ជាចិត្តមិនមានកម្លាំង ក្នុងគ្រាខ្លះ ចេតសិកទាំង ២ នេះ រមែងចូលទៅប្រកបព្រមគ្នាទាំង ២ ចេតសិក ព្រោះដូច្នោះ ទើបលោកហៅថា **សហកទាចិចេតសិក ។**

<u>ក្នុងវិភាវិនីដីកា</u> ពោលថា ថីនៈ និង មិទ្ធៈ គ្រាខ្លះកើតព្រមគ្នានឹងចេតសិក គឺ

\+ កើតព្រមជាមួយនឹងឥស្សា មច្ឆរិយៈ និងកុក្កុច្ចៈ ក្នុងបដិឃចិត្ត (ទោសមូលចិត្ត) ដែលជាសសង្ខារិកចិត្ត

\+ កើតព្រមជាមួយនឹងមានះ នៅក្នុងទិដ្ឋិវិប្បយុត្តសសង្ខារិកចិត្ត និងក្នុងកាលគ្រាខ្លះ គឺ ក្នុងវេលាប្រកបជាមួយនឹងសសង្ខារិកចិត្តដែលក្រៅពីបដិឃចិត្ត ដែលប្រាសចាកទិដ្ឋិទាំងនោះ ឬសូម្បីក្នុងវេលា ដែលប្រកបដោយបដិឃសសង្ខារិកចិត្តនោះ និងទិដ្ឋិវិប្បយុត្តសសង្ខារិកចិត្តទាំង ៥

នោះ រមែងកើតឡើងផ្សេងខណៈគ្នា ។

តែអាចារ្យមួយពួកទៀត ប្រកបពាក្យទុកត្រឹមប៉ុណ្ណេះ ថា មួយទៀត មានះ និងថីនៈ មិទ្ធៈ គ្រាខ្លះ កើតផ្សេងខណៈគ្នា គ្រាខ្លះកើតរួមគ្នា( គឺ ព្រមគ្នា ) ។

**និយតយោគីចេតសិក** បានដល់ ចេតសិក ៤១ គឺ

សព្វចិត្តសាធារណចេតសិក៧ បកិណ្ណកចេតសិក៦ មោចតុក្កចេតសិក៤ លោភចេតសិក១ ទិដ្ឋិចេតសិក១ ទោសចេតសិក១ វិចិកិច្ឆាចេតសិក១ សោភណសាធារណចេតសិក១៩ បញ្ញាចេតសិក១ ។

## អធិប្បាយ និយតយោគីចេតសិក

-ក្នុងវេលាណាចិត្ត ៨៩ ឬ ១២១ កើតឡើង វេលានោះ សព្វចិត្តសាធារណចេតសិក ៧ រមែងកើតរួមជាមួយជានិច្ច ។

-ក្នុងវេលាណា ចិត្ត ៥៥ ចិត្ត ៦៦ ចិត្ត ៧៨ឬ

១១០ ចិត្ត ៧៣ឬ១០៥ ចិត្ត ៥១ ចិត្ត ៦៩ឬ១០១ កើតឡើង វេលានោះ បកិណ្ណកចេតសិកទាំង ៦ នេះ គឺ វិតក្កៈ វិចារៈ អធិមោក្ខៈ វីរិយៈ បីតិ ឆន្ទៈ ក៏កើតរួមជាមួយចិត្តនោះ ៗ តាមលំដាប់ជានិច្ច ។

-ក្នុងវេលាណា អកុសលចិត្ត១២ កើតឡើង វេលានោះ មោចតុក្កចេតសិក គឺ មោហៈ អហិរកៈ អនោត្តប្បៈ ឧទ្ធច្ចៈ រមែងកើតជាមួយចិត្តនោះ ដោយប្រាកដ ។

-វេលាណា លោភមូលចិត្ត ៨ កើតឡើង វេលានោះ លោភចេតសិក រមែងកើតជាមួយលោភមូលចិត្ត ដោយប្រាកដជានិច្ច ។

-វេលាណា ទិដ្ឋិគតសម្បយុត្តចិត្ត៤ កើតឡើង វេលានោះ ទិដ្ឋិចេតសិក រមែងកើតជាមួយចិត្តនោះ ដោយពិត ។

-វេលាណា វិចិកិច្ឆាសម្បយុត្តចិត្តកើតឡើង វេលានោះ វិចិកិច្ឆាចេតសិក រមែងចូលទៅប្រកបជាមួយចិត្តនោះ ដោយប្រាកដជានិច្ច ។

-វេលាណា សោភណចិត្ត ៥៩ ឬ ៩១ កើតឡើង វេលានោះ សោភណសាមារណចេតសិក ១៩ រមែងកើតជាមួយសោភណចិត្តនោះ គ្រប់ដួង ដោយប្រាកដជានិច្ច ។

-វេលាណា ចិត្តសម្បយុត្តដោយញាណ ៤៧ ឬ ៧៩ កើតឡើង វេលានោះ បញ្ញាចេតសិក រមែងកើតរួមជាមួយចិត្តនោះ ដោយប្រាកដជានិច្ច ។

មួយទៀត វិរតិចេតសិក ៣ កាលកើតក្នុងលោកុត្តរចិត្ត ៨ ឬ ៤០ ក៏ជានិយតយោគីចេតសិក តែហៅថា **និយតឯកតោចេតសិក** ព្រោះជាអង្គមគ្គ ។

**ចប់ សម្បយោគន័យ**

# សង្គហន័យ

*សង្គហៈ ប្រែថា ការរួបរួម ឬការសង្គ្រោះ ដោយន័យនេះ សំដៅដល់ការរួបរួម គឺ ការរាប់ចិត្តនីមួយ ៗ ដែលមានចេតសិកកើត រួមជាមួយផង មានចេតសិកអ្វីខ្លះ ឬការរាប់ចេតសិកទាំងឡាយ ដែលកើតរួមជាមួយចិត្តតែមួយ ៗ, ដូចសង្គហគាថាតទៅនេះ ៖*

## សង្គហគាថា

**១០.** ឆត្តឹសានុត្តរេ ធម្មា    បញ្ចត្តឹស មហគ្គតេ
អដ្ឋត្តឹសាបិ លព្ភន្តិ    កាមាវចរសោភណេ ។
សត្តវីសត្យបុញ្ញម្ហិ    ទ្វាទសាហេតុកេតិ ច
យថា សម្ភវយោគេន    បញ្ចធា តត្ថ សង្គហោ ។

*លោកុត្តរចិត្ត មានចេតសិកកើតរួម ៣៦. មហគ្គតចិត្ត មានចេតសិកកើតរួម ៣៥. កាមាវចរសោភណចិត្ត មានចេតសិកកើត ៣៨. អកុសល*

ចិត្ត មានចេតសិកកើតរួម ២៧. អហេតុកចិត្ត មានចេតសិកកើតរួម ១២. ព្រោះដូច្នោះ ក្នុងចិត្ត ៨៩ ឬ ១២១ នោះ ទើបបានសង្គហៈ ៥ ន័យ តាមដែលប្រកបជាមួយគ្នាកើតឡើង ។

## សង្គហៈដោយសង្ខេប ៥ ន័យ

សង្គហគាថានេះ សម្តែងការសង្គ្រោះរបស់ចិត្ត ដោយសង្ខេប មាន ៥ ន័យ គឺ ៖

១-លោកុត្តរចិត្ត ៨ មានចេតសិកកើតរួម ៣៦ ១ ន័យ

២-មហគ្គតចិត្ត ២៧ មានចេតសិកកើតរួម ៣៥ ១ ន័យ

៣-កាមាវចរសោភណចិត្ត ២៤ មានចេតសិកកើតរួម ៣៨, ១ ន័យ

៤-អកុសលចិត្ត ១២ មានចេតសិកកើតរួម ២៧ ១ ន័យ

៥-អហេតុកចិត្ត ១៨ មានចេតសិកកើតរួម ១២ (វៀរឆន្ទៈ) ១ ន័យ

## សង្គហៈដោយពិស្តារ ៣៣ ន័យ គឺ

| | | | | |
|---|---|---|---|---|
| ១-លោកុត្តរចិត្ត | ៤០ | មាន | ៥ | ន័យ |
| ២-មហគ្គតចិត្ត | ២៧ | មាន | ៥ | ន័យ |
| ៣-កាមាវចរសោភណចិត្ត | ២៤ | មាន | ១២ | ន័យ |
| ៤-អកុសលចិត្ត | ១២ | មាន | ៧ | ន័យ |
| ៥-អហេតុកចិត្ត | ១៨ | មាន | ៤ | ន័យ |
| រួមចិត្ត | ១២១ | មាន | ៣៣ | ន័យ |

## អធិប្បាយសង្គហន័យ ៥ ឬ ៣៣ ន័យ

១-លោកុត្តរចិត្ត ៤០ មាន ៥ ន័យ លោកពោលទុកក្នុងសង្គហគាថាទី ១១ ដូចតទៅនេះ ៖

### សង្គហគាថា

**១១.** ឆត្តឹស បញ្ចតឹសា ច ចតុត្តឹស យថាក្កមំ
តេត្តឹស ទ្វយមិច្ចេវំ បញ្ចធានុត្តរេ ឋិតា ។

លោកុត្តរចិត្ត ៤០ មានសង្គហៈ ៥ ន័យ គឺ

ន័យទី ១ មានចេតសិកកើតរួម ៣៦.

**ន័យទី ២ មានចេតសិកកើតរួម ៣៥.**

**ន័យទី ៣ មានចេតសិកកើតរួម ៣៤.**

**ន័យទី ៤ - ទី ៥ មានចេតសិកកើតរួម ៣៣ ។**

## អធិប្បាយលោកុត្តរចិត្ត ៥ ន័យ

លោកុត្តរចិត្ត ៨ គឺ មគ្គចិត្ត៤ និងផលចិត្ត៤ នេះ មានចេតសិកកើតរួម៣៦( វៀរអប្បមញ្ញា២ ) ស្មើគ្នាទាំងអស់ តែកាលរាប់លោកុត្តរចិត្ត ដោយពិស្តារ៤០ ទើបមានសង្គហៈ៥ ន័យ ដោយអំណាចនៃអង្គឈាន ដូចតទៅនេះ ៖

*ន័យទី ១ លោកុត្តរបឋមជ្ឈានចិត្ត ៨ មានចេតសិកកើតរួម ៣៦ គឺ អញ្ញសមានាចេតសិក ១៣ សោភណចេតសិក ២៣ ( វៀរអប្បមញ្ញា២ )

*ន័យទី ២ លោកុត្តរទុតិយជ្ឈានចិត្ត ៨ មានចេតសិកកើតរួម ៣៥ គឺ អញ្ញសមានាចេតសិក ១២ ( វៀរវិតក្កៈ ) សោភណចេតសិក ២៣ ( វៀរអប្បមញ្ញា )

*ន័យទី ៣ លោកុត្តរតតិយជ្ឈានចិត្ត ៨ មានចេតសិកកើតរួម ៣៤ គឺ អញ្ញសមានាចេតសិក ១១ (វៀរវិតក្កៈវិចារៈ) សោភណចេតសិក ២៣

*ន័យទី ៤ លោកុត្តរចតុត្ថជ្ឈានចិត្ត ៨ មានចេតសិកកើតរួម ៣៣ គឺ អញ្ញសមានាចេតសិក១០ (វៀរវិតក្កៈវិចារៈបីតិ) សោភណចេតសិក២៣

*ន័យទី ៥ លោកុត្តរបញ្ចមជ្ឈានចិត្ត ៨ មានចេតសិកកើតរួម ៣៣ គឺ អញ្ញសមានាចេតសិក១០ (វៀរវិតក្កៈវិចារៈបីតិ) សោភណចេតសិក២៣

**២-<u>មហគ្គតចិត្ត ២៧</u>** មានសង្គហៈ ៥ ន័យពោលទុកក្នុងសង្គហគាថាទី ១២ ដូចតទៅនេះ ៖

## សង្គហគាថា

**១២.** បញ្ចត្តឹស ចតុត្តឹស    តេត្តឹស យថាក្កមំ
ទ្វត្តឹស ចេវ តឹសេតិ    បញ្ចធាវ មហគ្គតេ

មហគ្គតចិត្ត ២៧ មានសង្គហៈ ៥ ន័យ
តាមលំដាប់ គឺ

ន័យទី ១ មានចេតសិកកើតរួម ៣៥.
ន័យទី ២ មានចេតសិកកើតរួម ៣៤.
ន័យទី ៣ មានចេតសិកកើតរួម ៣៣.
ន័យទី ៤ មានចេតសិកកើតរួម ៣២.
ន័យទី ៥ មានចេតសិក កើតរួម ៣០ ។

## អធិប្បាយមហគ្គតចិត្ត ៥ ន័យ

មហគ្គតចិត្ត ២៧[១] គឺ រូបាវចរចិត្ត ១៥ អរូបាវចរចិត្ត ១២ មានសង្គហៈ ៥ ន័យ ដោយអំណាចនៃអង្គឈាន ទើបធ្វើឱ្យចេតសិកកើតរួម មិនស្មើគ្នា គឺ

*ន័យទី ១ រូបាវចរបឋមជ្ឈានចិត្ត ៣ មានចេតសិក

---

១. មិនមានវិរតិ ៣ ព្រោះមហគ្គតចិត្តមិនមានវត្ថុដែលគប្បីវៀរ

៣៥ គឺ អញ្ញសមានាចេតសិក ១៣ សោភណចេតសិក ២២

*ន័យទី ២ រូបាវចរទុតិយជ្ឈានចិត្ត ៣ មានចេតសិក ៣៤ គឺ អញ្ញសមានាចេតសិក ១២ (វៀរវិតក្កៈ) សោភណចេតសិក ២២

* ន័យទី ៣ តតិយជ្ឈានចិត្ត ៣ មានចេតសិកកើតរួម ៣៣ គឺ អញ្ញសមានាចេតសិក ១១ (វៀរវិតក្កៈវិចារៈ) សោភណចេតសិក ២២

*ន័យទី ៤ ចតុត្ថជ្ឈានចិត្ត ៣ មានចេតសិក កើតរួម ៣២ គឺ អញ្ញសមានាចេតសិក១០ (វៀរវិតក្កៈវិចារៈបីតិ) សោភណចេតសិក២២

*ន័យទី ៥ រូបាវចរបញ្ចមជ្ឈានចិត្ត ៣ អរូបាវចរចិត្ត ១២ មានចេតសិកកើតរួម ៣០ គឺ អញ្ញសមានាចេតសិក ១០ (វៀរវិតក្កវិចារបីតិ) សោភណចេតសិក ២០ (វៀរអប្បមញ្ញា ២)

៣-<u>*កាមាវចរសោភណចិត្ត ២៤*</u> *ចាត់ជាគូបាន ១២ គូ, ទើបជាសង្គហៈមួយ ៗ ២ ន័យ តាមដែលពោលទុកក្នុងសង្គហគាថាទី ១៣ ដូចតទៅនេះ ៖*

## សង្គហគាថា

១៣. អដ្ឋត្តឹស សត្តត្តឹស ទ្វយំ ឆត្តឹសកំ សុភេ
បញ្ចត្តឹស ចតុត្តឹស ទ្វយំតេត្តឹសកំ ក្រិយេ ។
តេត្តឹស បាកេ ទ្វត្តឹស ទ្វយេកត្តឹសកំ ភវេ
សហេតុកាមាវចរ បុញ្ញបាលក្រិយាមនេ ។

*កាមាវចរកុសលចិត្ត ៨ មានសង្គហៈ ៤ ន័យ ។ ន័យទី ១ មានចេតសិក កើតបាន ៣៨. ន័យទី ២-៣ មានចេតសិកកើតបានមួយន័យ ៗ ៣៧ ប៉ុនគ្នា. ន័យទី ៤ មានចេតសិកកើតបាន ៣៦ ។ កាមាវចរកិរិយាចិត្ត ៨ មានសង្គហៈ ៤ ន័យ ។ ន័យទី ១ មានចេតសិកកើតបាន ៣៥. ន័យទី*

២-៣ មានចេតសិកកើតបានមួយន័យ ៗ ៣៤ ប៉ុនគ្នា. ន័យទី ៤ មានចេតសិកកើតបាន ៣៣ ។

កាមាវចរវិបាកចិត្ត ៨ មានសង្គហៈ ៤ ន័យ ។ ន័យទី ១ មានចេតសិកកើតបាន ៣៣. ន័យទី ២-៣ មានចេតសិកកើតមួយន័យ ៗ ៣២ ប៉ុនគ្នា. ន័យទី ៤ មានចេតសិកកើតបាន ៣១ ។

## អធិប្បាយសង្គហគាថាទី ១៣

១-កាមាវចរកុសលចិត្ត៨ មានសង្គហៈ៤ ន័យ គឺ

*ន័យទី ១ មហាកុសលចិត្តទី ១-២ មានចេតសិកកើតបាន ៣៨ គឺ អញ្ញសមានាចេតសិក ១៣ សោភណចេតសិក ២៥

*ន័យទី ២ មហាកុសលចិត្តទី ៣-៤ មានចេតសិកកើតបាន ៣៧ គឺ អញ្ញសមានាចេតសិក ១៣ សោភណចេតសិក ២៤ ( វៀរបញ្ញា ) ។

*ន័យទី ៣ មហាកុសលចិត្តទី ៥-៦ មានចេតសិកកើតបាន ៣៧ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ) សោភណចេតសិក ២៥

*ន័យទី ៤ មហាកុសលចិត្តទី ៧-៨ មានចេតសិកកើតបាន ៣៦ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ)

សោភណចេតសិក ២៤ (វៀរបញ្ញា) ។

បណ្តាសោភណចេតសិកទាំងនោះ ចេតសិកដែលមិនកើតរួមជាមួយ សោភណចិត្តខ្លះនោះ ព្រះអនុរុទ្ធាចារ្យសម្តែងទុកក្នុងសង្គហគាថាទី ១៤ ដូចតទៅនេះ ៖

## សង្គហគាថា

១៤. នវិជ្ជន្តេត្ថ វិរតី ក្រិយេសុ មហគ្គតេ

អនុត្តរេ អប្បមញ្ញា កាមបាកេ ទ្វយំ តថា ។

***បណ្តាសោភណចិត្តទាំង ៥៩ ឬ ៩១ នោះ. វិរតិចេតសិក ៣ មិនកើតក្នុងកាមាវចរកិរិយាចិត្ត***

១១ និងក្នុងមហគ្គតកិរិយាចិត្ត ៩ ។ អប្បមញ្ញាចេតសិក ២ មិនកើតក្នុងលោកុត្តរចិត្ត ៨ ។ មួយទៀត ក្នុងកាមាវចរវិបាកចិត្ត ៨ មិនមានទាំងវិរតិ ៣ និងអប្បមញ្ញាចេតសិក ២ កើតរួមទេ ។

## អធិប្បាយសង្គហគាថាទី ១៤

កិរិយាចិត្ត ២០ គឺ មហាកិរិយាចិត្ត ៨ មហគ្គតកិរិយាចិត្ត ៩ បញ្ចទ្វារាវជ្ជនចិត្ត ១ មនោទ្វារាវជ្ជនចិត្ត ១ និងហសិតុប្បាទចិត្ត ១ រួមចិត្ត ២០ មិនមានវិរតិចេតសិក ៣ កើតរួមទេ ព្រោះកិរិយាចិត្តទាំងនេះ មិនមានវិរមិតព្វវត្ថុ ជាអារម្មណ៍ ។ ក្នុងមហគ្គតចិត្ត ក៏ដូចគ្នា មិនមានវិរមិតព្វវត្ថុជាអារម្មណ៍ ។

ក្នុងលោកុត្តរចិត្ត ៨ ឬ ៤០ មិនមានអប្បមញ្ញា ២ កើតរួមជាមួយទេ ព្រោះលោកុត្តរចិត្ត មានព្រះនិព្វានជាអារម្មណ៍ ។

ក្នុងមហាវិបាកចិត្ត ៨ ឬកាមាវចរវិបាកចិត្តទាំងអស់ មិនមានវិរតិ ៣ និងអប្បមញ្ញា ២ កើតរួមជាមួយទេ ព្រោះវិបាកទាំងនោះ ជាផលរបស់កុសល និងអកុសលកម្មដែលធ្វើហើយ រមែងមិនញ៉ាំងវិញ្ញត្តិឱ្យកើត និងមិនមានសត្តបញ្ញត្តិជាអារម្មណ៍ ទើបមិនមានចេតសិកទាំង ៥ នេះកើតរួមឡើយ ។

## ចេតសិកធ្វើចិត្តឱ្យផ្សេងគ្នា

## សង្គហគាថា

១៥. អនុត្តរេ ឈានធម្មា អប្បមញ្ញា ច មជ្ឈិមេ
វិរតិញាណបីតិ ច បរិត្តេសុ វិសេសកា ។

ក្នុងលោកុត្តរចិត្ត មានអង្គឈានធ្វើឱ្យផ្សេងគ្នា. ក្នុងមហគ្គតចិត្ត មានអង្គឈាន និងអប្បមញ្ញាធ្វើឱ្យផ្សេងគ្នា. ក្នុងកាមាវចរចិត្ត មានវិរតិ ៣ បញ្ញា ១ បីតិ ១ និងអប្បមញ្ញា ២ ធ្វើឱ្យផ្សេងគ្នា ។

## អធិប្បាយសង្គហគាថាទី ១៥

ក្នុងលោកុត្តរចិត្ត មានអង្គឈាន ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ធ្វើឱ្យផ្សេងគ្នានោះ គឺ វិតក្កៈ ធ្វើឱ្យលោកុត្តរបឋមជ្ឈានចិត្ត ផ្សេងអំពីលោកុត្តរឈានចិត្តដទៃ, វិចារៈធ្វើឱ្យលោកុត្តរទុតិយជ្ឈានចិត្ត ផ្សេងអំពីលោកុត្តរឈានចិត្តដែលនៅសល់, បីតិធ្វើឱ្យលោកុត្តរតតិយជ្ឈានចិត្ត ផ្សេងអំពីលោកុត្តរឈានចិត្តដែលនៅសល់, សុខធ្វើឱ្យលោកុត្តរចតុត្ថជ្ឈានចិត្ត ផ្សេងអំពីលោកុត្តរបញ្ចមជ្ឈានចិត្ត ។ ឧបេក្ខាវេទនា ធ្វើឱ្យលោកុត្តរបញ្ចមជ្ឈានចិត្តផ្សេងអំពីលោកុត្តរឈានចិត្តដែលនៅសល់ ។

ក្នុងមហគ្គចិត្ត មានអប្បញ្ញា ២ គឺ ករុណា និង មុទិតា ធ្វើឱ្យមហគ្គតចិត្ត ១២ (ពីបឋមជ្ឈានដល់ចតុត្ថជ្ឈានចិត្ត) ផ្សេងពីបញ្ចមជ្ឈានចិត្ត ១៥ ។

ចំណែកអង្គនៃឈាន ៥ មានវិតក្កៈជាដើម ដែលធ្វើឱ្យមហគ្គតចិត្តផ្សេងគ្នានោះ ដូចគ្នានឹងលោកុត្តរឈានចិត្តដែល

ពោលមកហើយ ។

ក្នុងកាមាវចរសោភណចិត្ត ២៤ មានវិរតិ ៣ ធ្វើឱ្យមហាកុសលចិត្តផ្សេង អំពីមហាវិបាកចិត្ត និងមហាកិរិយាចិត្ត ។ បញ្ញាចេតសិក ធ្វើឱ្យញាណសម្បយុត្តចិត្ត ផ្សេងអំពីញាណវិប្បយុត្តចិត្ត, បីតិធ្វើឱ្យសោមនស្សសហគតចិត្ត ផ្សេងអំពីឧបេក្ខាសហគតចិត្ត, អប្បមញ្ញា ២ ធ្វើឱ្យមហាកុសលចិត្ត មហាកិរិយាចិត្ត ផ្សេងអំពីមហាវិបាកចិត្ត ។

### ៤-<u>អកុសល ១២</u> មានសង្គហៈ ៧ ន័យ ៖

ក្នុងសង្គហគាថាទី ១០ មានពាក្យថា **សត្តវិសត្យបុញ្ញម្ហិ** ប្រែថា ក្នុងអកុសលចិត្ត ១២ មានចេតសិក ២៧ ប្រកបនោះ ជាការរាប់ចំនួនអកុសលចិត្តដែលមានចេតសិកប្រកបដោយសង្ខេប តែក្នុងសង្គហគាថាតទៅនេះ ជាន័យដែលសម្តែងការរាប់អកុសលចិត្ត ១២ ដោយពិស្តារ ។

## សង្គហគាថា

១៦. ឯកូនវីសដ្ឋារស វីសេកវីស វីសតិ
ពាវីស បណ្ណរសាតិ សត្តធាកុសលេ ឋិតា ។

ក្នុងអកុសលចិត្ត ១២ មានសង្គហៈ ៧ ន័យ ន័យទី១ មានចេតសិក ១៩. ន័យទី២ មានចេតសិក ១៨. ន័យទី៣ មានចេតសិក ២១. ន័យទី៤ មានចេតសិក ២០. ន័យទី៥ មានចេតសិក ២០. ន័យទី៦ មានចេតសិក ២២. ន័យទី៧ មានចេតសិក ១៥ (កើតរួមជាមួយ) ។

## អធិប្បាយសង្គហគាថាទី ១៦

អកុសលចិត្ត ១២ កាលពោលដោយសង្ខេប មានចេតសិក ប្រកបបាន ២៧ គឺ

អញ្ញសមានាចេតសិក ១៣ អកុសលចេតសិក ១៤, បើចែកដោយពិស្តារ បានចេតសិកប្រកបផ្សេងគ្នា មាន

សង្គហៈ ៧ ន័យ គឺ ៖

-លោភមូលចិត្ត ៨ បាន ៤ ន័យ

-ទោសមូលចិត្ត ២ បាន ២ ន័យ

-មោហមូលចិត្ត ២ បាន ១ ន័យ

លោភមូលចិត្ត ៨ បាន ៤ ន័យ គឺ ៖

+ ន័យទី ១ លោភមូលចិត្តទី ១ និងទី ៣ (សោមនស្សអសង្ខារិក ២) មានចេតសិកប្រកបបាន ១៩ ដូច្នេះ គឺ

* លោភមូលចិត្តទី ១ មានអញ្ញសមានាចេតសិក១៣ មោចតុក្កចេតសិក៤ លោភចេតសិក១ ទិដ្ឋិចេតសិក១

* លោភមូលចិត្តទី ៣ មានអញ្ញសមានាចេតសិក១៣ មោចតុក្កចេតសិក៤ លោភចេតសិក១ មានចេតសិក១

+ ន័យទី ២ លោភមូលចិត្តទី ៥ និងទី ៧ (ឧបេក្ខាអសង្ខារិក២) មានចេតសិកប្រកប១៨ ដូច្នេះ គឺ

* លោភមូលចិត្តទី ៥ មាន អញ្ញសមានាចេតសិក

១២ ( វៀរបីតិ ), មោចតុក្កចេតសិក៤, លោភចេតសិក១, ទិដ្ឋិចេតសិក ១,

* លោភមូលចិត្តទី ៧ មាន : អញ្ញសមានាចេតសិក ១២ ( វៀរបីតិ ) មោចតុក្កចេតសិក៤, លោភចេតសិក១, មានចេតសិក ១

+ ន័យទី ៣ លោភមូលចិត្តទី ២ និងទី ៤ ( សោមនស្សសសង្ខារិក ២ ) មានចេតសិកប្រកប ២១ ដូច្នេះ គឺ

* លោភមូលចិត្តទី ២ មាន : អញ្ញសមានាចេតសិក ១៣ , មោចតុក្កចេតសិក ៤, លោភចេតសិក ១, ទិដ្ឋិចេតសិក ១, ថីទុកចេតសិក ២ ។

* លោភមូលចិត្តទី ៤ មាន : អញ្ញសមានាចេតសិក ១៣ , មោចតុក្កចេតសិក ៤ លោភចេតសិក ១, មានចេតសិក ១, ថីទុកចេតសិក ២

+ ន័យទី ៤ លោភមូលចិត្តទី ៦ និងទី ៨ ( ឧបេក្ខា

សសង្ខារិក ២) មានចេតសិកប្រកប ២០ គឺ

* <u>លោភមូលចិត្តទី ៦</u> មាន : អញ្ញសមានាចេតសិក ១២ (វៀរបីតិ), មោចតុក្កចេតសិក ៤, លោភចេតសិក ១, ទិដ្ឋិចេតសិក ១, ថីទុកចេតសិក ២ ។

* <u>លោភមូលចិត្តទី ៨</u> មាន : អញ្ញសមានាចេតសិក ១២ (វៀរបីតិ), មោចតុក្កចេតសិក ៤, លោភចេតសិក ១, មានចេតសិក ១, ថីទុកចេតសិក ២ ។

\+ ន័យទី ៥ ទោសមូលចិត្តទី ១ (ទោមនស្ស អសង្ខារិក) មានចេតសិក២០ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ), មោចតុក្កចេតសិក៤, ទោចតុក្កចេតសិក៤

\+ ន័យទី ៦ ទោសមូលចិត្តទី ២ (ទោមនស្ស សសង្ខារិក) មានចេតសិក ២២ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ), មោចតុក្កចេតសិក ៤ ទោចតុក្កចេតសិក ៤ , ថីទុកចេតសិក ២

\+ ន័យទី ៧ មោហមូលចិត្ត ២ នីមួយ ៗ មាន

ចេតសិកបាន ១៥ គឺ

១-វិចិកិច្ឆាសម្បយុត្តចិត្ត មានចេតសិក ១៥ :
អញ្ញសមានា ១០ (វៀរអធិមោក្ខ បីតិ ឆន្ទៈ)
មោចតុក្កចេតសិក ៤ វិចិកិច្ឆាចេតសិក ១

២-ឧទ្ធច្ចសម្បយុត្តចិត្ត មានចេតសិក ១៥ :
អញ្ញសមានាចេតសិក ១១ (វៀរបីតិ ឆន្ទៈ)
មោចតុក្កចេតសិក ៤ ។

## សព្វាកុសលយោគីចេតសិក

ពាក្យថា សព្វាកុសលយោគីចេតសិក គឺ **សព្វ** = **អកុសល** = **យោគី** = **ចេតសិក** ប្រែថា ចេតសិកប្រកប ក្នុងអកុសលចិត្តទាំងពួង ។

សព្វាកុសលយោគីចេតសិកនេះ បានដល់ ចេតសិក ១៤ ដែលកើតក្នុងអកុសលចិត្ត ១២ ។ តាមដែលពោលទុក ក្នុងសង្គហគាថាតទៅនេះ ៖

## សង្គហគាថា

១៧. សាធារណា ច ចត្តារោ សមានា ច ទសាបរេ
ចុទ្ទសេតេ បវុច្ចន្តិ សព្វាកុសលយោគិនោ ។

*ក្នុងចេតសិក ១៤ គឺ អកុសលសាធារណចេតសិក ៤ អញ្ញសមានាចេតសិក ១០ (វៀរ អធិមោក្ខៈ បីតិ ឆន្ទៈ) ហៅថា សព្វាកុសលយោគីចេតសិក ។*

## អធិប្បាយសង្គហគាថាទី ១៧

*សព្វាកុសលយោគីចេតសិក មាន ១៤ ចេតសិក គឺ សព្វចិត្តសាធារណចេតសិក ៧ បកិណ្ណកចេតសិក ៣ (គឺ វិតក្កៈ វិចារៈ វីរិយៈ), មោចតុក្កចេតសិក ៤ ។*

*សព្វាកុសលយោគីចេតសិក ១៤ នេះ កើតក្នុងអកុសលចិត្ត ១២ បានគ្រប់ដួង ។*

៥-<u>អហេតុកសង្គហៈ</u> មាន ៤ ន័យ ៖

**សង្គហគាថា**

១៨. ទ្វាទសេកាទស ទស សត្ត ចាតិ ចតុព្វិធោ
អដ្ឋារសាហេតុកេសុ ចិត្តុប្បាទេសុ សង្គហោ ។
អហេតុកេសុ សព្វត្ថ សត្ត សេសា យថារហំ
ឥតិ វិត្ថារតោ វុត្តោ តេត្តឹសវិធ សង្គហោ ។

ក្នុងការកើតនៃអហេតុកចិត្ត១៨ មានសង្គហៈ៤ ន័យ, ន័យទី១ មានចេតសិកកើត ១២. ន័យទី២ មានចេតសិកកើត ១១. ន័យទី៣ មានចេតសិកកើត ១០. ន័យទី៤ មានចេតសិកកើត ៧ ។ សព្វចិត្តសាធារណចេតសិក ៧ កើតក្នុងអហេតុកចិត្ត បានគ្រប់. ដែលនៅសល់ បកិណ្ណកចេតសិក ៦ កើតបានតាមសមគួរ ព្រោះដូច្នោះ ដោយពិស្ដារ ទើបមានសង្គហៈ ៣៣ ន័យ ដោយប្រការដូច្នេះ ។

## អធិប្បាយ សង្គហគាថាទី ១៨

អហេតុកចិត្ត ១៨ មានសង្គហៈ ៤ ន័យ គឺ

+ ន័យទី ១ មាន ១ ហសិតុប្បាទចិត្ត ១ មានអញ្ញសមានាចេតសិកកើតបាន ១២ (វៀរឆន្ទៈ) ។

+ ន័យទី ២ មាន ២ មនោទ្វារាវជ្ជនចិត្ត ១ មានអញ្ញសមានាចេតសិកកើតរួមបាន ១១ (វៀរបីតិ ឆន្ទៈ) សោមនស្សអហេតុកវិបាកមនោវិញ្ញាណធាតុ ១ មានអញ្ញសមានាចេតសិកកើតរួមបាន១១ (វៀរវីរិយៈ ឆន្ទៈ) ។

+ ន័យទី ៣ មាន ៥ : បញ្ចទ្វារាវជ្ជនចិត្ត ១ , វិបាកមនោធាតុ ២ , ឧបេក្ខាហេតុកវិបាកមនោវិញ្ញាណធាតុ ២, មានអញ្ញសមានាចេតសិក កើតរួមបាន ១០ (វៀរវីរិយៈ បីតិ ឆន្ទៈ) ។

+ ន័យទី ៤ មាន ១០ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ មានសព្វចិត្តសាធារណចេតសិកកើតរួមបាន ៧ ។

ការដែលឆន្ទចេតសិក មិនកើតរួមជាមួយអហេតុក

ចិត្ត ១៨ នោះ ព្រោះឆន្ទៈជាធម្មជាតិ ពេញចិត្តប្រាថ្នានឹងធ្វើកិច្ចយ៉ាងណានីមួយ ( កត្តុកម្យតា ) ចំណែកអហេតុកចិត្តទាំងនោះកើតឡើង ព្រោះការប្រជុំព្រមនៃបច្ច័យធម៌ មិនបានអាស្រ័យឆន្ទៈ គឺ សេចក្ដីពេញចិត្តកើតឡើង ព្រោះដូច្នោះឆន្ទៈ ទើបមិនកើតរួមជាមួយអហេតុកចិត្តទាំង ១៨ ។

**ចប់ សង្គហន័យ**

# គន្ថកថាមិស្សកន័យ

## សង្គហគាថា

១៩. ឥត្ថំ ចិត្តាវិយុត្តានំ  សម្បយោគញ្ច សង្គហំ
ញត្វា ភេទំ យថាយោគំ  ចិត្តេន សមមុទ្ទិសេ ។

*បណ្ឌិតកាលជ្រាបសម្បយោគន័យ និងសង្គហន័យនៃចេតសិកដែលមិនបែកចេញពីចិត្ត ដោយប្រការដូច្នេះហើយ គប្បីសម្ដែងប្រភេទចេតសិកឱ្យប្រហែលនឹងចិត្តតាមដែលប្រកបបានតទៅ ។*

## អធិប្បាយសង្គហគាថាទី ១៩

*គាថានេះសម្ដែងថា កាលយល់ចូលចិត្តក្នុងសម្បយោគន័យ (ន័យនៃការប្រកបរួមគ្នារបស់ចេតសិកដែលមិនបែកចេញពីចិត្ត ដោយវិធី ១៦ យ៉ាង) និងសង្គហន័យ (ន័យពោលអំពីការរាប់ចិត្តនីមួយ ៗ ដែលមានចេតសិក ប្រកបដោយវិធីផ្សេង ៗ ៣៣ យ៉ាង)ហើយ*

ឥឡូវនេះ សមគួរសម្ដែងន័យទាំង ២ នោះ ឱ្យវិចិត្រពិស្ដារក្រៃលែងឡើង ហៅថា **តទុភយមិស្សកន័យ** (ន័យដែលលាយគ្នានៃន័យទាំង ២ នោះ) ក៏ន័យនេះ ជាការរាប់ចំនួនចេតសិក ដែលប្រកបរួមគ្នាទាំងអស់ នឹងបានចេតសិកដែលរាប់ហើយ រាប់ទៀត ជាចំនួនចេតសិកដល់ ៣.៤២៦ ដោយវិធីរាប់ដូចតទៅនេះ ៖

**១-សព្វចិត្តសាធារណចេតសិក ៧** ប្រកបជាមួយចិត្ត ១២១ (១២១ × ៧) រួមជាចេតសិក ៨៤៧ ។

**២-បកិណ្ណកចេតសិក ៦** ប្រកបជាមួយចិត្ត ដូច្នេះគឺ

-វិតក្កៈ ប្រកបជាមួយចិត្តបាន ៥៥

-វិចារៈ ប្រកបជាមួយចិត្តបាន ៦៦

-អធិមោក្ខៈ ប្រកបជាមួយចិត្តបាន ១១០

-វីរិយៈ ប្រកបជាមួយចិត្តបាន ១០៥

-បីតិ ប្រកបជាមួយចិត្តបាន ៥១

-ឆន្ទៈ ប្រកបជាមួយចិត្តបាន ១០១

+ រួមទាំង ៦ ប្រកបជាមួយចិត្តបាន ៤៨៨ ។

**៣-អកុសលចេតសិក ១៤ ប្រកបជាមួយអកុសលចិត្ត ១២ គឺ**

| | | | | |
|---|---|---|---|---|
| -មោចតុក្កៈ ៤ | កើតក្នុងអកុសលចិត្ត | ១២ | = | ៤៨ |
| -លោភៈ | កើតក្នុងលោភមូលចិត្ត | ៨ | = | ៨ |
| -ទិដ្ឋិ | កើតក្នុងលោភមូលចិត្ត | ៤ | = | ៤ |
| -មានះ | កើតក្នុងលោភមូលចិត្ត | ៤ | = | ៤ |
| -ទោសៈ | កើតក្នុងទោសមូលចិត្ត | ២ | = | ២ |
| -ឥស្សា | កើតក្នុងទោសមូលចិត្ត | ២ | = | ២ |
| -មច្ឆរិយៈ | កើតក្នុងទោសមូលចិត្ត | ២ | = | ២ |
| -កុក្កុច្ចៈ | កើតក្នុងទោសមូលចិត្ត | ២ | = | ២ |
| -វិចិកិច្ឆា | កើតក្នុងមោហមូលចិត្ត | ១ | = | ១ |
| -ថីទុក ២ | កើតក្នុងសសង្ខារិកចិត្ត | ៥ | = | ១០ |

* រួមចេតសិកទាំង ១៤ កើតបានទាំងអស់ = ៨៣

**៤- សោភណចេតសិក ២៥ ប្រកបជាមួយសោភណ**

ចិត្ត ៩១ ( មើលសង្គហគាថាទី ៨ ) គឺ ៖

-សោភណសាមារណចេតសិក ១៩×ចិត្ត៩១ = ១៧២៩

-វិរតិចេតសិក ៣ × ចិត្ត ៤៨ = ១៤៤

-អប្បមញ្ញាចេតសិក ២ × ចិត្ត ២៨ = ៥៦

-បញ្ញាចេតសិក ប្រកបជាមួយចិត្ត ៧៩ = ៧៩

* រួម ចេតសិកទាំង ២៥ ប្រកបបាន = ២.០០៨ ។

## ចេតសិក ប្រកបជាមួយចេតសិក

## អញ្ញសមានាចេតសិក ១៣ = ៦៥៦

-ផស្សៈ ប្រកបជាមួយចេតសិក ៥១ ( វៀរខ្លួនឯង )

-វេទនា ប្រកបជាមួយចេតសិក ៥១ ( វៀរខ្លួនឯង )

-សញ្ញា ប្រកបជាមួយចេតសិក ៥១ ( វៀរខ្លួនឯង )

-ចេតនា ប្រកបជាមួយចេតសិក ៥១ ( វៀរខ្លួនឯង )

-ឯកគ្គតា ប្រកបជាមួយចេតសិក ៥១ ( វៀរខ្លួនឯង )

-ជីវិតិន្ទ្រិយ ប្រកបជាមួយចេតសិក៥១ ( វៀរខ្លួនឯង )

-មនសិការៈ ប្រកបជាមួយចេតសិក ៥១ ( វៀរខ្លួនឯង )

-វិតក្កៈ វិចារៈ វីរិយៈ មានចេតសិកប្រកបនីមួយ ៗ ៥១ (វៀរខ្លួនឯង)

-អធិមោក្ខៈ មានចេតសិកប្រកប៥០ (វៀរវិចិកិច្ឆានិងខ្លួនឯង)

-បីតិ មានចេតសិកប្រកប ៤៦ (វៀរទោចតុក្កៈ៤ វិចិកិច្ឆា និងខ្លួនឯង)

-ឆន្ទៈ មានចេតសិកប្រកប ៥០ (វៀរវិចិកិច្ឆា និងខ្លួនឯង)

## អកុសលចេតសិក ១៤ = ៣០៧

❋ មោចតុក្កៈ ៤ នីមួយ ៗ មានចេតសិកកើតរួម ២៦ = ១០៤ គឺ

អញ្ញសមានាចេតសិក ១៣ អកុសលចេតសិក ១៣ (វៀរខ្លួនឯង)

❋ លោភៈ មានចេតសិកកើតរួម ២១ គឺ អញ្ញសមានាចេតសិក ១៣ , អកុសលចេតសិក ៨ (វៀរទោចតុក្កៈ ៤ វិចិកិច្ឆា និងខ្លួនឯង) ។

❁ ទិដ្ឋិ មានចេតសិកកើតរួម ២០ គឺ អញ្ញសមានាចេតសិក ១៣ អកុសលចេតសិក ៧ (វៀរទោចតុក្ក ៤ វិចិកិច្ឆា មានះ និងខ្លួនឯង) ។

❁ មានះ មានចេតសិក កើតរួម ២០ ដូចទិដ្ឋិចេតសិកនុ៎ះឯង ។

❁ ទោសៈ មានចេតសិកកើតរួម ២១ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ), មោចតុក្កចេតសិក ៤ ទោចតុក្កចេតសិក ៣ (វៀរខ្លួនឯង), ថីទុកចេតសិក ២ ។

❁ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ នីមួយ ៗ មានចេតសិកកើតរួម ១៩ = ៥៧ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ), មោចតុក្កចេតសិក ៤, ទោស ចេតសិក ១, ថីទុកចេតសិក ២ ។

❁ ថីទុកៈ នីមួយ ៗ មានចេតសិកកើតរួម ២៥ = ៥០ គឺ អញ្ញសមានាចេតសិក ១៣, អកុសលចេតសិក ១២ (វៀរវិចិកិច្ឆា និងខ្លួនឯង) ។

❁ វិចិកិច្ឆា មានចេតសិកកើតរួម ១៤ គឺ អញ្ញសមានាចេតសិក ១០ (វៀរបីតិ អធិមោក្ខៈ ឆន្ទៈ) មោចតុក្កចេតសិក ៤ ។

## សោភណចេតសិក ២៥ = ៩១១ គឺ ៖

❁ <u>សោភណសាធារណចេតសិក</u> ១៩ ទីមួយ ៗ មានចេតសិកកើតរួម ៣៧ ( ១៩ × ៣៧ = ៧០៣ ) គឺ ៖

អញ្ញសមានាចេតសិក ១៣ សោភណចេតសិក ២៤ ( វៀរខ្លួនឯង ) ។

❁ <u>លោកិយវិរតិ</u> ៣ ទីមួយ ៗ មានចេតសិកកើតរួម ៣៣ ( ៣ × ៣៣ = ៩៩ ) គឺ អញ្ញសមានាចេតសិក ១៣ , សោភណសាធារណចេតសិក ១៩ , បញ្ញាចេតសិក ១

❁ <u>លោកុត្តរវិរតិ</u> ៣ ទីមួយ ៗ មានចេតសិកកើតរួម ៣៥ ( ៣ × ៣៥ = ១០៥ ) គឺ អញ្ញសមានាចេតសិក ១៣, សោភណសាធារណចេតសិក ១៩, វិរតិ ២

(វៀរខ្លួនឯង), បញ្ញាចេតសិក ១ ។

❋ លោកុត្តរវិរតិ ៣ កើតព្រមគ្នា ឈ្មោះថា **និយតឯកតោចេតសិក ។** ការរាប់ចេតសិកកើតរួមជាមួយវិរតិ ៣ ទាំងលោកិយវិរតិ(៩៩) ទាំងលោកុត្តរ វិរតិ(១០៥) កាលរាប់ដោយសភាវៈរួម ក៏រាប់បាន ១០៥ នោះឯង ។

❋ អប្បមញ្ញា ២ (កើតក្នុងសោភណចិត្ត ២៨ គឺ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ រូបាវចរចិត្ត ១២) មានចេតសិកកើតរួមជាមួយ ៣៣ = ៦៦ គឺ អញ្ញសមានាចេតសិក ១៣, សោភណសាមារណចេតសិក ១៩, បញ្ញាចេតសិក ១

❋ បញ្ញាចេតសិក (កើតក្នុងសោភណចិត្ត ៧៩ គឺ កាមាវចរសោភណញាណសម្បយុត្តចិត្ត ១២ មហគ្គតចិត្ត ២៧ និងលោកុត្តរចិត្ត ៤០) មានចេតសិកកើតរួមជាមួយ ៣៧ គឺ
អញ្ញសមានាចេតសិក ១៣ សោភណចេតសិក ២៤

( វៀវខ្ទនឯង )

រួមចេតសិកកើតរួមជាមួយចេតសិក មាន ១៨៧៤ គឺ

អញ្ញសមានាចេតសិក ៦៥៦
អកុសលចេតសិក ៣០៧ = ១៨៧៤
សោភណចេតសិក ៩១១

## អវសានគាថា

ឥច្ចានុរុទ្ធ រចិតេ អភិធម្មត្ថសង្គហេ
ទុតិយោ បរិច្ឆេទោយំ សមាសេនេវ និដ្ឋិតោ ។

បរិច្ឆេទទី ២ ឈ្មោះថា ចេតសិកសង្គហវិភាគ ក្នុងបករណ៍ អភិធម្មត្ថសង្គហៈ ដែលព្រះអនុរុទ្ធាចារ្យរចនាទុក ចប់ហើយដោយប្រការដូច្នេះ ។

**បរិច្ឆេទទី ២ ចេតសិកសង្គហវិភាគ ចប់**

យំ ឯត្ថ វុឌ្ឍិមន្តោ សលក្ខណា បូជិតា បរិច្ឆិន្នា
វុត្តាធិកា ច ធម្មា អភិធម្មោ តេន អក្ខាតោ ។
ព្រោះហេតុដែលធម៌ទាំងឡាយ មានសេចក្ដីចម្រើន
មានការកំណត់ ជាធម៌ដែលបុគ្គលបូជាហើយ ជាធម៌
ដែលបណ្ឌិតកាត់ជាចំណែកៗ និងជាធម៌ដ៏ក្រៃលែង
ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ក្នុងព្រះ
អភិធម្មនេះ ដូច្នោះ ទើបលោកពោលថា អភិធម្ម ។



ភិក្ខុ អគ្គធីរោ គង់ សុមិត្ត